សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីដាស់តឿន

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ហៃ លីហួរ**
លោក **អុល ផានុ**

ណែនាំដោយ
លោក **យ៉ុខ និល**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# នីតិវិធីដាស់តឿន

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


| | |
|---|---|
| ស្រាវជ្រាវដោយ | ណែនាំដោយ |
| និស្សិតឈ្មោះ លោក **ហៃ លីហួរ** | លោក **យ៉ុង និល** |
| លោក **អុល ផានុ** | |


| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | | ឆ្នាំចូលសិក្សា | ២០២០ |
| ជំនាន់ទី២៤ | | ឆ្នាំសរសេរសារណា | ២០២៤ |

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ហៃ លីហួរ** និងខ្ញុំបាទឈ្មោះ **អុល ផាន់** ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២៤ ឆ្នាំសិក្សា២០២០-២០២៤។

ខ្ញុំបាទ សូមគោរពសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះអ្នកមានគុណទាំងទ្វេ មានលោកឪពុក និងអ្នកម្តាយ ដែលបានផ្តល់កំណើត ផ្គត់ផ្គង់ចិញ្ចឹមបីបាច់ថែរក្សា និងប្រៀនប្រដៅតម្រង់ផ្លូវតាំងពីតូចរហូតដល់ចម្រើនវ័យប្រកបដោយក្តីស្រឡាញ់ ភាពកក់ក្តៅ សុភមង្គល។ ដូចគ្នានេះ លោកបានអនុញ្ញាតឱ្យកូនទទួលបានការអប់រំពេញលេញ ទាំងផ្នែកចំណេះដឹង សីលធម៌ សុជីវធម៌ និងគុណធម៌ ដោយការចិញ្ចឹម និងឧបត្ថម្ភដល់កូនឱ្យទទួលបានការសិក្សាតាំងពីថ្នាក់បឋមសិក្សា មធ្យមសិក្សា រហូតដល់ឧត្តមសិក្សាថ្នាក់បរិញ្ញាបត្រនេះ។ ជាមួយគ្នានេះ លោកបានអប់រំទូន្មានប្រៀនប្រដៅល្អៗ ដើម្បីឱ្យកូនក្លាយខ្លួនជាមនុស្សដែលមានចំណេះដឹងមានទម្លាប់ល្អៗក្នុងគ្រួសារ និងសង្គមជាតិ។

សូមគោរពថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** ដែលបានដឹកនាំ អភិវឌ្ឍវិស័យអប់រំ និងលើកកម្ពស់ការសិក្សាគ្រប់ជាន់ថ្នាក់យ៉ាងមានប្រសិទ្ធិភាព។

សូមគោរពថ្លែងអំណរគុណចំពោះ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ** នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ ដែលបានបង្ហាត់បង្រៀន ដឹកនាំ និងផ្តល់ចំណេះដឹងលើផ្នែកនីតិសាស្ត្រនាថ្នាក់បរិញ្ញាបត្ររយៈពេលបួនឆ្នាំកន្លងមកនេះ។ ជាមួយគ្នានេះ ខ្ញុំបាទទាំងពីររូបសូមគោរពថ្លែងអំណរគុណចំពោះលោកនាយក លោកស្រីនាយិកា លោកគ្រូអ្នកគ្រូ នាថ្នាក់បឋមសិក្សា រហូតដល់មធ្យមសិក្សា ដែលបានបង្ហាត់បង្រៀនដល់សិស្សនូវពុទ្ធិ និងចំណេះដឹងសព្វសារពើ រួមទាំងវិន័យ សីលធម៌ សុជីវធម៌ ក្នុងសង្គមផងដែរ គឺលោកគ្រប់រូបបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សជាតិ។

សូមថ្លែងអំណរគុណចំពោះ **លោកគ្រូ យ៉ុង និល** ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំដំណើរការនៃការស្រាវជ្រាវលើប្រធានបទមួយនេះ និងកែតម្រូវរាល់ចំណុចខ្វះខាត ទាំងគម្រោងតែងសរសេរ ទាំងខ្លឹមសារ ធ្វើយ៉ាងណាដើម្បីឱ្យស្នាដៃស្រាវជ្រាវមួយនេះមានលទ្ធផលល្អប្រសើរ។

ជាចុងក្រោយក៏សូមថ្លែងអំណរគុណដល់លោកអ្នកមានគុណគ្រប់រូបដែលបានរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្សលើវិស័យអប់រំ និងជាផ្នែកមួយដ៏សំខាន់ប្រទេសជាតិយើងឱ្យមានភាពរីកចម្រើនរុងរឿងថ្កុំថ្កើងតទៅ  និងសូមប្រសិទ្ធិពរជ័យដល់វត្ថុស័ក្តសិទ្ធិក្នុងលោកសូមជួយថែរក្សា ដល់លោកជួបតែពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ចាប់តាំងពីកម្ពុជាមានការបង្រួមបង្រួមជាតិដោយមាន ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រលើកដំបូងនៅឆ្នាំ១៩៩៣ ដែលត្រូវបានជួយគាំទ្រដោយអង្គការសហប្រជាជាតិ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាទី២ក៏បានប្រតិស្ថានឡើង និងបានប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ ចាប់ពីពេលនោះមក កម្ពុជាបានចងក្រងប្រព័ន្ធច្បាប់ឡើងវិញបន្តិចម្តងៗ ក្នុងនោះក៏មាននីតិរដ្ឋប្បវេណី និងនីតិព្រហ្មទណ្ឌ ជាអាទិ៍។

ដោយការយល់ឃើញ និងឱ្យតម្លៃលើការសិក្សាស្រាវជ្រាវ យើងខ្ញុំពិតជាមានសេចក្តីសោមនស្សដែលបានបញ្ចប់ការសិក្សាបរិញ្ញាបត្រពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដោយជ្រើសរើសការសរសេរសារណាបញ្ចប់ការសិក្សាលើមុខវិជ្ជានីតិវិធីរដ្ឋប្បវេណី។

ក្រមនីតិវិធីរដ្ឋប្បវេណី ជាការរៀបរាប់ពីដំណើរការដោះស្រាយវិវាទប្បវេណីក្នុងប្រទេសកម្ពុជាយើងបច្ចុប្បន្ន ដែលបានប្រកាសឱ្យប្រើកាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។ នីតិវិធីរដ្ឋប្បវេណី ជាមុខវិជ្ជាមួយដែលអនុញ្ញាតដល់និស្សិតបរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤បានសិក្សា។ ក្រោយពីឆ្លងកាត់ការសម្រេចជារួមក្នុងក្រុមរួចមក យើងខ្ញុំបានជ្រើសរើសយកប្រធានបទស្តីពី "**នីតិវិធីដាស់តឿន**" ជានីតិវិធីមួយដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា មកធ្វើការសិក្សាស្រាវជ្រាវឱ្យកាន់តែស៊ីជម្រៅ។

ដើម្បីបានលេចចេញជាស្នាដៃមួយនេះឡើង យើងខ្ញុំបានចំណាយទាំងកម្លាំងកាយ កម្លាំងចិត្តពេលវេលារួមទាំងថវិកាផ្ទាល់ខ្លួន លើការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ។ នីតិវិធីដាស់តឿនជានីតិវិធីដែលស្ទើរតែមិនធ្លាប់មាននោះទេក្នុងការអនុវត្តផ្ទាល់ ហើយក្នុងទ្រឹស្តីទៀតសោត ក៏ពុំត្រូវបានគេលើកយកមកសិក្សាទូលំទូលាយដែរ ទើបធ្វើឱ្យលេចជាឧបសគ្គខ្លះៗក្នុងការសិក្សាចងក្រងជាឯកសារស្រាវជ្រាវនេះឡើង។

ប៉ុន្តែមិនថ្វី ស្នាដៃសៀវភៅនេះនឹងរៀបរាប់អំពីសញ្ញាណទូទៅ សារៈសំខាន់ និងការប្រព្រឹត្តទៅនៃនីតិវិធីដាស់តឿន។ ក្រោយអានចប់ យើងសង្ឃឹមថា អ្នកអាននឹងបានយល់អំពីនីតិវិធីនេះ ព្រមទាំងអាចដំណើរការនីតិវិធីនេះបានផងដែរ ព្រោះពាក្យពេចន៍ដែលប្រើនៅទីនេះគឺត្រូវបានពន្យល់ងាយយល់តាមតែអាចធ្វើទៅបាន និងតាមលក្ខណៈតក្ក ងាយស្រួលដល់អ្នកអាន ស្វែងយល់លើប្រធានបទនេះឱ្យកាន់តែច្បាស់លាស់។

ទោះជាយ៉ាងណាក៏ដោយ ចំណុចខ្វះខាតនៅតែមានទៅលើខ្លឹមសារ វិធីសាស្ត្រសរសេរ អក្ខរាវិរុទ្ធ ជាអាទិ៍ ទោះបីយើងខ្ញុំបានផ្ចិតផ្ចង់ សម្រិតសម្រាំងក្នុងការចងក្រងស្នាដៃនេះឡើងមកក៏ដោយ។ ជាមួយគ្នានេះ យើងខ្ញុំរង់ចាំជានិច្ចនូវមតិកែសម្រួលក្នុងការស្ថាបនា ពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សនិស្សិតគ្រប់ជំនាន់ ដើម្បីអភិវឌ្ឍស្នាដៃមួយនេះឱ្យកាន់តែមានភាពប្រត្យក្រ។

ជាចុងក្រោយ សូមថ្លែងអំណរអរព្រះគុណដល់ព្រះសង្ឃ និងសូមអរគុណដល់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សនិស្សិត និងអ្នកអានគ្រប់រូប និងសូមប្រគេនពរ ជូនពរដោយជួបតែសេចក្តីសុខចម្រើនតរៀងទៅ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ..... ១

## ជំពូកទី១

## សញ្ញាណទូទៅ និងលក្ខខណ្ឌនៃនីតិវិធីដាស់តឿន

**១.១. សញ្ញាណទូទៅនៃនីតិវិធីដាស់តឿន** ..... ៤

១.១.១. នីតិវិធីនៃបណ្តឹងពិសេស ..... ៥

១.១.២. ការអនុវត្តដូចគ្នាទាក់ទងនឹងបញ្ញត្តិស្តីពីបណ្តឹង ..... ៦

១.១.៣. ក្របខណ្ឌក្នុងការអនុវត្តនីតិវិធីដាស់តឿន ..... ៦

១.១.៤. តុលាការមានសមត្ថកិច្ច ..... ៧

១.១.៤.១. សមត្ថកិច្ចតាមលំនៅឋានរបស់កូនបំណុល ..... ៨

១.១.៤.២. សមត្ថកិច្ចតាមកន្លែងអនុវត្តកាតព្វកិច្ច ..... ៩

១.១.៤.៣. ភាពផ្តាច់មុខនៃសមត្ថកិច្ចតុលាការ ..... ១០

**១.២. លក្ខខណ្ឌនៃការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន** ..... ១០

១.២.១. ការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ..... ១០

១.២.១.១. ការសងជារូបិយវត្ថុក្នុងស្រុក រូបិយបណ្ណ ឬរូបិយាណត្តិ ..... ១០

១.២.១.២. ការសងជាមូលប្បទានបត្រ ..... ១១

១.២.១.៣. ការសងជាបណ្ណសងតាមបញ្ជា ..... ១៣

១.២.២. ការបញ្ជូនដីកាសម្រេចដាស់តឿន ..... ១៤

១.២.២.១. អត្ថន័យនៃការបញ្ជូន ..... ១៥

១.២.២.២. វិធីបញ្ជូនដែលធ្វើបានក្នុងនីតិវិធីដាស់តឿន ..... ១៥

ក. ការបញ្ជូនដោយការប្រគល់ ..... ១៥

ខ. ការបញ្ជូននៅកន្លែងជួបប្រទះ ..... ១៦

គ. ការបញ្ជូនបង្គ្រប់កិច្ច ..... ១៦

ឃ. ការបញ្ជូនដោយទុកចោល ..... ១៧

១.២.២.៣. ស្ថាប័នដែលធ្វើការបញ្ជូន ..... ១៧

១.២.២.៤. ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្តឹង ..... ១៨

**ជំពូកទី២**

**ការជំនុំជម្រះ និងសម្រេចអំពីពាក្យសុំនៃនីតិវិធីដាស់តឿន**

**២.១. ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន** ..... ២០
២.១.១. ការពិនិត្យពាក្យសុំ ..... ២០
២.១.១.១. ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ ..... ២១
ក. លក្ខខណ្ឌទម្រង់តាមមាត្រា៧៥ ..... ២១
ខ. ការបង់ពន្ធដាក់ពាក្យសុំ ..... ២៣
២.១.១.២. សមត្ថភាពភាគី និងអ្នកតំណាងតាមផ្លូវបណ្តឹង ..... ២៥
ក. សមត្ថភាពភាគី ..... ២៦
ខ. អ្នកតំណាងតាមផ្លូវបណ្តឹង ..... ២៩
២.១.១.៣. ការបង្គាប់ឱ្យកែតម្រូវ ..... ៣៣
២.១.២. ដីកាសម្រេចលើពាក្យសុំ ..... ៣៣
២.១.២.១. ដីកាសម្រេចលើកចោល ..... ៣៤
២.១.២.២. ដីកាសម្រេចដាស់តឿន ..... ៣៤
ក. ខ្លឹមសារដីកាសម្រេចដាស់តឿន ..... ៣៥
ខ. ការបញ្ជូនដីកាសម្រេចដាស់តឿនទៅកូនបំណុល ..... ៣៥
គ. អានុភាពដីកាសម្រេចដាស់តឿន ..... ៣៦
**២.២.ពាក្យសុំតវ៉ាលើដីកាសម្រេចដាស់តឿន មុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន** ៣៦
២.២.១. អានុភាពដីកាសម្រេចដាស់តឿនក្នុងករណីគ្មានពាក្យសុំតវ៉ា ..... ៣៧
២.២.២. អានុភាពដីកាសម្រេចដាស់តឿនក្នុងករណីមានពាក្យសុំតវ៉ា ..... ៣៧
២.២.២.១. ពាក្យសុំតវ៉ាស្របច្បាប់ ..... ៣៧
២.២.២.២. ពាក្យសុំតវ៉ាមិនស្របច្បាប់ ..... ៣៨
ក. បណ្តឹងជំទាស់ស្របច្បាប់ ..... ៣៩
ខ. បណ្តឹងជំទាស់មិនស្របច្បាប់ ..... ៣៩
**២.៣. ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន** ..... ៤០
**២.៤. ពាក្យសុំតវ៉ា ក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន** ..... ៤១

២.៤.១. អានុភាពដីកាសម្រេចដាស់តឿនក្នុងករណីគ្មានពាក្យសុំតវ៉ា ........................................ ៤១
២.៤.២. អានុភាពដីកាសម្រេចដាស់តឿនក្នុងករណីមានពាក្យសុំតវ៉ា ........................................ ៤១
២.៤.២.១. ពាក្យសុំតវ៉ាស្របច្បាប់ ........................................ ៤២
២.៤.២.២. ពាក្យសុំតវ៉ាមិនស្របច្បាប់ ........................................ ៤៣
ក. បណ្ដឹងជំទាស់មិនស្របច្បាប់ ........................................ ៤៣
ខ. បណ្ដឹងជំទាស់ស្របច្បាប់ ........................................ ៤៤

## ជំពូកទី៣

## ការអនុវត្តដីកាសម្រេចដាស់តឿន

**៣.១. អានុភាពនៃការអនុវត្ត** ........................................ ៤៥
៣.១.១. ពាក្យសុំអនុវត្ត ........................................ ៤៦
៣.១.២. រូបមន្តអនុវត្ត ........................................ ៤៧
៣.១.៣. លិខិតអនុវត្ត ........................................ ៤៨
**៣.២. ស្ថាប័នអនុវត្ត** ........................................ ៥១
៣.២.១. តុលាការអនុវត្ត ........................................ ៥១
៣.២.២. អាជ្ញាសាលា ........................................ ៥២
**៣.៣. គុណប្រយោជន៍នៃបញ្ញត្តិស្ដីពីនីតិវិធីដាស់តឿន** ........................................ ៥៦
**សេចក្ដីសន្និដ្ឋាន** ........................................ ៥៧
**អនុសាសន៍** ........................................ ៦០
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាជារដ្ឋដែលធ្លាប់មានអារ្យធម៌ ឧត្តុងឧត្តម ធំទូលាយថ្កុំថ្កើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ប៉ុន្តែបានធ្លាក់ខ្លួនដ៏សែនវេទនា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនាឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ក្រោយពីកម្ពុជាបានចុះហត្ថលេខាលើសន្ធិសញ្ញាក្រុងប៉ារីសមក កម្ពុជាបានក្រោកឈរឡើង ពង្រឹងឯកភាពជាតិ រក្សាទឹកដី សន្តិភាព និងអធិបតេយ្យ ដោយគោរពតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ដើម្បីការអភិវឌ្ឍជាតិ ឱ្យមានភាពរីកចម្រើនលូតលាស់ទៅមុខ។ ព្រះរាជាណាចក្រកម្ពុជា ក៏សម្រេចបានរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ជាតិ ដែលត្រូវបានសភាធម្មនុញ្ញអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ហើយត្រូវបានព្រះមហាក្សត្រ ឡាយព្រះហស្ថលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា អ្វីឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗមិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ដែលសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់។

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ គ្របដណ្តប់លើជីវភាព និងជីវិតបុគ្គលឯកជន។ ក្រមរដ្ឋប្បវេណី បញ្ញត្តអំពីគោលការណ៍ទូទៅដែលទាក់ទងនឹងទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី ដែលក្នុងនោះមាន ទំនាក់ទំនងទ្រព្យសម្បត្តិ និងទំនាក់ទំនងញាតិផងដែរ។ ក្រមរដ្ឋប្បវេណីមានមុខងារពីរគឺ បទដ្ឋានសម្រាប់ធ្វើការសម្រេចសេចក្តី និងបទដ្ឋានសម្រាប់ធ្វើសកម្មភាព។ បទដ្ឋានសម្រាប់ធ្វើការសម្រេចសេចក្តី ជាបទដ្ឋានសម្រាប់ចេញសាលក្រម គឺការសម្រេចតាមបញ្ញត្តិដែលក្រមរដ្ឋប្បវេណីបានចែង។ ចំណែកបទដ្ឋានសម្រាប់ធ្វើសកម្មភាព មានសិទ្ធិទាមទារបញ្ជាក់ពេលមានវិវាទជាដើម ដូចករណីដែលភាគីអាចនឹងដឹងថា សេចក្តីសម្រេចនោះត្រូវបានធ្វើឡើងដោយផ្អែកទៅតាមក្រមរដ្ឋប្បវេណី ដើម្បីឱ្យតុលាការចេញសាលក្រម ដូច្នេះ ភាគីអាចអនុវត្តតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ព្រោះថាភាគីធ្វើសកម្មភាពស្របតាមក្រមរដ្ឋប្បវេណីកាន់តែច្រើន ភាគីនោះនឹងទំនងជាទទួលបានផលប្រយោជន៍កាន់តែច្រើនពីក្រមនោះ។ ដូចនេះ ក្រមរដ្ឋប្បវេណីផ្តល់ឱ្យភាគីនូវបទដ្ឋានសម្រាប់ធ្វើសកម្មភាព។

ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានប្រកាសឱ្យប្រើកាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។ ក្រមនេះ ចែងអំពីវិធានដែលត្រូវធ្វើសកម្មភាពបណ្តឹង ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកនឹងក្រមរដ្ឋប្បវេណី ដើម្បីធានាការដោះស្រាយរឿងក្តីមួយទទួលបានលទ្ធផលជាវិជ្ជមានចំពោះភាគីនៃបណ្តឹង និងការចូលរួមអនុវត្តឱ្យអស់ពីលទ្ធភាពពីសំណាក់អ្នកអនុវត្តច្បាប់ផងដែរ។ ក្រមរដ្ឋប្បវេណីអាចហៅបានថា ច្បាប់សារធាតុ រីឯក្រមនីតិវិធីរដ្ឋប្បវេណី អាចហៅថា ច្បាប់នីតិវិធី។

ក្នុងច្បាប់នីតិវិធីនេះ យើងសង្កេតឃើញមានបញ្ញត្តិទោលមួយដែលចែងអំពីនីតិវិធីដាស់តឿន។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តុលាការមានអំណាចឯករាជ្យ ដែលជានារក្សាអនាគត និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ។ ការកាត់ក្តីផ្តល់យុត្តិធម៌ ត្រូវគោរពតាមច្បាប់ជាធរមាន។ នីតិវិធីដាស់តឿន គឺជានីតិវិធីមួយដែលម្ចាស់បំណុលស្នើសុំទៅតុលាការដើម្បីចេញលិខិតអនុវត្តលើកូនបំណុល ក្នុងគោលបំណងឱ្យសងជាប្រាក់។ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង នីតិវិធីមួយនេះហាក់មិនត្រូវបានយកមកអនុវត្តឱ្យបានទូលំទូលាយឡើយ។

ដូចនេះ តើអ្វីដែលជាបញ្ហាដែលធ្វើឱ្យនីតិវិធីនេះមិនមានការអនុវត្តបានទូលំទូលាយ? តើនីតិវិធីដាស់តឿនត្រូវមានលក្ខខណ្ឌអ្វីខ្លះ? តើនីតិវិធីដាស់តឿនប្រព្រឹត្តទៅបានយ៉ាងដូចម្តេចខ្លះ? តើនីតិវិធីដាស់តឿននាំមកនូវគុណប្រយោជន៍ និងគុណវិបត្តិអ្វីខ្លះដល់ភាគីនៃរឿងក្តី?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនីតិវិធីដាស់តឿននេះ គឺក្នុងគោលបំណងដើម្បីផ្តល់ជាចំណេះដឹងដល់អ្នកអានអំពីដំណើរប្រព្រឹត្តទៅអំពីនីតិវិធីដាស់តឿន ចាប់ផ្តើមពីលក្ខខណ្ឌក្នុងការស្នើទៅតុលាការ នីតិវិធីដែលមានចែងក្នុងក្រមនីតិវិធី និងគុណសម្បត្តិគុណវិបត្តិ នៃនីតិវិធីដាស់តឿននេះ។ ជាមួយគ្នានេះដែរ យើងខ្ញុំសង្ឃឹមថានឹងមានការអនុវត្តទូលំទូលាយ ព្រោះវាជាបញ្ញត្តិមួយដែលផ្តល់ភាពងាយស្រួលដល់ការអនុវត្តការដែលកូនបំណុលមិនព្រមសងប្រាក់។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទាក់ទងនឹងប្រធានបទនេះ គឺផ្អែកទៅលើក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ ជាមូលដ្ឋានចម្បង ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា គួបផ្សំជាមួយនឹងឯកសារច្បាប់ដែលពាក់ព័ន្ធនឹងនីតិវិធីដាស់តឿនផងដែរ។ ក្រៅពីឯកសារទាំងនេះ យើងខ្ញុំបានប្រើប្រាស់នូវចំណេះដឹងផ្ទាល់ខ្លួន និងចំណេះដឹងដែលបានមកពីការណែនាំរបស់សាស្ត្រាចារ្យ ព្រមទាំងទស្សនៈដែលយើងខ្ញុំមាន យកមកបញ្ចូលគ្នា ដើម្បីចងក្រងបានជាខ្លឹមសារក្នុងអត្ថបទស្រាវជ្រាវមួយនេះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី នីតិវិធីដាស់តឿន បានផ្តល់នូវឧត្តមប្រយោជន៍យ៉ាងច្រើនសម្រាប់សិស្សនិស្សិត ព្រមទាំងប្រជាពលរដ្ឋទូទៅ ឱ្យបានយល់ដឹងបន្ថែមកាន់តែច្បាស់ពីការអនុវត្តនីតិវិធីដាស់តឿននៅប្រទេសកម្ពុជា។ លើសពីនេះ ក៏បានពង្រីកនូវចំណេះដឹងឱ្យកាន់តែទូលំទូលាយ ពោលគឺជាចំណេះដឹងថ្មីមួយសម្រាប់សិស្សនិស្សិត និងអ្នកសិក្សាទាំងឡាយបង្កើននូវទស្សនៈវិស័យវែងឆ្ងាយផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ស្នាដៃស្រាវជ្រាវមួយនេះ គឺកកើតក្រោមការរៀបចំចងក្រងលើឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធ ព្រមទាំងក្រោមការគិតគូរវិភាគចេញពីឯកសារទាំងនេះ។ វិធីសាស្ត្រក្នុងការសរសេរអត្ថបទស្រាវជ្រាវនេះ គឺមានការផ្តល់ប្រភពឯកសារច្បាស់លាស់ និងប្រកបដោយលក្ខណៈវិទ្យាសាស្ត្រមានគុណភាពអាចជឿជាក់បាន។ ប៉ុន្តែកំហុសដោយអចេតនាដែលតែងកើតមាន ដែលយើងខ្ញុំនឹងធ្វើការកែសម្រួលឱ្យអស់ពីសមត្ថភាពតាមតែអាចធ្វើទៅបាន។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទស្តីពី នីតិវិធីនៃការដាស់តឿន ត្រូវបានបែងចែកជាបីជំពូកសំខាន់ៗរួមមាន៖ សញ្ញាណទូទៅ និងលក្ខខណ្ឌនៃនីតិវិធីដាស់តឿន(ជំពូកទី១) អំពី ការជំនុំជម្រះ និងសម្រេចអំពីពាក្យសុំនៃនីតិវិធីដាស់តឿន(ជំពូកទី២) និងការអនុវត្តដីកាសម្រេចដាស់តឿន(ជំពូកទី៣)។

# ជំពូកទី១

# សញ្ញាណទូទៅ និង

# លក្ខខណ្ឌនៃ

# នីតិវិធីដាស់តឿន

# ជំពូកទី១

# សញ្ញាណទូទៅ និងលក្ខខណ្ឌនៃនីតិវិធីដាស់តឿន

ក្នុងរឿងក្ដីរដ្ឋប្បវេណី បានចែកបណ្ដឹងជាបី គឺបណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក បណ្ដឹងទាមទារឱ្យបញ្ជាក់ និងបណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត ដែលត្រូវឆ្លងកាត់តាមនីតិវិធីបណ្ដឹងធម្មតាទៅតាមដំណាក់កាលនីមួយៗរហូតដល់ទទួលបានសាលក្រមស្ថាពរស្រមតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងនោះបណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក ដែលមានគោលបំណងច្បាស់លាស់ទាមទារឱ្យសងជាប្រាក់ ម្ចាស់បំណុលអាចជ្រើសរើសយកនីតិវិធីដាស់តឿនបាន ដើម្បីឱ្យតុលាការចេញលិខិតអនុវត្តមកខ្លួនបានដោយមិនចាំបាច់សួរពីកូនបំណុលឡើយ។[1]

ជាជំហានដំបូងក្នុងការស្វែងយល់អំពីនីតិវិធីដាស់តឿនដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី យើងត្រូវសិក្សាពី សញ្ញាណទូទៅនៃនីតិវិធីដាស់តឿន(១.១) និងលក្ខខណ្ឌនៃការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន(១.២) ជាមុនសិន។

## ១.១. សញ្ញាណទូទៅនៃនីតិវិធីដាស់តឿន

នីតិវិធីដាស់តឿន គឺជានីតិវិធីមួយដែលម្ចាស់បំណុលស្នើសុំទៅតុលាការដើម្បីចេញលិខិតអនុវត្តលើកូនបំណុល ចំពោះការទាមទារឱ្យកូនបំណុលបំពេញកាតព្វកិច្ចដែលមានចំពោះខ្លួនក្នុងគោលបំណងឱ្យសងជាប្រាក់។[2] លិខិតអនុវត្តនៅទីនេះ សំដៅដល់ ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន។[3] នីតិវិធីដាស់តឿននេះ មិនត្រូវបានឆ្លងកាត់ដូចនីតិវិធីជំនុំជម្រះលើកទីមួយទេ ដែលធ្វើឱ្យនីតិវិធីនេះ មានលក្ខណៈងាយស្រួល និងឆាប់រហ័សជាងនីតិវិធីបណ្ដឹងធម្មតា។[4] ឆាប់រហ័សក្នុងន័យនេះ ផ្សាភ្ជាប់នឹងភាពយុត្តិធម៌ ព្រោះយុត្តិធម៌យឺតយ៉ាវគឺ អយុត្តិធម៌។[5]

ពាក្យសុំទៅតុលាការដើម្បីបញ្ជាក់ថាខ្លួនមានអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិក្នុងការទាមទារពីកូនបំណុលឡើយ។ ប៉ុន្តែនៅពេលដែលកូនបំណុលមានវិវាទ តតាំងចំពោះអត្ថិភាពនៃសិទ្ធិនោះ ភាគីនឹងមានឱកាសធ្វើ

[1] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៣។

[2] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្ដឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៤១។

[3] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៥០ កថាខណ្ឌទី២។

[4] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៥២។

[5] អ៊ីវ ប៉ូលី, *មេរៀនសង្ខេបស្ដីពីនីតិវិធីរដ្ឋប្បវេណី,* (ភ្នំពេញ, ២០១០), ១១៦។

បណ្តឹងតាមនីតិវិធីបណ្តឹងធម្មតា។[6]

ចំពោះការទាមទារក្នុងនីតិវិធីដាស់តឿន អាចស្នើសុំទាមទារទាំងស្រុង ឬដោយផ្នែកបាន។ ជាមួយគ្នានេះ តុលាការរដ្ឋប្បវេណី ជាតុលាការអកម្ម ដែលធ្វើការសម្រេចសេចក្តីលើការទាមទាររបស់ភាគីតែប៉ុណ្ណោះ។ ដូចនេះ តុលាការអាចសម្រេចចេញដីកាដាស់តឿន ឬដីកាលើកចោលទាំងស្រុង ឬមួយផ្នែកតាមការទាមទាររបស់ម្ចាស់បំណុលបាន។ ដោយសារតែនីតិវិធីដាស់តឿន ជានីតិវិធីពិសេស ដែលមិនមានទម្រង់សាកសួរភាគីឡើយ ដូចនេះមិនមានពាក្យ "ដើមចោទ" ឬ "ចុងចម្លើយ" ចំពោះភាគីនៃនីតិវិធីដាស់តឿនទេ។[7] ក្នុងនីតិវិធីដាស់តឿន អ្នកដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ត្រូវបានហៅថា "ម្ចាស់បំណុល" រីឯភាគីម្ខាងទៀតហៅថា "កូនបំណុល"។[8]

នីតិវិធីដាស់តឿន ជានីតិវិធីបណ្តឹងពិសេស(១.១.១) ដែលមានការអនុវត្តដូចគ្នាទាក់ទងនឹងបញ្ញត្តិស្តីពីបណ្តឹង (១.១.២) ហើយអនុវត្តលើក្របខណ្ឌនៃវិវាទតាមបញ្ញត្តិច្បាប់(១.១.៣) និងដាក់ទៅតុលាការដែលមានសមត្ថកិច្ច(១.១.៤) ដើម្បីឱ្យពាក្យសុំមានសុពលភាព។

### ១.១.១. នីតិវិធីនៃបណ្តឹងពិសេស

ជាទូទៅ ប្រភេទនៃបណ្តឹងត្រូវបានបែងចែកជាបីមាន៖ បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក[9] បណ្តឹងទាមទារឱ្យបញ្ជាក់ និងបណ្តឹងបង្កើត កែប្រែ និងរំលត់ទំនាក់ទំនងគតិយុត្ត។ ដើម្បីសម្រេចសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកតាមរយៈការអនុវត្តដោយបង្ខំ គឺម្ចាស់បំណុលត្រូវដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីទទួលបានសាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិក។[10] ប៉ុន្តែ នីតិវិធីដាស់តឿន មិនមែនជានីតិវិធីបណ្តឹងធម្មតាទេ តែជានីតិវិធីបណ្តឹងពិសេស ដែលម្ចាស់បំណុលអាចទទួលបាននូវលិខិតអនុវត្ត មានអានុភាពដូចសាលក្រម ឬសាលដីកាដែរ តាមរយៈវិធីសាមញ្ញ ឆាប់រហ័ស និងអស់សោហ៊ុយតិច។

---

[6] អ៊ីវ ប៉ូលី, *មេរៀនសង្ខេបស្តីពីនីតិវិធីរដ្ឋប្បវេណី*, (ភ្នំពេញ, ២០១០), ១១៦។

[7] ហ៊ី សោភា, *នីតិវិធីរដ្ឋប្បវេណី*, (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច), ១១០។

[8] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង*, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៤១។

[9] គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, *សន្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពីសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី*, (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ៥០, វត្ថុ ឬសកម្មភាពដែលជាទីតាំង ឬជាកម្មវត្ថុនៃកាតព្វកិច្ច។

[10] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង*, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៤១។

ដូចនេះ ម្ចាស់បំណុលអាចស្នើទៅតុលាការឱ្យចេញដីកាសម្រេចដាស់តឿនឱ្យសងបាន កាលណាកូនបំណុលប្រកែកមិនព្រមអនុវត្តកាតព្វកិច្ចផ្តល់តាវកាលិកដោយស្ម័គ្រចិត្ត ដោយមិនបានធ្វើវិវាទអំពីអត្ថិភាពនៃសិទ្ធិទាមទាររបស់ម្ចាស់បំណុលទេ។ ប៉ុន្តែ ប្រសិនបើកូនបំណុលមានបំណងធ្វើវិវាទទៅនឹងការទាមទាររបស់ម្ចាស់បំណុល កូនបំណុលអាចដាក់ពាក្យសុំតវ៉ា ព្រោះកូនបំណុលត្រូវបានធានាឱ្យមានឱកាសទទួលនូវការវិនិច្ឆ័យតាមនីតិវិធីបណ្តឹងធម្មតា។[11]

### ១.១.២. ការអនុវត្តដូចគ្នាទាក់ទងនឹងបញ្ញត្តិស្តីពីបណ្តឹង

ជាគោលការណ៍ បញ្ញត្តិស្តីពីបណ្តឹង[12] ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន លុះត្រាតែគ្មានភាពផ្ទុយនឹងលក្ខណៈរបស់ពាក្យសុំនោះ។[13] ដូចនេះ ពាក្យសុំត្រូវមានទម្រង់ដូចគ្នានឹងមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ទើបអាចអនុវត្តបញ្ញត្តិស្តីពីបណ្តឹងបាន។ ទោះបីជាបញ្ញត្តិច្បាប់មិនបានចែងថា ការសរសេរពាក្យសុំឱ្យស្របតាមមាត្រា៧៥នេះ ជាលក្ខខណ្ឌនៃនីតិវិធីដាស់តឿនដូចមានចែងក្នុងមាត្រា៣១៩ក៏ដោយ[14] ប៉ុន្តែបើកាលណាពាក្យសុំមិនបានសរសេរនូវអ្វីដែលច្បាប់តម្រូវដូចមាត្រា៧៥ទេ នោះតុលាការនឹងលើកចោលពាក្យសុំនោះ។[15]

### ១.១.៣. ក្របខណ្ឌក្នុងការអនុវត្តនីតិវិធីដាស់តឿន

ក្នុងនីតិវិធីដាស់តឿន ម្ចាស់បំណុលអាចស្នើសុំតុលាការឱ្យចេញដីកាសម្រេចដាស់តឿនបាន ចំពោះគោលបំណងឱ្យសងជាប្រាក់តែប៉ុណ្ណោះ ដែលជាការទាមទារនាពេលបច្ចុប្បន្ន ទើបតុលាការធ្វើការវិនិច្ឆ័យចេញដីកាសម្រេចបាន ទោះបីជាមានការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ក៏ដោយ ប៉ុន្តែការទាមទារឱ្យសងនាពេលអនាគត គឺមិនអាចស្នើសុំដីកាសម្រេចដាស់តឿនបានទេ។ ការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន អាចដាក់បានតែក្នុងករណីដែលសិទ្ធិរបស់ម្ចាស់បំណុលនោះ ជាសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ប៉ុណ្ណោះ ព្រោះនៅពេលដែលសិទ្ធិទាមទារនេះត្រូវបានអនុវត្តដោយបង្ខំ និងមានកំហុសដោយម្ចាស់បំណុលក៏ដោយ ក៏តាមធម្មតាអាចធ្វើបដិទាន[16]នូវការខូតខាតដែលកូនបំណុលបានទទួលនោះ

[11] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៤១។

[12] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, គន្ថីទី២, ជំពូកទី១។

[13] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២១។

[14] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១៩។

[15] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២២។

[16] គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, *សទ្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពីសទ្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី,* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ៨៣. ការស្តារឡើងវិញនូវស្ថានភាពដើម ឬ

ដោយការសងជាប្រាក់បាន។[17] ដើម្បីអាចដាក់ពាក្យសុំបាន លុះត្រាតែពេលវេលាកំណត់ដែលត្រូវអនុវត្តបានមកដល់ ហើយទោះបីជាសិទ្ធិទាមទារជាសិទ្ធិដែលត្រូវអនុវត្តដោយថ្នូរនឹងតាវកាលិកតប ក៏ដោយ ក៏អាចស្នើពាក្យសុំចេញដីកាសម្រេចដាស់តឿនបានដែរ។[18]

### ១.១.៤. តុលាការមានសមត្ថកិច្ច

តុលាការ ជាអ្នកដឹកនាំ និងដោះស្រាយវិវាទ នៅពេលមានបណ្តឹង។[19] សមត្ថកិច្ចមកពីពាក្យ “សមត្ថ” ផ្សំជាមួយនឹង “កិច្ច” ។ “សមត្ថ” មានន័យថា ដែលអាច ដែលហ៊ាន ដែលធ្វើកើត។[20] “កិច្ច” មានន័យថា ការដែលត្រូវធ្វើ។[21] ដូចនេះ សមត្ថកិច្ច ជាកិច្ចការដែលអាចធ្វើបាន បើតាមអត្ថន័យវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត។

តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការដែលអាចទទួលដោយស្របច្បាប់នៃពាក្យបណ្ដឹង វិនិច្ឆ័យលើរឿងក្តី ហើយចេញសាលក្រម ឬសាលដីកាបាន។[22] ប៉ុន្តែ “តុលាការមានសមត្ថកិច្ច” នៅទីនេះសំដៅដល់សាលាជម្រះដែលអាចទទួលពាក្យសុំដីកាសម្រេចដាស់តឿនបាន។ ជាមួយគ្នានេះ តុលាការ មានមុខងារវិនិច្ឆ័យ និងចេញសេចក្តីសម្រេចទៅលើបណ្ដឹង ហៅថា សិទ្ធិជម្រះក្តី។[23]

ដូចនេះ តុលាការដែលមានសមត្ថកិច្ចទទួលពាក្យសុំ ហើយពិនិត្យពាក្យសុំ និងចេញដីកាសម្រេច គឺជាសាលាដំបូងដែលមានសមត្ថកិច្ចលើតំបន់ ដែលត្រូវបានកំណត់ទៅ តាមលំនៅឋានរបស់កូនបំណុល(១.១.៤.១) និងសមត្ថកិច្ចតាមទីកន្លែងដែលអនុវត្តកាតព្វកិច្ច (១.១.៤.២) ដែលសុទ្ធសឹងជាសមត្ថកិច្ចផ្ដាច់មុខ(១.១.៤.៣)។

ការប្រគល់ត្រឡប់វិញ។ឧ. ការបង្វិលសងវត្ថុ ដែលកូនបំណុលបានប្រគល់ ឬសងប្រាក់ដែលកូនបំណុលបានបង់ ឬបង្វិលសងវត្ថុ ដែលម្ចាស់បំណុលកំពុងប្រើប្រាស់ ឬថែរក្សាគ្រប់គ្រង ទៅកូនបំណុលវិញ ឬការបង្វិលសងវិញ នូវទ្រព្យមរតកដែលអ្នកគ្មានសិទ្ធិខាងសន្តតិកម្មបានទទួលជាដើម។

[17] អ៊ីវ ប៉ូលី, *មេរៀនសង្ខេបស្តីពីនីតិវិធីរដ្ឋប្បវេណី*, (ភ្នំពេញ, ២០១០), ១១៧។

[18] អ៊ីវ ប៉ូលី, *មេរៀនសង្ខេបស្តីពីនីតិវិធីរដ្ឋប្បវេណី*, (ភ្នំពេញ, ២០១០), ១១៧។

[19] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧។

[20] ជួន ណាត. វចនានុក្រមខ្មែរ, ភ្នំពេញ៖ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧។

[21] ជួន ណាត. វចនានុក្រមខ្មែរ, ភ្នំពេញ៖ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧។

[22] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧។

[23] អ៊ីវ ប៉ូលី, *ក្រមនីតិវិធីរដ្ឋប្បវេណី,* “មេរៀនទី២អំពី សមត្ថកិច្ចសាលាជម្រះក្តី”, (ភ្នំពេញ៖ វគ្គបណ្តុះបណ្តាលវិភាគទានច្បាប់ជំនាន់ទី៧, ២០២៣), ៤។

### ១.១.៤.១. សមត្ថកិច្ចតាមលំនៅឋានរបស់កូនបំណុល

ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនចំពោះកូនបំណុល អាចជារូបវន្តបុគ្គល[24] ឬនីតិបុគ្គល[25] ដែលត្រូវកំណត់តាមលំនៅឋានរបស់រូបវន្តបុគ្គល ឬទីតាំងចំពោះនីតិបុគ្គល។[26] នីតិបុគ្គលនៅទីនេះសំដៅដល់នីតិបុគ្គលក្នុងប្រទេស និងនីតិបុគ្គលបរទេស។[27]

ចំពោះកូនបំណុលជារូបវន្តបុគ្គល ត្រូវកំណត់ទៅតាមទីតាំងលំនៅឋានរបស់រូបវន្តបុគ្គលនោះ ហើយប្រសិនបើពុំមានលំនៅឋាន ឬក៏មានលំនៅឋានមិនពិតប្រាកដក្នុងព្រះរាជាណាចក្រកម្ពុជាទេ ត្រូវកំណត់យកទីសំណាក់។[28] លំនៅឋាន ជាកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ។[29] ទីសំណាក់ ជាទីស្ថាន ដែលបុគ្គលម្នាក់អាស្រ័យនៅ ឬអាស្រ័យនៅជាក់ស្តែងក្នុងរយៈពេលជាកំណត់ណាមួយដែលមិនមែនជាលំនៅឋាន។[30] គោលការណ៍ទីសំណាក់នេះ ជាគោលការណ៍សារធាតុដែលទទួលស្គាល់លំនៅឋានដោយផ្អែកលើទំនាក់ទំនងជាក់ស្តែង។[31]

ចំពោះកូនបំណុលជានីតិបុគ្គលក្នុងប្រទេស ត្រូវបានកំណត់ទីតាំងទៅតាមទីស្នាក់ការកណ្តាល ឬទីកន្លែងអាជីវកម្មចម្បង ប្រសិនបើមិនមានទេ គឺកំណត់យកលំនៅឋានរបស់អ្នកតំណាង ឬអ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បង។[32]

---

[24] គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, *សន្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពីសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី*, (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ ១២៧. មនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល។

[25] គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, *សន្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពីសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី*, (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ ៧១. ក្រុមមនុស្ស ឬមូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច។

[26] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២០។

[27] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២០ កថាខណ្ឌទី១ ចំណុច ខ និងចំណុច គ។

[28] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២០ កថាខណ្ឌទី១ ចំណុច ក។

[29] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៤។

[30] គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, *សន្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពីសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី*, (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ ៥៤។

[31] ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី,* ភាគ១, គន្ថីទី១-ទី៩ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), ២៨។

[32] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២០ កថាខណ្ឌទី១ ចំណុច ខ។

ចំណែកឯកូនបំណុលជានីតិបុគ្គលបរទេស ត្រូវកំណត់យកទីតាំងនៃទីស្នាក់ការកណ្តាល[33] ឬទីកន្លែងអាជីវកម្មចម្បងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមិនមានទេ នោះត្រូវកំណត់យកទីតាំងនៃលំនៅឋានរបស់អ្នកតំណាងប្រចាំព្រះរាជាណាចក្រកម្ពុជា ឬអ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[34] សាលាដំបូងដែលមានសមត្ថកិច្ចលើទីតាំងទាំងនេះ ជាតុលាការដែលមានសមត្ថកិច្ចដែលម្ចាស់បំណុលអាចដាក់ពាក្យសុំបាន។[35]

### ១.១.៤.២. សមត្ថកិច្ចតាមកន្លែងអនុវត្តភាតព្វកិច្ច

ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន អាចធ្វើទៅសាលាដំបូងដែលមានសមត្ថកិច្ចលើតំបន់ នៃទីស្នាក់ការ ឬកន្លែងអាជីវកម្ម របស់កូនបំណុលចំពោះការទាមទារដែលទាក់ទងនឹងការងារនៃទីស្នាក់ការ ឬកន្លែងអាជីវកម្មនោះ។[36]

មួយវិញទៀត ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន អាចធ្វើទៅសាលាដំបូងដែលមានសមត្ថកិច្ចលើតំបន់នៃកន្លែងដែលត្រូវសងជារូបិយាណត្តិ មូលប្បទានប័ត្រ និងការទាមទារបន្ទាប់បន្សំដែលទាក់ទងនឹងវត្ថុទាំងនោះ ចំពោះការទាមទារឱ្យសងតាមវត្ថុទាំងនោះ។[37] វត្ថុទាំងនោះ សំដៅដល់ឧបករណ៍អាចជួញដូរបានដែលគ្រប់គ្រងដោយច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់[38] ក្នុងនោះរួមមាន មូលប្បទានប័ត្រ[39] រូបិយាណត្តិ[40] និងប័ណ្ណសងតាមបញ្ជា[41]។ ចំពោះការទាមទារបន្ទាប់បន្សំមានការទាមទារឱ្យសងការប្រាក់ ជាដើម។[42]

---

[33] គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, *សន្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពីសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី,* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ៥៥. ទីតាំង ដែលបញ្ជាក់ក្នុងលក្ខន្តិកៈរបស់នីតិបុគ្គល និងដែលត្រូវកំណត់ថាជាការិយាល័យចម្បងរបស់នីតិបុគ្គល។

[34] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២០ កថាខណ្ឌទី១ ចំណុច គ។

[35] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៤២។

[36] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២០ កថាខណ្ឌទី២ ចំណុច ក។

[37] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២០ កថាខណ្ឌទី២ ចំណុច ខ។

[38] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥។

[39] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, ជំពូកទី២។

[40] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, ជំពូកទី៣។

[41] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, ជំពូកទី៤។

[42] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៤២។

#### ១.១.៤.៣. ភាពផ្តាច់មុខនៃសមត្ថកិច្ចតុលាការ

សមត្ថកិច្ចតុលាការដែលមានភាពផ្តាច់មុខ ជាសមត្ថកិច្ចដែលកំណត់ដោយបញ្ញត្តិច្បាប់ ដែលមិនទទួលស្គាល់សមត្ថកិច្ចតុលាការផ្សេងទៀតឡើយ ព្រមទាំងមិនអនុញ្ញាតដល់ភាគី ក្នុងការផ្តល់សមត្ថកិច្ចទៅតុលាការណាមួយដោយឆន្ទៈខ្លួនឡើយ។[43] សមត្ថកិច្ចផ្តាច់មុខនេះ ត្រូវបានអនុវត្តសម្រាប់តែ ករណីសមត្ថកិច្ចតាមភារកិច្ច មានបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និងនីតិវិធីដាស់តឿនផងដែរ។[44]

## ១.២. លក្ខខណ្ឌនៃការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន

ដើម្បីអាចចេញដីកាសម្រេចដាស់តឿនបាន ត្រូវមានលក្ខខណ្ឌពីរសំខាន់ៗគឺ ការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់(១.២.១) និងការបញ្ជូនដីកាសម្រេចដាស់តឿន(១.២.២)។

### ១.២.១. ការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់

ការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ អាចលេចជារូបភាពក្រោមទម្រង់ ការសងជារូបិយវត្ថុក្នុងស្រុក រូបិយបណ្ណ ឬរូបិយាណត្តិ(១.២.១.១) ការសងជាមូលប្បទានបត្រ(១.២.១.២) និងការសងជាបណ្ណសងតាមបញ្ជា(១.២.១.៣)។

#### ១.២.១.១. ការសងជារូបិយវត្ថុក្នុងស្រុក រូបិយបណ្ណ ឬរូបិយាណត្តិ

ការទាមទារដែលមានគោលបំណងសងជាប្រាក់ អាចមើលឃើញតាមច្រើនរូបភាព រួមមាន រូបិយវត្ថុក្នុងស្រុក រូបិយាបណ្ណ និងរូបិយាណត្តិ។ រូបិយវត្ថុក្នុងស្រុក សំដៅដល់ប្រាក់រៀល(៛) ដែលជារូបិយវត្ថុផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជា។[45] រូបិយវត្ថុគឺសំដៅដល់ផលិតផលដ៏សំខាន់មួយនៅក្នុងសេដ្ឋកិច្ចទីផ្សារ ដើម្បីបង្កើតលក្ខណៈងាយស្រួលដល់ដំណើរការដោះដូរទំនិញ ឬសេវា។ គេអាចឱ្យនិយមន័យវាទៀតថា ជាវត្ថុមួយដែលត្រូវបានគេប្រើប្រាស់ជាមធ្យោបាយដើម្បីដោះដូរទំនិញ សេវាកម្ម និងទូទាត់នូវបំណុលផ្សេងៗ។ ការសងជារូបិយវត្ថុក្នុងស្រុងនេះ មានការប្រតិបត្តិរាល់ថ្ងៃដូចដែលយើងមើលឃើញជាក់ស្តែង ដែលមានការសងដូចជាការទូទាត់ជាប្រាក់រៀល។

រូបិយប័ណ្ណ សំដៅដល់រូបិយវត្ថុណាមួយ ក្រៅពីរូបិយវត្ថុក្នុងស្រុក។[46] រូបិយវត្ថុក្រៅពីរូបិយវត្ថុក្នុងស្រុក

---

[43] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៥។

[44] អ៊ីរ ប៉ូលី, *មេរៀនសង្ខេបស្តីពីនីតិវិធីរដ្ឋប្បវេណី*, (ភ្នំពេញ, ២០១០), ១៧។

[45] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, មាត្រា២ ចំណុចទី៣៩។

[46] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, មាត្រា២ កថាខណ្ឌទី៣៨។

សំដៅដល់រូបិយវត្ថុក្រៅពីប្រាក់រៀល។ ឧទាហរណ៍ ប្រាក់ដុល្លាជារូបិយវត្ថុរបស់សហរដ្ឋអាមេរិក($) បាតជារូបិយវត្ថុរបស់ប្រទេសថៃ(฿) ដុងជារូបិយវត្ថុរបស់ប្រទេសវៀតណាម(₫)។

ចំណែកឯ រូបិយាណត្តិវិញ គឺជាបញ្ជាជាលាយលក្ខណ៍អក្សរដោយឥតលក្ខខណ្ឌ ចេញដោយបុគ្គលមួយឱ្យទៅបុគ្គលដទៃ ចុះហត្ថលេខាដោយបុគ្គលដែលចេញបញ្ជា តម្រូវឱ្យបុគ្គលដែលជាអ្នកទទួលបញ្ជាទូទាត់សងចំនួនប្រាក់ជាកំណត់មួយឱ្យទៅ ឬតាមបញ្ជាបុគ្គលមួយទៀត ឬអ្នកកាន់។ រូបិយាណត្តិត្រូវតែបានទូទាត់សងប្រាក់នៅពេលដល់ឥណប្រតិទាន[47]ហើយស្របតាមរាល់កាតព្វកិច្ច។[48] រូបិយាណត្តិជាឧបករណ៍ឥណទានអាចត្រូវបានសរសេរជាអក្សរខ្មែរ ឬអក្សរបរទេស ហើយត្រូវតែមាននិទ្ទេសដូចជា បញ្ជាដោយឥតលក្ខខណ្ឌឱ្យទូទាត់សងនូវចំនួនប្រាក់ជាកំណត់មួយ ឈ្មោះរបស់បហារិតដែលជាបុគ្គលត្រូវទូទាត់សងប្រាក់ កន្លែងដែលត្រូវធ្វើការទូទាត់សងប្រាក់ រយៈពេលកំណត់ត្រូវទូទាត់សងប្រាក់ ឈ្មោះរបស់បុគ្គលដែលទទួលការទូទាត់សងប្រាក់ ឬឈ្មោះរបស់បុគ្គលដែលមានបញ្ជាឱ្យទូទាត់សងប្រាក់ចំពោះខ្លួន កាលបរិច្ឆេទ និងកន្លែងដែលរូបិយាណត្តិត្រូវបានចេញផ្សាយ និងហត្ថលេខារបស់បហារ៉កដែលចេញបញ្ជាលើរូបិយាណត្តិ។[49] អ្នកកាន់រូបិយាណត្តិ ដែលត្រូវទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ ឬនៅក្នុងពេលកំណត់មួយក្រោយកាលបរិច្ឆេទចេញផ្សាយ ឬក្រោយការបង្ហាញ ត្រូវបង្ហាញនៅថ្ងៃទូទាត់សងប្រាក់ ឬនៅថ្ងៃណាមួយរវាង២(ពីរ)ថ្ងៃបន្ទាប់។ បហារិតដែលទូទាត់សងរូបិយាណត្តិ អាចត្រូវឱ្យប្រគល់រូបិយាណត្តិនោះឱ្យខ្លួនក្រោយពីការបញ្ជាក់ការទទួលប្រាក់ពីអ្នកកាន់។ អ្នកកាន់អាចមិនបដិសេធការទូទាត់សងប្រាក់មួយផ្នែកនៃចំនួនប្រាក់រូបិយាណត្តិ។ នៅពេលដែលរូបិយាណត្តិមិនត្រូវបានបង្ហាញឱ្យទូទាត់សងប្រាក់ក្នុងរយៈពេលដែលកំណត់ កូនបំណុលត្រូវបានអនុញ្ញាតឱ្យតម្កល់ចំនួនទឹកប្រាក់នោះនៅអាជ្ញាធរមានសមត្ថកិច្ច តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជាក្រោមការទទួលខុសត្រូវ និងហានិភ័យរបស់អ្នកកាន់។[50]

### ១.២.១.២. ការសងជាមូលប្បទានបត្រ

និយមន័យនៃមូលប្បទានប័ត្រ សំដៅដល់ការចេញបញ្ជាជាលាយលក្ខណ៍អក្សរដែលឥតលក្ខខណ្ឌឱ្យទៅធនាគារ និងចុះហត្ថលេខាដោយបុគ្គលជាអ្នកចេញបញ្ជា តម្រូវឱ្យធនាគារទូទាត់សងចំនួនប្រាក់ជាកំណត់មួយឱ្យទៅ ឬតាមបញ្ជាបុគ្គលមួយទៀត ឬអ្នកកាន់។ មូលប្បទានប័ត្រត្រូវតែបានទូទាត់សងប្រាក់នៅពេល

---

[47] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, មាត្រា២ ចំណុចទី៥៣. ឥណប្រតិទាន សំដៅដល់កាលបរិច្ឆេទ ដែលរូបិយាណត្តិ ឬ បណ្ណសងតាមបញ្ជា ត្រូវកំណត់សង។

[48] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, មាត្រា៦០។

[49] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, មាត្រា៦១។

[50] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, មាត្រា១០០។

បង្ហាញ ហើយស្របតាមរាល់កាតព្វកិច្ច។[51] មូលប្បទានប័ត្រដែលមានសុពលភាពត្រូវតែមាននិទ្ទេសដូចជា អាចត្រូវបានសរសេរជាអក្សរខ្មែរ ឬជាអក្សរបរទេស ពាក្យថា មូលប្បទានប័ត្រ ដែលចារឹកជាភាសាណាមួយ ដែលប្រើក្នុងការចេញឧបករណ៍នេះ បញ្ជាដោយឥតលក្ខខណ្ឌឱ្យទូទាត់សងចំនួនប្រាក់ជាកំណត់មួយ ឈ្មោះរបស់បហារិត[52]ដែលជាធនាគារត្រូវទូទាត់សងប្រាក់ កាលបរិច្ឆេទ និងកន្លែងដែលមូលប្បទានប័ត្រត្រូវបានចេញ ហត្ថលេខារបស់បហារក[53] ដែលជាបុគ្គលចេញបញ្ជាលើមូលប្បទានប័ត្រ។[54] បើទោះបីជា ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ត្រង់មាត្រា ៤ ចែងអំពីសុពលភាពនៃមូលប្បទានប័ត្រ ដោយត្រូវចុះនិទ្ទេសក៏ពិតមែន ប៉ុន្តែក៏មានករណីលើកលែងមួយចំនួនផងដែរដូចជា៖

(១) បើគ្មានការបញ្ជាក់ជាពិសេសទេ កន្លែងដែលបញ្ជានៅក្បែរឈ្មោះរបស់បហារិតត្រូវបានចាត់ទុកថាជាកន្លែងទូទាត់ប្រាក់។ បើមានកន្លែងច្រើនបញ្ជាក់នៅក្បែរឈ្មោះរបស់បហារិត មូលប្បទានប័ត្រនោះអាចត្រូវទូទាត់សងប្រាក់នៅកន្លែងដែលបញ្ជាក់មុនគេបង្អស់។

(២) បើគ្មានសេចក្តីបញ្ជាក់ទាំងនេះ និងសេចក្តីបញ្ជាក់ណាមួយផ្សេងទៀតទេ មូលប្បទានប័ត្រអាចត្រូវបានទូទាត់សងប្រាក់នៅកន្លែងដែលបហារិតមានទីស្នាក់ការកណ្តាលរបស់ខ្លួន។

(៣) មូលប្បទានប័ត្រដែលមិនបានបញ្ជាក់ច្បាស់លាស់នៅកន្លែងដែលត្រូវចេញ ត្រូវបានចាត់ទុកថាចេញនៅកន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់បហារិត។[55]

នៅរាល់ចំនួនទឹកប្រាក់ដែលត្រូវទូទាត់សង ដោយមូលប្បទានប័ត្រ ត្រូវសរសេរជាតួអក្សរផង និងជាតួលេខផង ហើយកាលបើមានលំអៀងគ្នា ចំនួនទឹកប្រាក់ដែលជាតួអក្សរជាចំនួនដែលត្រូវយកជាបានការ។ ក្នុងករណីដែលចំនួនប្រាក់ដែលត្រូវទូទាត់សង ដោយមូលប្បទានប័ត្រ ត្រូវបានសរសេរច្រើនដងជាតួអក្សរ ឬជាតួលេខ ហើយកាលបើមានចំនួនលំអៀងគ្នា ចំនួនប្រាក់ដែលតូចជាងជាចំនួនដែលត្រូវយកជាបានការ។[56] រាល់កាតព្វកិច្ចនៃបុគ្គលដទៃៗទៀត ដែលបានចុះហត្ថលេខាលើមូលប្បទានប័ត្រនៅតែមានតម្លៃដដែល ទោះបី

---

[51] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, មាត្រា៣។

[52] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, មាត្រា២ ចំណុចទី៣១. សំដៅដល់បុគ្គលដែលទទួលបញ្ជាឱ្យទូទាត់សងមូលប្បទានប័ត្រ ឬរូបិយាណត្តិ។

[53] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, មាត្រា២ ចំណុចទី៣០. សំដៅដល់បុគ្គលដែលចេញបញ្ជាឱ្យទូទាត់សងមូលប្បទានប័ត្រ ឬរូបិយាណត្តិ។

[54] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, មាត្រា៤។

[55] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, មាត្រា៥។

[56] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, មាត្រា១២។

មូលប្បទានប័ត្រនោះ មានហត្ថលេខារបស់បុគ្គលអសមត្ថភាព ឬហត្ថលេខាក្លែងបន្លំ ឬហត្ថលេខារបស់បុគ្គលតាមការប្រឌិត ឬហត្ថលេខាដែលតាមហេតុផលផ្សេងទៀត មិនធ្វើឱ្យបុគ្គលចុះហត្ថលេខា ឬបានចុះហត្ថលេខាជំនួសមានការទទួលខុសត្រូវ។[57]

### ១.២.១.៣. ការសងជាបណ្ណសងតាមបញ្ជា

បណ្ណសងតាមបញ្ជា ជាការសន្យាលាយលក្ខណ៍អក្សរដោយឥតលក្ខខណ្ឌដែលធ្វើឡើង និងចុះហត្ថលេខាដោយបុគ្គលជាអ្នកចេញបណ្ណដែលសន្យាសងចំនួនប្រាក់ជាកំណត់មួយឱ្យទៅ ឬតាមបញ្ជាបុគ្គលមួយទៀត ឬអ្នកកាន់។ បណ្ណសងតាមបញ្ជាត្រូវតែបានទូទាត់សងប្រាក់នៅពេលដល់តណប្រតិទាន ហើយស្របតាមរាល់កាតព្វកិច្ច។[58] បណ្ណសងតាមបញ្ជាក៏មាននិទ្ទេសមិនខុសគ្នានឹងរូបិយាណត្តិដែរ ដូចជា ការសន្យាទូទាត់សងដោយឥតលក្ខខណ្ឌនូវចំនួនប្រាក់ជាកំណត់មួយ រយៈពេលកំណត់ត្រូវទូទាត់សងប្រាក់ កន្លែងដែលត្រូវធ្វើការទូទាត់សងប្រាក់ ឈ្មោះរបស់បុគ្គលដែលទទួលការទូទាត់សងប្រាក់ ឬឈ្មោះរបស់បុគ្គលដែលមានបញ្ជាឱ្យទូទាត់សងប្រាក់ កាលបរិច្ឆេទ និងកន្លែងដែលបណ្ណសងតាមបញ្ជានោះបានចេញផ្សាយ ហត្ថលេខារបស់អ្នកចេញបណ្ណដែលជាបុគ្គលធ្វើការសន្យាលើបណ្ណសងតាមបញ្ជា។[59]

អ្នកកាន់បណ្ណសងតាមបញ្ជាដែលត្រូវទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ ឬនៅក្នុងពេលកំណត់មួយក្រោយកាលបរិច្ឆេទចេញបណ្ណ ឬក្រោយការបង្ហាញ ត្រូវបង្ហាញនៅថ្ងៃទូទាត់សងប្រាក់ ឬនៅថ្ងៃណាមួយរវាង២(ពីរ)ថ្ងៃធ្វើការបន្ទាប់។ ការបង្ហាញបណ្ណសងតាមបញ្ជាតាមរយៈសភាផាត់ទាត់ ឬតាមរយៈប្រព័ន្ធអេឡិចត្រូនិកដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ឬបទបញ្ជាដែលចេញដោយធនាគារជាតិនៃកម្ពុជា គឺជាការបង្ហាញឱ្យទូទាត់សងប្រាក់ជាផ្លូវការ។ អ្នកចេញបណ្ណដែលទូទាត់សងបណ្ណសងតាមបញ្ជា អាចតម្រូវឱ្យប្រគល់បណ្ណសងតាមបញ្ជានោះឱ្យខ្លួន ក្រោយពីបញ្ជាក់ការទទួលប្រាក់ពីអ្នកកាន់។ អ្នកកាន់អាចមិនបដិសេធការទូទាត់ប្រាក់មួយផ្នែកនៃចំនួនប្រាក់បណ្ណសងតាមបញ្ជា។ ក្នុងករណីមានការទូទាត់សងប្រាក់មួយផ្នែកនៃចំនួនប្រាក់ អ្នកចេញបណ្ណអាចទាមទារឱ្យបញ្ជាក់ការសងប្រាក់មួយផ្នែកនោះលើបណ្ណសងតាមបញ្ជា និងទាមទារបង្កាន់ដៃទទួលប្រាក់ផងដែរ។ នៅពេលដែលបណ្ណសងតាមបញ្ជាមិនត្រូវបានបង្ហាញឱ្យទូទាត់សងប្រាក់ នៅក្នុងរយៈពេលកំណត់ កូនបំណុលត្រូវបានអនុញ្ញាតឱ្យតម្កល់ចំនួនប្រាក់នោះនៅអាជ្ញាធរមានសមត្ថកិច្ចតាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា ក្រោយការទទួលខុសត្រូវ និងហានិភ័យរបស់អ្នកកាន់។[60]

[57] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, មាត្រា១៣។

[58] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, មាត្រា១៣៥។

[59] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, មាត្រា១៣៦។

[60] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, មាត្រា១៦៧។

អ្នកកាន់បណ្ណសងតាមបញ្ជាមិនអាចត្រូវបានបង្ខំឱ្យទទួលយកការទូទាត់សងប្រាក់ នៅមុនពេលដល់តណប្រតិទានឡើយ។ អ្នកចេញបណ្ណដែលទូទាត់សងប្រាក់ នៅមុនពេលដល់តណប្រតិទាន ត្រូវទទួលរងហានិភ័យដោយខ្លួនឯងផ្ទាល់។ អ្នកចេញបណ្ណដែលទូទាត់សងប្រាក់ នៅពេលដល់តណប្រតិទាន ត្រូវបានរួចផុតយ៉ាងត្រឹមត្រូវពីកាតព្វកិច្ចរបស់ខ្លួន លើកលែងតែមានកំហុសនៃការក្លែងបន្លំ ឬនៃការធ្វេសប្រហែសធ្ងន់ធ្ងរ។ អ្នកចេញបណ្ណត្រូវទទួលខុសត្រូវផ្ទៀងផ្ទាត់ប្រក្រតីភាពនៃលំដាប់បិដ្ឋិលេខ ប៉ុន្តែមិនផ្ទៀងផ្ទាត់ហត្ថលេខាអ្នកធ្វើបិដ្ឋិលេខឡើយ។ នៅពេលបណ្ណសងតាមបញ្ជាត្រូវបានធ្វើជារូបិយបណ្ណ ដែលមិនមែនជារបស់កន្លែងត្រូវទូទាត់សងប្រាក់ ចំនួនប្រាក់អាចត្រូវទូទាត់សងជារូបិយបណ្ណនៃប្រទេសជាកន្លែងទូទាត់សងប្រាក់ ទៅតាមអត្រាប្តូរប្រាក់នៅថ្ងៃតណប្រតិទាន។ បើការទូទាត់សងប្រាក់មិនត្រូវបានធ្វើនៅពេលបង្ហាញ អ្នកកាន់អាចស្នើសុំការទូទាត់សងចំនួនប្រាក់នៅលើបណ្ណសងតាមបញ្ជានោះ ធ្វើឡើងជារូបិយបណ្ណរបស់ប្រទេសជាកន្លែងទូទាត់សងប្រាក់ ទៅតាមអត្រាប្តូរប្រាក់នៅថ្ងៃតណប្រតិទាន ឬនៅថ្ងៃដែលទូទាត់សងប្រាក់ តាមការជ្រើសរើសរបស់ខ្លួន។ រាល់ការប្រើប្រាស់កន្លែងទូទាត់សងប្រាក់នឹងត្រូវអនុវត្តសម្រាប់កំណត់តម្លៃរូបិយបណ្ណ។ ប៉ុន្តែអ្នកចេញបណ្ណអាចចែងលក្ខខណ្ឌថា ចំនួនប្រាក់ដែលទូទាត់សងនឹងត្រូវគណនាទៅតាមអត្រាប្តូរប្រាក់ ដែលបញ្ជាក់នៅលើបណ្ណសងតាមបញ្ជា។[61]

### ១.២.២. ការបញ្ជូនដីកាសម្រេចដាស់តឿន

ជាគោលការណ៍ការបញ្ជូនដែលមានចែងក្នុងនីតិវិធីរដ្ឋប្បវេណីមាន ការបញ្ជូននៅក្នុងប្រទេស ការបញ្ជូនដែលត្រូវធ្វើនៅបរទេស និងការបញ្ជូនតាមការផ្សាយជាសាធារណៈ។

ប៉ុន្តែ ចំពោះនីតិវិធីដាស់តឿន តុលាការអាចចេញដីកាសម្រេចដាស់តឿនបាន លុះត្រាតែអាចធ្វើការបញ្ជូនដីកាសម្រេចដាស់តឿននោះបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមវិធីផ្សេងៗក្រៅពីការបញ្ជូនតាមការផ្សាយជាសាធារណៈ។[62] ដូចនេះ ការបញ្ជូនដែលត្រូវធ្វើនៅបរទេស និងការផ្សាយជាសាធារណៈ តុលាការមិនចេញដីកាសម្រេចដាស់តឿនបានទេ។

ជារួម លក្ខខណ្ឌនៃការបញ្ជូននេះ គឺធ្វើយ៉ាងណាធានាឱ្យកូនបំណុលទទួលបាននូវដំណឹងអំពីដីកាសម្រេចដាស់តឿន ព្រោះដីកានេះនឹងក្លាយជាលិខិតអនុវត្ត ប្រសិនបើកូនបំណុលខកខានធ្វើការតវ៉ាតាមពេលវេលាកំណត់ ដូច្នេះ បើកូនបំណុលស្ថិតនៅបរទេស ឬក៏ការបញ្ជូនត្រូវបានធ្វើតាមការផ្សាយជាសាធារណៈវិញ

[61] ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥, ជំពូកទី៤, ផ្នែកទី៦។

[62] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១៩ វាក្យខណ្ឌទី២។

នោះកូនបំណុលមានលទ្ធភាពខ្ពស់ ដែលពុំទទួលបាននូវដីកាសម្រេច។[63]

បន្តទៅនេះ យើងនឹងធ្វើការស្វែងយល់អំពីអត្ថន័យនៃការបញ្ជូន(១.២.២.១) អំពីវិធីបញ្ជូនធ្វើបានក្នុងនីតិវិធីដាស់តឿន (១.២.២.២) ដែលអនុវត្តដោយស្ថាប័នដែលធ្វើការបញ្ជូន(១.២.២.៣) និងការបញ្ជូនទៅបុគ្គលដែលអសមត្ថភាព(១.២.២.៤)។

### ១.២.២.១. អត្ថន័យនៃការបញ្ជូន

ការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមវិធីដែលច្បាប់បានកំណត់ ដើម្បីជូនដំណឹងអំពីខ្លឹមសារនៃការឯកសារតាមផ្លូវបណ្តឹងចំពោះភាគី និងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍។ ការជូនដំណឹង  គឺជាវិធីមួយដែលលក្ខណៈទូលាយ និងងាយស្រួលជាងវិធីនៃការបញ្ជូន ដោយអ្នកប្រតិបត្តិការបញ្ជូនអាចប្រើគ្រប់មធ្យោបាយដូចជា តាមទូរស័ព្ទ អ៊ីម៉ែល ប្រៃសនីយ៍ សំបុត្រដើម្បីឱ្យអ្នកត្រូវទទួលការបញ្ជូនបានដឹង ហើយក្នុងនោះនីតិវិធីនៃការបញ្ជូន ក៏ជាមធ្យោបាយមួយនៃការជូនដំណឹងដែរ។

### ១.២.២.២. វិធីបញ្ជូនដែលធ្វើបានក្នុងនីតិវិធីដាស់តឿន

ការបញ្ជូនដីកាសម្រេចដាស់តឿន ច្បាប់បានអនុញ្ញាតលើការបញ្ជូនក្រៅពីការបញ្ជូនដែលធ្វើនៅបរទេស និងការបញ្ជូនជាសាធារណៈ។[64]

នោះការបញ្ជូនដែលធ្វើបានក្នុងក្របខណ្ឌនៃនីតិវិធីដាស់តឿនមាន ការបញ្ជូនដោយការប្រគល់(ក) ការបញ្ជូនដោយការនៅកន្លែងជួបប្រទះ(ខ) ការបញ្ជូនបង្គ្រប់កិច្ច(គ) និងការបញ្ជូនដោយទុកចោល(ឃ) ដែលសុទ្ធសឹងជានីតិវិធីបញ្ជូនដែលត្រូវធ្វើក្នុងព្រះរាជាណាចក្រកម្ពុជា ក្រៅពីការបញ្ជូនជាសាធារណៈ។

#### ក. ការបញ្ជូនដោយការប្រគល់

ដើម្បីអាចធ្វើការបញ្ជូនបានត្រូវមានការជូនដំណឹងអំពីកន្លែងដែលត្រូវធ្វើការបញ្ជូន ហើយការជូនដំណឹងនេះផងដែរត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ។ កន្លែងបញ្ជូន ត្រូវធ្វើនៅទៅលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូន។ ប៉ុន្តែ ចំពោះការបញ្ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់វិញ អាចធ្វើទៅទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់សាមីខ្លួនបាន។[65] ការជូនដំណឹងអំពីទីកន្លែង

---

[63] ក្រុមការងារគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, "សិក្ខាសាលាគណៈមេធាវី(តូច) លើកទី១៤, ប្រធានបទ៖ នីតិវិធីដាស់តឿន, ១៦ កុម្ភៈ ២០១៧", នៅក្នុង *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ៣,* បោះពុម្ពលើកទី១ (ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), មីនា ២០១៧), ៨៤។

[64] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១៩ វាក្យខណ្ឌទី២។

[65] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៤៥។

បញ្ជូន ជាអាទិ៍ ភាគី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអាណត្តិ អាចជូនដំណឹងអំពីកន្លែងដែលខ្លួន ត្រូវទទួលការបញ្ជូននៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬអ្នកដែលទទួលការបញ្ជូន ទៅតុលាការទៅទទួលបណ្តឹង។ ភាគី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអាណត្តិអាចជូនដំណឹងដើម្បីប្តូរកន្លែង ដែលបានជូនដំណឹងថាជាកន្លែងដែលខ្លួនត្រូវទទួលការបញ្ជូន ឬអ្នកដែលបានជូនដំណឹងថាជាអ្នកទទួលការបញ្ជូននោះបាន។[66] មានករណីខ្លះភាគី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអាណត្តិ បានសរសេរបញ្ជាក់រួចជាស្រេចនៅក្នុង ពាក្យបណ្តឹងអំពីទីកន្លែងដែលត្រូវបញ្ជូន បើក្នុងពាក្យបណ្តឹងបានសរសេរអំពីទីកន្លែងដែលត្រូវបញ្ជូនរួចហើយ ហើយការជូនដំណឹងអំពីទីកន្លែងដែលត្រូវបញ្ជូនបើធ្វើតាមនីតិវិធីបានត្រឹមត្រូវហើយ គឺអានុភាពរបស់វាបន្តរហូតដល់តុលាការជាន់ខ្ពស់។ ដើម្បីងាយស្រួលសម្រាប់ធ្វើការបញ្ជូន តុលាការឱ្យភាគីបញ្ជាក់អំពីទីកន្លែងដែលត្រូវបញ្ជូន ហើយឱ្យភាគីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីទីកន្លែងដែលត្រូវបញ្ជូននោះមកតុលាការ។[67]

### ខ. ការបញ្ជូននៅកន្លែងជួបប្រទះ

ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន ពុំច្បាស់លាស់ថា មានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការ នៅក្នុងប្រទេសកម្ពុជាទេ ការបញ្ជូនអាចធ្វើបាននៅទីកន្លែងដែលបានជួបជននោះបាន លើកលែងតែក្នុងករណីដែលមានការជូនដំណឹងអំពីទីកន្លែងដែលធ្វើការបញ្ជូននោះ។ម្យ៉ាងទៀត ទោះបីជាមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការច្បាស់លាស់ នៅក្នុងប្រទេសកម្ពុជា ឬមានការជូនដំណឹងអំពីទីកន្លែងដែលត្រូវបញ្ជូនក៏ដោយ ក៏អាចធ្វើការបញ្ជូននៅទីកន្លែងដែលបានជួបប្រទះជននោះបានដែរ ប្រសិនបើជននោះមិនប្រកែកចំពោះការទទួលការបញ្ជូនទេ។[68]

### គ. ការបញ្ជូនបន្ទប់កិច្ច

ប្រសិនបើមិនបានជួបជនដែលត្រូវទទួលការបញ្ជូននៅកន្លែងដែលត្រូវបញ្ជូនទេ មន្ត្រីដែលទទួលបន្ទុកការបញ្ជូនអាចប្រគល់ឯកសារទៅឱ្យអ្នកបម្រើ ឬអ្នកផ្សេងដែលធ្វើការនៅទីនោះ ឬអ្នកនៅជាមួយដែលបានយល់ដឹងសមរម្យក្នុងការទទួលឯកសារ។[69] អ្នកដែលមានការយល់ដឹងសមរម្យ គឺសំដៅដល់អ្នកដែលបានយល់

[66] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥០។

[67] ក្រុមការងាររាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, "សិក្ខាសាលាស្តីពីនីតិវិធីនៃការបញ្ជូន, ធ្នូ ២០១៤", នៅក្នុង *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), វិច្ឆិកា ២០១៦),១៧១។

[68] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥១។

[69] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥២ កថាខណ្ឌទី១។

ច្បាស់អំពីសារៈសំខាន់នៃការបញ្ជូន យល់ពីអត្ថន័យនៃឯកសារដែលបានទទួល និងមានសមត្ថភាពអាចយកឯកសារនោះទៅប្រគល់ឱ្យជនដែលត្រូវទទួលការបញ្ជូនបាន។

**ឃ. ការបញ្ជូនដោយទុកចោល**

ប្រសិនបើជនដែលទទួលការបញ្ជូន ឬជនដែលត្រូវទទួលការបញ្ជូន ដោយការបង្គ្រប់កិច្ច មិនព្រមទទួលការបញ្ជូន ដោយគ្មានមូលហេតុត្រឹមត្រូវ អាចទុកឯកសារដែលត្រូវបញ្ជូនចោលនៅទីកន្លែងនោះបាន។[70]

ឧទាហរណ៍ ដីកាកោះត្រូវបញ្ជូនទៅឱ្យលោក “ក”(ដើមចោទ) ពេលអាជ្ញាសាលាយកឯកសារនោះទៅដល់លោកផ្ទះលោក “ក” មិនបានជួបលោក “ក” ទេ ជួបតែកញ្ញា “ខ” ដែលជាបម្រើរបស់លោក “ក”។ អាជ្ញាសាលាក៏ប្រគល់ឯកសារឱ្យទៅកញ្ញា “ខ” ដើម្បីទុកឱ្យលោក “ក” តែកញ្ញា “ខ” បានបដិសេធមិនទទួលដោយសំអាងថាខ្លួនជាអ្នកបម្រើមិនហ៊ានទទួល។ ការសំអាងបែបនេះ គឺមិនអាចនិយាយថាមានមូលហេតុត្រឹមត្រូវបានទេ អាជ្ញាសាលាក៏បានទុកឯកសារនៅទីនោះ គឺនៅនៅចំពោះកញ្ញា “ខ”។

**១.២.២.៣. ស្ថាប័នដែលធ្វើការបញ្ជូន**

ស្ថាប័នដែលធ្វើការបញ្ជូន គឺមានមន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន និងមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន។ មន្ត្រីទទួលបន្ទុកក្នុងការបញ្ជូន គឺក្រឡាបញ្ជី។[71] មុខងាររបស់មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន គឺការធ្វើ ឬការផ្តល់សេចក្តីបញ្ជាក់នូវឯកសារសម្រាប់បញ្ជាក់ក្នុងការបញ្ជូន ហើយប្រគល់អំណាចនៃការបញ្ជូនឯកសារនោះទៅមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន ហើយបន្ទាប់មក ទទួលរបាយការណ៍នៃការបញ្ជូនពីមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន ក្រោយការប្រតិបត្តិ ហើយការរក្សារបាយការណ៍នោះជាមួយនឹងសំណុំរឿង ជាដើម។ ក្រៅពីក្រឡាបញ្ជី ក៏មានមន្ត្រីប៉ុស្តិ៍ប្រៃសនីយ៍ អាជ្ញាសាលា ដែលជាអ្នកទទួលបន្ទុកក្នុងការប្រតិបត្តិការបញ្ជូន។[72] មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនមានមុខងារ បញ្ជូនដោយជាក់លាក់ចំពោះជនដែលត្រូវទទួលការធ្វើរបាយការណ៍អំពីការបញ្ជូននោះជូនទៅតុលាការ។

របាយការណ៍ដែលត្រូវបញ្ជូនទៅតុលាការត្រូវបញ្ជាក់អំពីចំណុចដូចជា៖

(ក) សញ្ញាណនៃរឿងក្តី និងឯកសារដែលបានបញ្ជូន។ សញ្ញាណនៃរឿងក្តី ត្រូវសរសេរបញ្ជាក់អំពីប្រភេទនៃរឿងក្តី អាចជារឿងក្តីទាមទារប្រាក់កម្ចី រឿងក្តីលែងលះ ឬសុំបែងចែកមរតក ជាអាទិ៍។ ចំណែកឯ ឯកសារដែលត្រូវបានបញ្ជូនវិញ ត្រូវសរសេរឈ្មោះឯកសារដែលត្រូវបញ្ជូននោះអាចជាដីកាកោះហៅឱ្យចូលមកធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ ដីកាសម្រេចរក្សាការពារ ជាអាទិ៍។

[70] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥២ កថាខណ្ឌទី២។

[71] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៤៦ កថាខណ្ឌទី២។

[72] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៤៦ កថាខណ្ឌទី៣។

(ខ) ជនដែលត្រូវទទួលការបញ្ជូន ត្រូវសរសេរឈ្មោះជនដែលត្រូវទទួលការបញ្ជូន អាចជាដើមចោទ ចុងចម្លើយ ម្ចាស់បំណុល កូនបំណុល ឬសាក្សី ជាអាទិ៍ និងអាសយដ្ឋានរបស់ជននោះ។

(គ) ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលបានធ្វើការបញ្ជូន ជាការបញ្ជាក់អំពីទីកន្លែងដែលបានធ្វើការបញ្ជូន អាចជាទីលំនៅ ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូន និងត្រូវបញ្ជាក់ថា ការបញ្ជូននេះធ្វើនៅថ្ងៃទីប៉ុន្មាន ខែណា ឆ្នាំណា។

(ឃ) វិធីបញ្ជូន មានច្រើនវិធីដូចជា ការបញ្ជូនដោយការប្រគល់ ការបញ្ជូនដោយការជួបប្រទះ ការបញ្ជូនដោយបង្គ្រប់កិច្ច ឬការបញ្ជូនដោយទុកចោល ជាអាទិ៍។

(ង) ក្នុងករណីជនដែលត្រូវទទួលការបញ្ជូននោះមិនចេះអក្សរ មន្ត្រីដែលទទួលបន្ទុកប្រតិបត្តិការបញ្ជូន ត្រូវបញ្ជាក់អំពីហេតុនៃការបញ្ជូននៅក្នុងរបាយការណ៍គប្បីបញ្ជាក់ថា បានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូននូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននេះមិនចេះអានអក្សរ។ ក្នុងករណីបានប្រគល់ទៅឱ្យអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារ គប្បីបញ្ជាក់អត្តសញ្ញាណ ឬរបស់អ្នកទទួលឯកសារ និងបញ្ជាក់ថាបានប្រគល់ទៅឱ្យអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ព្រោះមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅទីកន្លែងដែលត្រូវបញ្ជូននោះ។

(ច) ហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដែលទទួលឯកសារ។

(ឆ) ហេតុការណ៍ដែលមិនព្រមទទួលការបញ្ជូនក្នុងករណីជនដែលត្រូវទទួលការបញ្ជូន ឬអ្នកដែលត្រូវទទួលការប្រគល់ឯកសារប្រកែកមិនព្រមទទួល។

(ជ) ហេតុការណ៍ក្នុងករណីដែលការបញ្ជូនធ្វើតាមការបញ្ជូនដោយបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល គប្បីបញ្ជាក់ថា ឯកសារត្រូវបានទុកចោលនៅទីកន្លែងដែលត្រូវបញ្ជូនដោយហេតុថាបុគ្គលនោះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល ឬហេតុផលរបស់បុគ្គលនោះ មិនទទួលការបញ្ជូន ជាអាទិ៍។

(ឈ) ហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិការបញ្ជូន។[73] ចំពោះឯកសារដែលត្រូវបញ្ជូន គឺឯកសារចម្លងលើកលែងតែក្នុងករណីដែលបានកំណត់ពិសេសដោយច្បាប់។[74]

### ១.២.២.៤. ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្តឹង

តាមក្រមនីតិរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៦ បុគ្គលដែលអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបាន ទាល់តែបុគ្គលនោះមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ផ្សេង

[73] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៤ កថាខណ្ឌទី២។

[74] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៤៧ កថាខណ្ឌទី២។

ទៀត។[75] ហើយបុគ្គលដែលកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពមាន អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។[76] ជនទាំង៣ប្រភេទនេះ ត្រូវធ្វើសកម្មភាពបណ្ដឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ លើកលែងតែចំពោះអនីតិជនដែលទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្ម ពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន។[77] និងលើកលែងចំពោះអនីតិជនដែលទទួលបានអត្តាធីនភាព។[78]

អនីតិជនទាំង២ប្រភេទនេះ គឺអាចធ្វើសកម្មភាពបណ្ដឹងដោយខ្លួនឯងបាន ដោយមិនចាំបាច់ឆ្លងកាត់អ្នកតំណាងដែលច្បាប់បានកំណត់។ ចំពោះអនីតិជនដែលទទួលបានការអនុញ្ញាតឱ្យប្រកបអាជីវកម្ម មានសមត្ថភាពក្នុងការធ្វើបណ្ដឹង បានត្រឹមតែបណ្ដឹងទាក់ទងនឹងជំនួញដែលអនុញ្ញាតនោះប៉ុណ្ណោះ។ ដូចនេះទោះជាអនីតិជនដែលទទួលបានការអនុញ្ញាតឱ្យធ្វើអាជីវកម្មក៏ដោយ បើមិនមែនជាបណ្ដឹងទាក់ទងនឹងអាជីវកម្មដែលបានអនុញ្ញាតនោះទេ អនីតិជននោះនៅតែជាបុគ្គលអសមត្ថភាពដដែល។

ចំពោះបុគ្គលដែលអសមត្ថភាពក្នុងបណ្ដឹង ក៏អាចធ្វើការបញ្ជូនបានដែរ ដោយធ្វើទៅចំពោះអ្នកតំណាងដែលច្បាប់បានកំណត់។[79] អ្នកដែលច្បាប់បានកំណត់សំដៅលើ អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលចំពោះអនីតិជន។[80] មានអ្នកអាណាព្យាបាលទូទៅ ចំពោះជនក្រោមអាណាព្យាបាលទូទៅ និងមានហិតូបត្ថម្ភកៈចំពោះជននៅក្រោមហិតូបត្ថម្ភ។[81]

ចំពោះករណីដែលមានអ្នកមានសិទ្ធិជាតំណាងរួមគ្នាច្រើននាក់ ការបញ្ជូនចំពោះជនណាម្នាក់ជាការគ្រប់គ្រាន់។[82] មានន័យថា បើមានអ្នកតំណាងដែលច្បាប់បានកំណត់រួមគ្នាច្រើននាក់ ការបញ្ជូនអាចធ្វើទៅបានចំពោះតែអ្នកតំណាងដែលច្បាប់បានកំណត់ណាម្នាក់ជាការគ្រប់គ្រាន់។[83] មួយវិញទៀតចំពោះអ្នកជាប់ពន្ធនាគារ ការបញ្ជូនត្រូវធ្វើទៅចំពោះប្រធានពន្ធនាគារ។[84]

---

[75] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២ កថាខណ្ឌទី២។

[76] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៦។

[77] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា២០ កថាខណ្ឌទី១។

[78] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា២១។

[79] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៤៨ កថាខណ្ឌទី១។

[80] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣៤ និងមាត្រា១០៦៧។

[81] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា២៥ និងមាត្រា២៩។

[82] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៤៨ កថាខណ្ឌទី២។

[83] ក្រុមការងាររាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, "សិក្ខាសាលាស្ដីពីនីតិវិធីនៃការបញ្ជូន, ធ្នូ ២០១៤", នៅក្នុង *មេរៀនស្ដីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), វិច្ឆិកា ២០១៦), ៧។

[84] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៤៨។

# ជំពូកទី២
# ការជំនុំជម្រះ និងសម្រេច
# អំពីពាក្យសុំ
# នៃនីតិវិធីដាស់តឿន

# ជំពូកទី២

# ការជំនុំជម្រះ និងសម្រេចអំពីពាក្យសុំនៃនីតិវិធីដាស់តឿន

ក្រោយពីស្វែងយល់អំពីសញ្ញាណនៃនីតិវិធីដាស់តឿន និងអំពីលក្ខខណ្ឌអំពីដីកាសម្រេចដាស់តឿនរួចមក។ ម្ចាស់បំណុលនឹងដាក់ពាក្យសុំទៅតុលាការមានសមត្ថកិច្ចដើម្បីឱ្យចេញដីកាសម្រេចដាស់តឿន។

ម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន(២.១) បន្ទាប់មកកាលបើតុលាការចេញដីកាសម្រេចដាស់តឿន មុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ហើយកូនបំណុលមិនយល់ព្រមនឹងការសម្រេចនេះ នោះកូនបំណុលអាចដាក់ពាក្យសុំតវ៉ាលើដីកាសម្រេចដាស់តឿននោះ(២.២) បន្ទាប់មកតុលាការនឹងប្រកាសការអនុវត្តជាបណ្ដោះអាសន្ន(២.៣) ហើយកូនបំណុលក៏អាចដាក់ពាក្យសុំតវ៉ាក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នបានផងដែរ(២.៤)។

## ២.១. ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន

ដោយពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ត្រូវអនុវត្តតាមបញ្ញត្តិស្ដីពីបណ្ដឹង។ ដូចនេះ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងចំណុចផ្សេងទៀតដូចមានចែងក្នុងមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវស្របតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៣១៩ (លក្ខខណ្ឌនៃដីកាសម្រេចដាស់តឿន) ដោយដាក់ទៅតុលាការមានសមត្ថកិច្ច។

ក្រោយពីម្ចាស់បំណុលបានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន នោះតុលាការនឹងធ្វើការពិនិត្យពាក្យសុំ(២.១.១) និងសម្រេចសេចក្ដីដោយដីកាសម្រេច(២.២.២)។

### ២.១.១. ការពិនិត្យពាក្យសុំ

ក្រោយពីបានដាក់ពាក្យសុំ តុលាការនឹងធ្វើការពិនិត្យលក្ខខណ្ឌ វិនិច្ឆ័យ ដើម្បីចេញដីកាសម្រេច។ ដោយមានការអនុវត្តដូចគ្នាទាក់ទងនឹងបញ្ញត្តិស្ដីពីបណ្ដឹង[85] ក្នុងដំណាក់កាលពិនិត្យពាក្យសុំនេះ បើពាក្យសុំផ្ទុយនឹងមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា នោះតុលាការត្រូវកំណត់អំឡុងពេលសមរម្យឱ្យកែតម្រូវ។[86] ជាមួយគ្នានេះ តុលាការពិនិត្យការដែលម្ចាស់បំណុលបានបង់ពន្ធដាក់ពាក្យសុំផងដែរ បើមិនទាន់បានបង់ទេ នោះតុលាការនឹងកំណត់អំឡុងពេលសម្រាប់ឱ្យម្ចាស់បំណុលបង់ក្នុងអំឡុងពេលសមរម្យដូចគ្នា។[87]

---

[85] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២១។

[86] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៨ កថាខណ្ឌទី១ វាក្យខណ្ឌទី ១។

[87] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៨ កថាខណ្ឌទី១ វាក្យខណ្ឌទី ២។

ការពិនិត្យពាក្យសុំ ត្រូវពិនិត្យលើចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ(២.១.១.១) និងសមត្ថភាពរបស់អ្នកដាក់សុំ(២.១.១.២) ហើយកាលណាបើមានចំណុចខ្វះខាត នោះតុលាការនឹងចេញដីកាបង្គាប់ឱ្យកែតម្រូវ (២.១.១.៣)។

**២.១.១.១. ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ**

ក្នុងពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ម្ចាស់បំណុលត្រូវបំពេញតាមលក្ខខណ្ឌតាម៣១៩នៃក្រមនីតិវិធីរដ្ឋប្បវេណីដែលតម្រូវឱ្យការទាមទារត្រូវតែមានគោលបំណងឱ្យសងជាប្រាក់ និងការបញ្ជូនទៅកូនបំណុលឱ្យបានក្នុងព្រះរាជាណាចក្រកម្ពុជា។ បន្ថែមលើសនេះ ដោយអនុវត្តដូចគ្នាទាក់ទងនឹងបញ្ញត្តិស្ដីពីបណ្ដឹង នោះនីតិវិធីដាស់តឿនត្រូវបំពេញលក្ខខណ្ឌទម្រង់ដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃមាត្រា៧៥ និងត្រូវបង់ពន្ធដាក់ពាក្យសុំផងដែរ ដើម្បីឱ្យនីតិវិធីតុលាការដំណើរទៅបាន។

នោះ តុលាការនឹងធ្វើការពិនិត្យថា ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនត្រូវបានបំពេញតាមមាត្រា៧៥នៃក្រមនីតិវិធីរដ្ឋប្បវេណី(ក) និងការបង់ពន្ធដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿននោះ(ខ)។

**ក. លក្ខខណ្ឌទម្រង់តាមមាត្រា៧៥**

ការដាក់ពាក្យសុំនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដែលត្រូវសរសេរចំណុចដូចខាងក្រោម៖

(ក) ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋាន ជាអាទិ៍ របស់ភាគីមានម្ចាស់បំណុល និងកូនបំណុល និងរបស់អ្នកតំណាងដែលច្បាប់បានកំណត់។[88] ប្រសិនបើជានីតិបុគ្គលវិញ ត្រូវសរសេរនាមករណ៍ ឬឈ្មោះ និងទីតាំងនៃទីស្នាក់ការរបស់នីតិបុគ្គលនោះ បើជាក្រុមហ៊ុន គឺទីស្នាក់ការនាយក ហើយបង្ហាញឱ្យបានច្បាស់លាស់អំពីម្ចាស់បំណុល និងកូនបំណុល បន្ថែមលើសនេះគួរតែបញ្ជាក់អំពីអាសយដ្ឋានដើមតាមច្បាប់ អាយុ ភេទ ជាអាទិ៍។[89] នៅក្នុងបណ្ដឹង ដើមចោទ ឬមេធាវី ត្រូវសរសេរជាចាំបាច់នូវ ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគីព្រមទាំងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ ភាគី គឺជាចំណុចចាំបាច់ដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង ដើម្បីបញ្ជាក់ថាអ្នកណាជាដើមចោទ អ្នកណាជាចុងចម្លើយ បើជារូបវន្តបុគ្គលត្រូវសរសេរឈ្មោះបុគ្គលនោះ ព្រមទាំងអាសយដ្ឋាន។ តែបើជានីតិបុគ្គលត្រូវសរសេរនាមករណ៍ ឬឈ្មោះ និងទីតាំងនៃទីស្នាក់ការនៃនីតិបុគ្គល និងអត្តសញ្ញាណនៃអ្នកតំណាង។ ជាគោលការណ៍ អានុភាពនៃសាលក្រមដែលចេញដោយតុលាការនឹងមានឥទ្ធិពលទៅលើភាគីហើយត្រូវចងភាគីនោះ ហេតុដូច្នេះក្នុងករណីមានការភ័ន្តច្រឡំភាគី នោះសាលក្រមដែលតុលាការចេញនឹងមានបញ្ហា ព្រោះថាពេលដែលពាក្យបណ្ដឹងត្រូវបានដាក់

---

[88] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៥ កថាខណ្ឌទី២ ចំណុច ក ។

[89] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្ដឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ៣៥។

ហើយ តុលាការត្រូវមានករណីយកិច្ចធ្វើការវិនិច្ឆ័យស្តីពីវិវាទរវាងដើមចោទ និងចុងចម្លើយនោះ ហើយក្នុងករណីមានការភ័ន្តច្រឡំភាគី និងមិនស្គាល់ភាគីនោះសាលក្រមនឹងមិនអាចអនុវត្តទៅបានទេ ឬអាចប៉ះពាល់ដល់ផលប្រយោជន៍តតិយជន។ ចំណុចសំខាន់មួយទៀត គឺសមត្ថភាពភាគីក្នុងការធ្វើបណ្តឹង និងអ្នកតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពធ្វើបណ្តឹង ព្រោះថាមានតែបុគ្គលដែលមានសិទ្ធិ និងករណីយកិច្ចតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ផ្សេងទៀត ដែលអាចទទួលឋានៈជាភាគីដើមចោទ ឬចុងចម្លើយ។[90]

(ខ) ខ្លឹមសារនៃដីកាសម្រេចដាស់តឿនដែលម្ចាស់បំណុលទាមទារឱ្យតុលាការចេញ[91] និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ។[92] ការសរសេរបញ្ជាក់អំពីដីកាសម្រេចដែលចង់ឱ្យតុលាការចេញនោះ គឺសរសេរអំពីកម្មវត្ថុនៃការដាក់ពាក្យស្នើសុំដីកាសម្រេចដាស់តឿន ដែលជាចំណុចមួយដែលចាំបាច់ត្រូវសរសេរបញ្ជាក់ក្នុងពាក្យសុំ ដែលត្រូវធ្វើឱ្យបានលំអិត និងច្បាស់លាស់។[93] ដូចដែលបានបកស្រាយអំពីនីតិវិធីដាស់តឿនដែលអាចធ្វើបានចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់[94] ដូចនេះចាំបាច់ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីចំនួនទឹកប្រាក់ដែលទាមទារនោះ។[95] ចំពោះអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ ជាអង្គហេតុចាំបាច់សម្រាប់បញ្ជាក់អំពីការអះអាងអំពីសិទ្ធិ ដែលមានជាអង្គហេតុសំខាន់ៗដែលពាក់ព័ន្ធក្នុងការទាមទារនីមួយៗ។[96] ការទាមទាររបស់ដើមចោទត្រូវតែជាការទាមទារដែលមានផលប្រយោជន៍ និងត្រូវបានកំណត់ដោយច្បាប់សារធាតុ។ នៅក្នុងពាក្យបណ្តឹងដើមចោទត្រូវតែសរសេរនូវខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់នៃសាលក្រមដែលខ្លួនទាមទារឱ្យតុលាការចេញ។ ខ្លឹមសារនៃសាលក្រមដែលទាមទារអោយតុលាការចេញគឺជា

---

[90] ក្រុមការងារគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, "សិក្ខាសាលាគណៈមេធាវី(ធំ) លើកទី១០, ប្រធានបទ៖ អង្គហេតុចម្លង និងការសរសេរពាក្យបណ្តឹង, ២០ សីហា ២០១៥", នៅក្នុង *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), វិច្ឆិកា ២០១៦), ១៥២។

[91] អ៊ីវ ប៉ូលី, *មេរៀនសង្ខេបស្តីពីនីតិវិធីរដ្ឋប្បវេណី*, (ភ្នំពេញ, ២០១០), ១១៨។

[92] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៥ កថាខណ្ឌទី២ ចំណុច ខ ។

[93] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ៣៦។

[94] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៥ កថាខណ្ឌទី២ ចំណុច ខ ។

[95] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ៣៦។

[96] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៥ កថាខណ្ឌទី២ ចំណុច ខ ។

ការសំខាន់ ដែលចាំបាច់ត្រូវសរសេរបញ្ជាក់អោយច្បាស់លាស់នៅក្នុងពាក្យបណ្ដឹង។[97] ដូចនេះក្នុងពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ក៏ត្រូវសរសេរយ៉ាងចាំបាច់អំពីខ្លឹមសារនៃដីកាសម្រេចដែលម្ចាស់បំណុលទាមទារឱ្យតុលាការចេញដូចគ្នាផងដែរ។

(គ) ក្រៅពីនេះ ម្ចាស់បំណុលអាចសរសេរបន្ថែមនូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងតាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗ។ គួរបញ្ជាក់ផងដែរថា ចំណុចនេះ ជាចំណុចដែលស្ម័គ្រចិត្តក្នុងការសរសេរបន្ថែមរបស់ម្ចាស់បំណុល។ ហើយទោះបីជាសរសេរ ឬមិនបានសរសេរក៏ដោយក៏មិនមែនជាមូលហេតុនៃការលើកពាក្យសុំចោលទេ ប៉ុន្តែដើម្បីឱ្យមានភាពច្បាស់លាស់នូវចំណុចវិវាទទាន់ពេលវេលា ម្ចាស់បំណុលគប្បីសរសេរលំអិតនូវចំណុចទាំងនេះ។[98] គោលបំណងនៃបណ្ដឹងរដ្ឋប្បវេណី គឺរក្សាការពារសិទ្ធិដែលត្រូវបានចែងដោយច្បាប់សារធាតុ ដូចនេះកម្មវត្ថុនៃការវិនិច្ឆ័យក្នុងនីតិវិធីបណ្ដឹងគឺជាសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលស្ថិតនៅក្រោមច្បាប់សារធាតុ។ នៅក្នុងបណ្ដឹងរដ្ឋប្បវេណី តុលាការត្រូវសម្រេចថាតើបណ្ដឹងទាមទារនោះ មាន ឬគ្មានមូលហេតុត្រឹមត្រូវ មានន័យថា ដើមចោទមាន ឬគ្មានសិទ្ធិ ហើយសិទ្ធិទាមទាររបស់ដើមចោទ គឺជាចំណុចដែលតុលាការមិនអាចយល់ដឹងផ្ទាល់បានទេ ពីព្រោះសិទ្ធិ គឺជាទស្សនៈវិស័យអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុដែលកើតឡើងសិទ្ធិនោះ ពីព្រោះអង្គហេតុ គឺជាចំណុចដែលអាចយល់ដឹងអំពីអត្ថិភាព ឬនត្ថិភាពបានដោយភស្តុតាង។[99]

### ខ. ការបង់ពន្ធដាក់ពាក្យសុំ

ក្រៅពីសរសេរចំណុចតម្រូវខាងលើហើយ ម្ចាស់បំណុលត្រូវបង់ពន្ធដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿននៅកន្លែងទទួលពាក្យនៃតុលាការ។[100] ចំនួនទឹកប្រាក់ដែលត្រូវបង់មានចំនួន១ភាគ២ (មួយភាគពីរ)

[97] ក្រុមការងារគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, "សិក្ខាសាលាគណៈមេធាវី(ធំ) លើកទី១០, ប្រធានបទ៖ អង្គហេតុចម្បង និងការសរសេរពាក្យបណ្ដឹង, ២០ សីហា ២០១៥", នៅក្នុង *មេរៀនស្ដីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), វិច្ឆិកា ២០១៦),១៥៣។

[98] អ៊ីវ ប៉ូលី, *មេរៀនសង្ខេបស្ដីពីនីតិវិធីរដ្ឋប្បវេណី*, (ភ្នំពេញ, ២០១០), ៤។

[99] ក្រុមការងារគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, "សិក្ខាសាលាគណៈមេធាវី(ធំ) លើកទី១០, ប្រធានបទ៖ អង្គហេតុចម្បង និងការសរសេរពាក្យបណ្ដឹង, ២០ សីហា ២០១៥", នៅក្នុង *មេរៀនស្ដីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), វិច្ឆិកា ២០១៦),១៥៣។

[100] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦១ កថាខណ្ឌទី៧។

នៃចំនួនទឹកប្រាក់ដែលបានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា៦១ ទៅតាមតម្លៃកម្មវត្ថុនៃការទាមទារ។[101] ហើយតម្លៃដែលត្រូវបង់ពន្ធក្នុងកថាខណ្ឌទី១នោះ កំណត់ថា ពេលដែលដាក់ពាក្យបណ្ដឹង ត្រូវបង់ពន្ធដែលមានចំនួនប្រាក់ដោយគណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្ដឹង ដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ ទៅតុលាការ៖[102]

(ក) ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្ដឹងដល់ ១០.០០០.០០០ (ដប់លាន) រៀលក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ១.០០០ (មួយពាន់) រៀល ។

(ខ) ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្ដឹងដែលលើស ១០.០០០.០០០ (ដប់លាន) រៀលដល់ ១០០.០០០.០០០ (មួយរយលាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ៧០០ (ប្រាំពីររយ) រៀល ។

(គ) ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្ដឹងដែលលើស ១០០.០០០.០០០ (មួយរយលាន) រៀលដល់ ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ៣០០ (បីរយ) រៀល ។

(ឃ) ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្ដឹងដែលលើស១.០០០.០០០.០០០ (មួយពាន់លាន) រៀល ក្នុងចំនួន ១០០.០០០ (មួយសែន) រៀល ត្រូវបង់ ១០០ (មួយរយ) រៀល ។

ក្នុងករណីដែលមានការដាក់ពាក្យតវ៉ាស្របច្បាប់លើដីកាសម្រេចដាស់តឿនពីកូនបំណុល ដែលនាំឱ្យការមានការចាត់ទុកថា មានពាក្យបណ្ដឹងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា៣២៧ (អានុភាពនៃពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន) ឬមាត្រា៣៣១ (ការផ្ទេរនីតិវិធីដាស់តឿនទៅនីតិវិធីនៃបណ្ដឹង ដោយពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន) នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការបង់ពន្ធដាក់ពាក្យសុំត្រូវធ្វើឡើងម្ដងទៀតដោយអ្នកដែលបានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ដែលជាម្ចាស់បំណុល ហើយត្រូវបង់ពន្ធចំនួនទឹកប្រាក់ដែលគណនាដោយដកចំនួនពន្ធ ដែលខ្លួនបានបង់ចំពោះការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនពីចំនួនពន្ធដែលបានគណនាតាមកថាខណ្ឌទី១ មាត្រា៦១(ពន្ធដាក់ពាក្យសុំ)។[103] ក្នុងន័យនេះ ទោះបីជាកូនបំណុលបានដាក់ពាក្យសុំតវ៉ាស្របច្បាប់ ហើយនីតិវិធីដាស់តឿនត្រូវក្លាយជានីតិវិធីបណ្ដឹងធម្មតា

---

[101] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦១ កថាខណ្ឌទី៥ វាក្យខណ្ឌទី១។

[102] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦១ កថាខណ្ឌទី១។

[103] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦១ កថាខណ្ឌទី៥ វាក្យខណ្ឌទី២។

ក៏ដោយ ក៏ពន្ធដាក់ពាក្យសុំត្រូវបង់បន្ថែមដោយម្ចាស់បំណុលតាមពន្ធដាក់ពាក្យសុំតាមកម្មវត្ថុនៃបណ្តឹងធម្មតា ដោយដកចេញនូវប្រាក់ពន្ធដែលបានបង់កាលពីដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿននោះ។

### ២.១.១.២. សមត្ថភាពភាគី និងអ្នកតំណាងតាមផ្លូវបណ្តឹង

ភាគី គឺជាប្រធាននៃបណ្តឹងរដ្ឋប្បវេណី ដែលជាទូទៅបណ្តឹងរដ្ឋប្បវេណីត្រូវបានធ្វើឡើង ក្នុងគោលបំណង កំណត់អំពីសិទ្ធិជាកំណត់ណាមួយ ឬនូវអត្ថិភាព ឬនត្ថិភាពនៃទំនាក់ទំនងគតិយុត្តរវាងភាគីទាំងសងខាង ដូចនេះ តុលាការត្រូវធ្វើយ៉ាងណាឱ្យភាគី ដែលប្រឆាំងគ្នាអំពីផលប្រយោជន៍ ចូលរួមក្នុងនីតិវិធីក្នុងនាមជាប្រធាននៃបណ្តឹង ដើម្បីស្តាប់ការអះអាងរបស់ជនទាំងនេះ និងធ្វើការពិនិត្យភស្តុតាង ដែលគេបានស្នើសុំ រួចចេញជាសាលក្រម ឬសាលដីកា។[104]

ភាពចាំបាច់ក្នុងការកំណត់អំពីភាគីនៃបណ្តឹង ពីព្រោះភាគីនៃបណ្តឹង ឬត្រូវបានគេប្តឹង ហើយដើម្បីឱ្យបណ្តឹងមានអានុភាពចំពោះភាគីនោះ យើងត្រូវគិតអំពីសមត្ថភាពរបស់ពួកគេជាមុនសិនផ្អែកលើគោលការណ៍សមត្ថភាពទទួលសិទ្ធិ។ ជាគោលការណ៍ ការធ្វើពាក្យបណ្តឹងរដ្ឋប្បវេណីមួយ ត្រូវបានធ្វើឡើងដោយភាគី ដែលផ្អែកលើមូលដ្ឋានក្នុងការកំណត់សមត្ថភាពក្នុងការធ្វើពាក្យបណ្តឹង។ បុគ្គលដែលអាចជាភាគីក្នុងរឿងក្តីរដ្ឋ-ប្បវេណី ត្រូវតែជាបុគ្គលដែលច្បាប់ទទួលស្គាល់ថា មានសមត្ថភាពគ្រប់គ្រាន់ដើម្បីធ្វើជាភាគីបើសិនជាពុំមានសមត្ថភាពគ្រប់គ្រាន់ត្រូវតែមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីឱ្យតុលាការអនុវត្តនូវបណ្តឹង ឬការចាត់ការលើបណ្តឹងរហូតដល់សេចក្តីសម្រេច។ សមត្ថភាពក្នុងការធ្វើបណ្តឹង គឺជាលក្ខខណ្ឌសុពលភាពនៃសកម្មភាពបណ្តឹងនីមួយៗ ហើយសកម្មភាពរបស់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង គឺជាសកម្មភាពមោឃៈ។ ករណីនេះខុសគ្នានឹងករណីដែលមានកង្វះសមត្ថភាពក្នុងការធ្វើសកម្មភាពតាមក្រមរដ្ឋប្បវេណី ដែលចែងថា សកម្មភាពមានសុពលភាព រហូតដល់ពេលដែលមានការលុបចោល។[105]

បុគ្គលដែលទទួលបានសិទ្ធិ ករណីយកិច្ច តាមបញ្ញត្តិក្រមរដ្ឋប្បវេណីគឺជាបុគ្គលដែលមានលក្ខណៈអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច ហៅថា សមត្ថភាពទទួលសិទ្ធិ។[106] សកម្មភាពក្នុងការធ្វើសកម្មភាពបណ្តឹង គឺជាលក្ខណៈសម្បត្តិភាគី ឬបុគ្គលផ្សេងទៀតដែលពាក់ព័ន្ធក្នុងនីតិវិធីបណ្តឹង អាចមានសមត្ថភាពធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងឱ្យមានអានុភាព ឬទទួលសកម្មភាពបណ្តឹងរបស់តុលាការ និងភាគីម្ខាងទៀតបានហៅថា សមត្ថភាពក្នុងធ្វើសកម្មភាពបណ្តឹង។[107] ទោះបីជាទារកនៅក្នុងគភ៌ក៏ដោយ ក៏ទារកនៅក្នុងគភ៌

[104] ហ៊ី សោភា, *នីតិវិធីរដ្ឋប្បវេណី*, (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច), ៣១។

[105] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៨, មាត្រា២៦ និងមាត្រា៣៥៨ កថាខណ្ឌទី១។

[106] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២ កថាខណ្ឌទី១។

[107] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២ កថាខណ្ឌទី២។

មានសមត្ថភាពក្នុងការទទួលបានសិទ្ធិទាក់ទងនឹងអំពើអនីត្យានុកូល[108] និងសន្តតិកម្ម[109]ផងដែរ។

តទៅនេះ យើងនឹងធ្វើការស្វែងយល់ឱ្យស៊ីជម្រៅអំពី សមត្ថភាពរបស់ភាគី(ក) និងអ្នកតំណាងតាមផ្លូវបណ្ដឹង(ខ)។

**ក. សមត្ថភាពភាគី**

សមត្ថភាពភាគី គឺជាលក្ខណៈសម្បត្តិទូទៅ ដែលបានទទួលស្គាល់ដោយច្បាប់សារធាតុ (ក្រមរដ្ឋប្បវេណី និងច្បាប់ឯកជនផ្សេងទៀត) ចំពោះបុគ្គលដែលអាចមានសិទ្ធិ និងកាតព្វកិច្ចតាមច្បាប់នេះ ដែលអាចជាដើមចោទ ឬចុងចម្លើយនៅក្នុងបណ្ដឹងរដ្ឋប្បវេណីបាន។

រឿងក្ដីរដ្ឋប្បវេណីជារបបមួយ ដើម្បីដោះស្រាយវិវាទរវាងបុគ្គលឯកជន តាមរយៈពេលការកំណត់អំពីសិទ្ធិ និងកាតព្វកិច្ចតាមផ្លូវច្បាប់នៃនីតិឯកជន ឬអត្ថិភាព ឬនត្ថិភាពនៃទំនាក់ទំនងគតិយុត្ត ដូចនេះក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ដោយផ្អែកលើប្រធាននៃទំនាក់ទំនងសិទ្ធិ និងកាតព្វកិច្ច តាមច្បាប់នៃនីតិឯកជនជាការត្រឹមត្រូវមួយ។ ដូចនេះរូបវន្តបុគ្គល និងនីតិបុគ្គល មានសមត្ថភាពជាភាគីនៅក្នុងបណ្ដឹងរដ្ឋប្បវេណី។ ករណីពិសេស ទារកក្នុងគភ៌ក៏មានសមត្ថភាពទទួលសិទ្ធិស្ដីពីការទាមទារសំណង[110] នៃការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល ឬបណ្ដឹងពាក់ព័ន្ធនឹងសន្តតិកម្ម[111] និងអច្ច័យទាន[112]ផងដែរ។ ម៉្យាងទៀតនីតិបុគ្គល មានសមត្ថភាពទទួលសិទ្ធិក្នុងបណ្ដឹង[113] ដែលមានគោលបំណងជម្រះបញ្ជី ទោះបីជានីតិបុគ្គលនោះបានរំលាយហើយក៏ដោយ ដូចនេះនីតិបុគ្គលដែលបានរំលាយក៏មានសមត្ថភាពជាភាគីដែរ។[114]

សមត្ថភាពភាគីក្នុងការធ្វើសកម្មភាពបណ្ដឹង គឺជាលក្ខណៈដែលភាគី ឬបុគ្គលដែលពាក់ព័ន្ធក្នុងនីតិវិធីនៃបណ្ដឹង អាចធ្វើសកម្មភាពបណ្ដឹងខ្លួនឯងដោយមានអានុភាព ឬអាចទទួលសកម្មភាពនៃបណ្ដឹងរបស់

---

[108] គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, *សន្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពីសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី,* (ភ្នំពេញ៖ ទីស្ដីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ ២០៤. អំពើ ដែលបំពាន់ដោយខុសច្បាប់លើសិទ្ធិ ឬផលប្រយោជន៍អ្នកដទៃដោយកំហុសចេតនា ឬអចេតនា។

[109] គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, *សន្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពីសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី,* (ភ្នំពេញ៖ ទីស្ដីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ ១៤៣. ការផ្ទេរនូវសិទ្ធិ និងករណីកិច្ចរបស់មតកជនឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។

[110] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៩។

[111] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៤៩។

[112] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៩៩។

[113] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៦៦។

[114] ហ៊ី សោភា, *នីតិវិធីរដ្ឋប្បវេណី,* (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច), ៣២។

តុលាការ ឬភាគីម្ខាងទៀត មានន័យថាភាគី មានសមត្ថភាពយល់ដឹងអំពីសកម្មភាព លទ្ធផលផ្នែកគតិយុត្តដែលកើតចេញពីសកម្មភាពរបស់ភាគីផ្សេងទៀតរួមទាំងអានុភាពតាមផ្លូវច្បាប់ដែលកើតចេញពីសកម្មភាពរបស់ខ្លួន ឬ អាចយល់អំពីសកម្មភាពរបស់ភាគីផ្សេងទៀតរួមទាំងអានុភាពតាមផ្លូវច្បាប់ ដែលកើតចេញពីសកម្មភាពទាំងនោះផង។ ទោះជាភាគីមានសមត្ថភាពភាគីក៏ដោយ តែប្រសិនបើសាមីខ្លួនពុំមានសមត្ថភាពអាចយល់បាននូវគោលគំនិត ឬអានុភាពនៃសកម្មភាពនៅនៅពេលធ្វើ ឬទទួលសកម្មភាពបណ្ដឹងជាក់ស្ដែងបានទេ បុគ្គលនោះមិនអាចការពារផលប្រយោជន៍របស់ខ្លួនតាមបណ្ដឹងបានទេ ហើយអាចបាត់បង់នូវប្រយោជន៍ច្រើនបាន។[115] ដើម្បីការពារជនដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអះអាង និងការពារផលប្រយោជន៍របស់ខ្លួនតាមពាក្យសុំបាន ច្បាប់បង្កើតនូវរបបនៃសកម្មភាពក្នុងការធ្វើបណ្ដឹង ហើយឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ ធ្វើសកម្មភាពបណ្ដឹងជំនួសជននោះ។[116]

បណ្ដឹង គឺជានីតិវិធីកំណត់ជាស្ថាពរនូវអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ និងកាតព្វកិច្ច ឬទំនាក់ទំនងគតិយុត្តតាមក្រមរដ្ឋប្បវេណី ហើយលទ្ធផលនៃបណ្ដឹង គឺដូចជាការចាត់ចែងសិទ្ធិ និងកាតព្វកិច្ច ឬទំនាក់ទំនងគតិយុត្តដែរ ហេតុនេះហើយ ជាគោលការណ៍ វិសាលភាពនៃជនដែលមានសមត្ថភាពក្នុងការធ្វើបណ្ដឹង ត្រូវបានសម្រេចដោយយកវិសាលភាពនៃជនដែលមានសមត្ថភាពក្នុងការសកម្មភាពតាមច្បាប់សារធាតុ មកធ្វើជាបទដ្ឋាន។[117]

### គ.១. អនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅ

អនីតិជន សំដៅដល់ជនដែលមានអាយុក្រោម ១៨ ឆ្នាំ។[118] ជននៅក្រោមអាណាព្យាបាលទូទៅ សំដៅដល់ នីតិជន ដែលស្ថិតនៅក្នុងស្ថានភាពខ្វះសមត្ថភាពខាងយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធភាពតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនជានិរន្តរ៍ដោយសារមានវិបត្តិផ្នែកស្មារតី ហើយត្រូវបានប្រកាសឱ្យស្ថិតនៅក្រោមអាណា-ព្យាបាលទូទៅ។[119] ក្នុងចំណោមជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព[120] ចំពោះអនីតិជន និងជនដែលក្រោមអាណាព្យាបាលទូទៅ ជាគោលការណ៍ ពុំមានសមត្ថភាពក្នុងការធ្វើបណ្ដឹងទេ ហើយអាចធ្វើ

---

115 ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្ដឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ៣៤។

116 ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣២ កថាខណ្ឌទី២ និងទី៣។

117 ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្ដឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៥។

118 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៧។

119 សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ, *វចនានុក្រមច្បាប់តាមបទដ្ឋានគតិយុត្តខ្មែរ,* (ភ្នំពេញ, មករា ២០១៨), ១២៤។

120 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៦។

សកម្មភាពបណ្តឹងសុពលបាន លុះត្រាតែត្រូវធ្វើតាមអ្នកតំណាងដែលច្បាប់បានកំណត់។[121]

សកម្មភាពបណ្តឹងដែលអនីតិជន និងជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានធ្វើមិនត្រឹមតែអាចលុបចោលបានទេ[122] គឺសកម្មភាពនោះមោឃៈជាដាច់ខាត។ ទោះជាមានការយល់ព្រមពីជនដែលមានសិទ្ធិអំណាចមេបា ឬពីអាណាព្យាបាលក៏ដោយ ក៏មោឃៈដែរ។ ក៏ប៉ុន្តែ ទោះជាអនីតិជនក៏ដោយ តែក្នុងករណីដែលជននោះត្រូវបានចាត់ទុកថា ដល់នីតិភាពដោយអាពាហ៍ពិពាហ៍[123] ជននោះមានសមត្ថភាពក្នុងការធ្វើបណ្តឹងជាទូទៅ ម្យ៉ាងទៀត ក្នុងករណីដែលអនីតិជនត្រូវបានអនុញ្ញាតឱ្យចាត់ចែងចំពោះទ្រព្យសម្បត្តិជាក់លាក់ពិសេស ឬត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម ហើយមានសមត្ថភាពក្នុងការធ្វើសកម្មភាពត្រឹមទំហំនោះ[124] ជននោះមានសមត្ថភាពក្នុងការធ្វើបណ្តឹង ចំពោះបណ្តឹងដែលទាក់ទងនឹងទ្រព្យសម្បត្តិនោះ ឬអាជីវកម្មនោះ[125]។

### ក.២. ជននៅក្រោមហិតូបត្ថម្ភ

ជននៅក្រោមហិតូបត្ថម្ភ សំដៅដល់ជនដែលមានសមត្ថភាពតិចតួចក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ហើយត្រូវបានតុលាការដាក់ឱ្យស្ថិតនៅក្រោមការថែទាំដោយហិតូបត្ថម្ភកៈ។[126]

ដើម្បីធ្វើសកម្មភាពបណ្តឹង អ្នកនៅក្រោមហិតូបត្ថម្ភត្រូវទទួលការយល់ព្រមពីហិតូបត្ថម្ភកៈ។[127] ដូច្នេះ ដើម្បីដាក់ពាក្យសុំ ឬធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ អ្នកនៅក្រោមហិតូបត្ថម្ភត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ ហើយការយល់ព្រមនេះដែរ ត្រូវធ្វើការបញ្ជាក់ដោយលិខិតជាលាយលក្ខណ៍អក្សរ។[128] ប៉ុន្តែ ដើម្បីធ្វើសកម្មភាពតប ចំពោះបណ្តឹង ឬបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលត្រូវបានធ្វើឡើងដោយភាគីម្ខាងទៀត មិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈទេ។[129] ប្រសិនបើចាំបាច់ឱ្យមានការយល់ព្រមពីហិតូបត្ថម្ភកៈ ហើយការយល់ព្រមនេះដែរ ត្រូវធ្វើការបញ្ជាក់ដោយលិខិតជាលាយលក្ខណ៍អក្សរ។[130] ក្នុងករណី

[121] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣២ កថាខណ្ឌទី៣ វាក្យខណ្ឌទី១។

[122] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៨។

[123] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៨។

[124] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៩ និងមាត្រា២០។

[125] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣២ កថាខណ្ឌទី២ វាក្យខណ្ឌទី២។

[126] សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ, *វចនានុក្រមច្បាប់តាមបទដ្ឋានគតិយុត្តខ្មែរ*, (ភ្នំពេញ, មករា ២០១៨), ១២៤។

[127] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣០ ចំណុច ឃ។

[128] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៥ កថាខណ្ឌទី៣។

[129] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៣ កថាខណ្ឌទី១។

[130] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៥ កថាខណ្ឌទី៣។

បើចាំបាច់ឱ្យមានការយល់ព្រមពីហិតូបត្ថម្ភកៈ ប្រសិនជាពុំបានទទួលការយល់ព្រមនោះទេ ភាគីម្ខាងទៀតពុំអាចដាក់ពាក្យបណ្តឹង ឬធ្វើការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានទេ ដោយសារតែហិតូបត្ថម្ភកៈពុំមែនជាអ្នកតំណាងដែលច្បាប់បានកំណត់ទេ ដូច្នេះហើយមិនអាចឱ្យហិតូបត្ថម្ភកៈតំណាងបានទេ។ ដោយឡែក ចំពោះសកម្មភាពដកពាក្យបណ្តឹង ឬដកបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ការផ្សះផ្សា ជាដើម ដែលជាសកម្មភាពបញ្ចប់បណ្តឹងដោយមិនចាំបាច់ឆ្លងកាត់តាមសាលក្រម ឬសាលដីកាឡើយ ជននៅក្រោមហិតូបត្ថម្ភចាំបាច់ត្រូវមានការយល់ព្រមពិសេសជានិច្ច។[131]

### ខ. អ្នកតំណាងតាមផ្លូវបណ្តឹង

អ្នកតំណាងតាមផ្លូវបណ្តឹង គឺជាអ្នកធ្វើសកម្មភាពបណ្តឹង ឬទទួលនូវសកម្មភាពបណ្តឹងរបស់តុលាការ ឬភាគីម្ខាងទៀត ដោយផ្អែកលើឆន្ទៈរបស់ខ្លួន ក្នុងនាមជាភាគី ហើយជំនួសភាគី ហើយអានុភាពនៃការធ្វើសកម្មភាពបណ្តឹង ឬទទួលនូវសកម្មភាពបណ្តឹងនោះនឹងមានទៅលើភាគី។ អានុភាពនៃសកម្មភាពរបស់អ្នកតំណាង មានទៅលើសាមីខ្លួន ដោយសារតែអ្នកតំណាងមានសិទ្ធិតំណាង។ ចំពោះអ្នកតំណាងតាមផ្លូវបណ្តឹង មានអ្នកតំណាងដែលច្បាប់បានកំណត់ និងអ្នកតំណាងដោយអាណត្តិ។[132]

#### ខ.១ អ្នកតំណាងដែលច្បាប់បានកំណត់

តំណាងដែលច្បាប់បានកំណត់ គឺជាអ្នកតំណាងដែលបានទទួលសិទ្ធិនោះដោយយោងតាមបញ្ញត្តិនៃច្បាប់ ឬតាមរយៈសេចក្តីសម្រេចរបស់តុលាការ ជាអាទិ៍ មិនមែនបានទទួលសិទ្ធិនោះដោយផ្អែកលើឆន្ទៈរបស់សាមីភាគីទេ។ អ្នកតំណាងដែលច្បាប់បានកំណត់ ជាទូទៅ នឹងធ្វើសកម្មភាពបណ្តឹង ជំនួសភាគីដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង ដើម្បីផលប្រយោជន៍ភាគីនោះ។ ក៏ប៉ុន្តែ ក្នុងករណីដែលពុំមានអ្នកតំណាងដែលច្បាប់បានកំណត់ទេ ហើយដោយសារតែភាគីម្ខាងទៀតចាំបាច់ធ្វើបណ្តឹងជាបន្ទាន់នោះ ដូច្នេះហើយ តុលាការត្រូវធ្វើការជ្រើសតាំងអ្នកតំណាងពិសេស សម្រាប់តែក្នុងករណីពិសេសនេះ ដើម្បីការពារផលប្រយោជន៍ភាគីម្ខាងទៀតទៅវិញ[133] ហើយនេះក៏ជាការតំណាងដែលច្បាប់បានកំណត់មួយប្រភេទដែរ។[134]

---

[131] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣ កថាខណ្ឌទី២; ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៦។

[132] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៨។

[133] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦។

[134] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៩។

ក្នុងករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់មានការពាក់ព័ន្ធក្នុងនីតិវិធីបណ្តឹង ជាបឋម ភាគីជាអនីតិជន ឬជាជននៅក្រោមអាណាព្យាបាលទូទៅ ហេតុនេះហើយ ជនដែលត្រូវបានផ្តល់នូវសិទ្ធិតំណាងដែលច្បាប់បានកំណត់ តាមផ្លូវច្បាប់សារធាតុ ដូចជាអ្នកមានសិទ្ធិអំណាចមេបាលើអនីតិជននោះ ឬអ្នកអាណាព្យាបាលទូទៅជាដើម ក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់តាមផ្លូវបណ្តឹងសម្រាប់អនីតិជន ឬជននៅក្រោមអាណាព្យាបាលនោះផងដែរ។ ម៉្យាងទៀតប្រសិនបើគ្មានអ្នកតំណាងដែលច្បាប់បានកំណត់តាមច្បាប់សារធាតុទេ ឬប្រសិនបើអ្នកតំណាងដែលច្បាប់បានកំណាត់ពុំអាចអនុវត្តសិទ្ធិតំណាងរបស់ខ្លួនបានទេ តុលាការអាចជ្រើសតាំងអ្នកតំណាងពិសេស[135]សម្រាប់ជនដែលមានបំណងធ្វើសកម្មភាពបណ្តឹងចំពោះបុគ្គលដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង ដោយផ្អែកលើពាក្យសុំរបស់បុគ្គលនោះ។[136]

អ្នកតំណាងដែលច្បាប់បានកំណត់ គឺជាអ្នកតំណាងដែលមិនមែនជាសាមីភាគីទេ ដូច្នេះ មិនអាចក្លាយជាអ្នកដែលមានឈ្មោះនៅក្នុងសាលក្រម ឬសាលដីកាបានឡើយ។[137] ក៏ប៉ុន្តែ អ្នកតំណាងដែលច្បាប់បានកំណត់ ធ្វើសកម្មភាពបណ្តឹង ជំនួសសាមីភាគី ក្នុងករណីដែលសាមីភាគីនោះពុំមានសមត្ថភាពក្នុងការធ្វើបណ្តឹង ហេតុនេះហើយ មានករណីជាច្រើនដែលត្រូវចាត់ទុកអ្នកតំណាងដែលច្បាប់បានកំណត់ ដូចសាមីភាគីដែរ។[138]

## ខ.២ អ្នកតំណាងដោយអាណត្តិ

ជាគោលការណ៍ ជនដែលអាចក្លាយទៅជាអ្នកតំណាងដោយអាណត្តិ មានតែមេធាវីប៉ុណ្ណោះ។[139] នេះគឺដើម្បីការពារផលប្រយោជន៍សាមីភាគីដែលជាអ្នកពឹងពាក់។ ហេតុនេះហើយ ក្នុងករណីដែលជនក្រៅពីមេធាវីបានធ្វើសកម្មភាពបណ្តឹង ក្នុងនាមជាអ្នកតំណាងដោយអាណត្តិ ជាគោលការណ៍ គឺជាអំពើខុសច្បាប់ ហើយតុលាការត្រូវបំបាត់ចោលនូវការពាក់ព័ន្ធរបស់អ្នកនោះ ក្នុងបណ្តឹង។ សកម្មភាពដែលអ្នកនោះបានធ្វើពុំមានសុពលភាពទេ ក៏ប៉ុន្តែ ប្រសិនបើភាគីបានផ្តល់សច្ចានុមតិ សកម្មភាពនោះនឹងមានសុពលភាព។[140]

---

[135] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦ កថាខណ្ឌទី១។

[136] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ៣០។

[137] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៩៨ ចំណុច ក។

[138] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៥ កថាខណ្ឌទី២ ចំណុច ក; មាត្រា១៨៩ កថាខណ្ឌទី១ ចំណុច គ; មាត្រា២៤៨; មាត្រា១៤២ និង មាត្រា១៧៣ កថាខណ្ឌទី១ ចំណុច គ។

[139] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣ កថាខណ្ឌទី១។

[140] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ៣០។

សិទ្ធិតំណាងដោយអាណត្តិ ត្រូវបានផ្តល់ដោយការបង្ហាញឆន្ទៈដោយភាគីថា បានផ្តល់នូវសិទ្ធិតំណាងដោយអាណត្តិក្នុងរឿងក្តីពិសេសណាមួយ ចំពោះជនដែលត្រូវធ្វើតំណាង។ ដើម្បីធ្វើសកម្មភាពតាមផ្លូវនីតិវិធីបណ្តឹងអ្នកតំណាងដោយអាណត្តិ ត្រូវធ្វើការបញ្ជាក់ដោយលាយលក្ខណ៍អក្សរថា ខ្លួនមានសិទ្ធិតំណាងដោយអាណត្តិនោះ។[141] សកម្មភាពបណ្តឹងដែលធ្វើដោយអ្នកតំណាងដោយអាណត្តិ នឹងបង្កើតនូវអានុភាពដូចគ្នានឹងសកម្មភាពដែលធ្វើដោយភាគីដែរ។[142] ក៏ប៉ុន្តែអ្នកតំណាងដោយអាណត្តិមិនមែនជាភាគីទេ ដូច្នេះមិនទទួលនូវអានុភាពនៃសាលក្រម ឬសាលដីកាឡើយ។ ម្យ៉ាងទៀត ខុសពីអ្នកតំណាងដែលច្បាប់បានកំណត់អ្នកតំណាងដោយអាណត្តិអាចធ្វើជាសាក្សី ឬអ្នកធ្វើកោសលវិច័យបាន។ ទោះបីជាបានធ្វើការជ្រើសតាំងអ្នកតំណាងដោយអាណត្តិក៏ដោយ ក៏ភាគីនោះអាចចូលតុលាការតែឯង ឬជាមួយអ្នកតំណាងដោយអាណត្តិ ដើម្បីទាញហេតុផលដោយផ្ទាល់មាត់ដោយខ្លួនឯងបាន។[143] ក្នុងករណីដែលសាមីភាគីបានចូលតុលាការជាមួយអ្នកតំណាងដោយអាណត្តិ ហើយបានលុបចោល ឬកែតម្រូវភ្លាមៗនូវការសារភាព និងសេចក្តីថ្លែងការណ៍ផ្សេងទៀតស្តីពីអង្គហេតុដែលធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ សកម្មភាពរបស់អ្នកតំណាងដោយអាណត្តិនោះនឹងពុំមានសុពលភាពឡើយ។[144] ទំហំនៃសិទ្ធិតំណាងដែលច្បាប់បានកំណត់ មានចែងនៅក្នុងច្បាប់ ចំណែកឯទំហំនៃសិទ្ធិតំណាងដោយឆន្ទៈ គឺមានកំណត់នៅក្នុងកិច្ចសន្យា។[145] ករណីសិទ្ធិតំណាងដោយឆន្ទៈ ជាទូទៅទំហំនៃសិទ្ធិតំណាងត្រូវកំណត់នៅក្នុងលិខិតកិច្ចសន្យាអាណត្តិ ឬលិខិតប្រគល់សិទ្ធិ។

ប៉ុន្តែ ក៏មានករណីខ្លះ កិច្ចសន្យាប្រគល់សិទ្ធិតំណាង ក៏អាចកើតឡើងដោយផ្ទាល់មាត់ផងដែរ។ ទោះបីជា គ្មានលិខិតលាយលក្ខណ៍អក្សរក៏ដោយ ប្រសិនបើបានកំណត់អំពីទំហំនៃសិទ្ធិតំណាងដោយផ្ទាល់មាត់នោះពុំមានបញ្ហាអ្វីនោះទេ ប៉ុន្តែ អាចមានករណីខ្លះទាំងនៅក្នុងលិខិតទាំងផ្ទាល់មាត់ ពុំបានកំណត់អំពីទំហំនៃសិទ្ធិតំណាងទេ។ ក្នុងករណីដែលអ្នកតំណាងដែលមិនបានកំណត់អំពីទំហំនៃសិទ្ធិតំណាងបានបង្កើតកិច្ចសន្យា ប្រសិនបើកិច្ចសន្យានោះជាអំពើថែរក្សា ឬអំពើកែលំអ (អំពើដែលមិនផ្លាស់ប្តូលក្ខណៈនៃកម្មវត្ថុ ឬសិទ្ធិ) នោះកិច្ចសន្យា ដែលត្រូវបានបង្កើតឡើងនោះគឺធ្វើឡើងក្នុងទំហំនៃសិទ្ធិតំណាង ហើយមានអានុភាព។ ប៉ុន្តែ ប្រសិនបើកិច្ចសន្យានោះជា អំពើកែលំអដែលផ្លាស់ប្តូរលក្ខណៈនៃកម្មវត្ថុ ឬសិទ្ធិ ឬជាសកម្មភាពចាត់ចែង នោះកិច្ចសន្យាដែលត្រូវបានបង្កើតឡើង គឺនៅក្រៅទំហំនៃសិទ្ធិតំណាង ហើយជាសកម្មភាពតំណាងដោយគ្មាន

141 ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៥ កថាខណ្ឌទី៣។

142 ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥២ កថាខណ្ឌទី៣។

143 ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥២ កថាខណ្ឌទី២។

144 ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥២ កថាខណ្ឌទី៣ វាក្យខណ្ឌទី២។

145 ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៦៦ កថាខណ្ឌទី១។

សិទ្ធិ។ ហេតុនេះការវិនិច្ឆ័យថា អំពើណាមួយ ជាអំពើថែរក្សា ឬអំពើកែលំអ ( អំពើដែលមិនផ្លាស់ប្តូរលក្ខណៈនៃកម្មវត្ថុ ឬសិទ្ធិ ) ឬជាអំពើផ្សេងពីនេះ មានសារៈសំខាន់ណាស់។ ការវិនិច្ឆ័យថា អំពើណាមួយថាអំពើថែរក្សា ឬអំពើកែលំអនោះ មានភាពពិបាកហេតុនេះ ចាំបាច់ត្រូវធ្វើការសិក្សាស្រាវជ្រាវទៅលើសាលក្រម ឬសាលដីកាដើម្បីមានភាពច្បាស់លាស់។[146]

អ្នកតំណាងដោយអាណត្តិ អាចធ្វើរាល់សកម្មភាពបណ្តឹង ដែលចាំបាច់ក្នុងការបន្តនីតិវិធី ដូចជា ការដាក់ពាក្យបណ្តឹង ការឆ្លើយដោះសាចំពោះបណ្តឹង ការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ជាដើម ចំពោះរឿងក្តីដែលខ្លួនបានទទួលអាណត្តិ។[147] លើសពីនេះទៀត ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិជាមេធាវី ភាគីមិនអាចកម្រិតនូវសិទ្ធិតំណាងនោះបានទេ លើកលែងតែករណីកំណត់មួយចំនួន។[148] ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិជាជនដែលមិនមែនជាមេធាវី ភាគីអាចកម្រិតនូវទំហំនៃសិទ្ធិតំណាងនោះបាន ហើយអាចឱ្យអ្នកតំណាងដោយអាណត្តិនោះធ្វើតំណាងតែចំពោះសកម្មភាពបណ្តឹងមួយចំនួនដែលកំណត់ដោយឡែកបាន។[149] អំពើដែលជាផលប្រយោជន៍របស់ម្ចាស់សិទ្ធិ និងផលប្រយោជន៍របស់អ្នកតំណាងមានភាពផ្ទុយគ្នាទោះបីជាអំពើនោះស្ថិតនៅក្នុងទំហំនៃសិទ្ធិតំណាងក៏ដោយ ក៏អ្នកតំណាងនោះគ្មានសិទ្ធិតំណាងទេ។[150] អំពើដែលនាំឱ្យមានផលប្រយោជន៍ផ្ទុយគ្នា បើនិយាយឱ្យងាយយល់ គឺករណីដែលអ្នកតំណាងទទួលបានផលប្រយោជន៍ពីការខាតបង់របស់ម្ចាស់សិទ្ធិ។ ករណីនេះ ដោយសារកម្រិតគ្រោះថ្នាក់ដែលអ្នកតំណាងបំពានផលប្រយោជន៍របស់ម្ចាស់សិទ្ធិមានកម្រិតខ្ពស់ទើបសិទ្ធិតំណាងត្រូវបានគេកម្រិត។ បញ្ហាត្រង់ថា តើអំពើមួយណាជាអំពើដែលនាំឱ្យមានផលប្រយោជន៍ផ្ទុយគ្នា ឬអត់នោះ គឺចាំបាច់ត្រូវពិចារណាទៅតាមអំពើនីមួយៗ ប៉ុន្តែជំនួយដោយខ្លួនឯង ច្រើនតែជាអំពើដែលនាំឱ្យមានផលប្រយោជន៍ផ្ទុយគ្នា ហេតុនេះត្រូវបានគេសន្មតថា ជាអំពើដែលនាំឱ្យមានផលប្រយោជន៍ផ្ទុយគ្នា។[151]

ការរលត់សិទ្ធិតំណាងដែលបានទទួលពីម្ចាស់សិទ្ធិដោយកិច្ចសន្យាដោយមូលហេតុដូចខាងក្រោម៖

---

[146] ក្រុមការងារក្រសួងយុត្តិធម៌, ប្រធានបទ៖ ការតំណាង , វិច្ឆិកា ២០១៦, នៅក្នុង *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), វិច្ឆិកា ២០១៦), ២៥។

[147] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤ កថាខណ្ឌទី១។

[148] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤ កថាខណ្ឌទី៣។

[149] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤ កថាខណ្ឌទី៤។

[150] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៦៧ កថាខណ្ឌទី១។

[151] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៦៧ កថាខណ្ឌទី២។

(ក) មរណភាព ធនក្ស័យ ឬការរំលាយរបស់ម្ចាស់សិទ្ធិ។

(ខ) មរណភាព ធនក្ស័យ ឬការកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អ្នកតំណាង។

(គ) ការបញ្ចប់អាណត្តិ កិច្ចសន្យាការងារ ឬទំនាក់ទំនងគតិយុត្តផ្សេងទៀត ដែលបានប្រគល់សិទ្ធិតំណាង និងការតំណាងដែលច្បាប់បានកំណត់ ត្រូវរលត់ដោយសារមូលហេតុដែលច្បាប់បានកំណត់។[152]

### ២.១.១.៣. ការបង្គាប់ឱ្យកែតម្រូវ

ក្នុងពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ម្ចាស់បំណុលត្រូវសរសេរចំណុចចាំបាច់ដែលជាចំណុចបញ្ជាក់នៃពាក្យសុំស្របតាមមាត្រា៧៥។ បើមានកង្វះនៅចំណុចទាំងនេះ ពាក្យសុំគ្មានសុពលភាពឡើយដែលតុលាការនឹងបង្គាប់ឱ្យកែតម្រូវក្នុងពេលសមរម្យ ហើយបើកាលណាមិនបានកែតម្រូវក្នុងពេលកំណត់នេះទេ តុលាការនឹងចេញដីកាលើកចោលពាក្យសុំដោយដីកាសម្រេច។[153] ដូចគ្នានឹងករណីមិនបានបង់ពន្ធដាក់ពាក្យសុំនោះតុលាការនឹងបង្គាប់ឱ្យបង់ក្នុងរយៈពេលសមរម្យដូចគ្នា បើមិនដូច្នោះទេ តុលាការនឹងលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនដោយដីកាសម្រេច[154] ព្រោះក្នុងករណីដែលពាក្យសុំមិនបានបង់ពន្ធនៅពេលដាក់ទេ ត្រូវចាត់ទុកថាពាក្យសុំមិនស្របច្បាប់។[155] ចំពោះករណីប្ដឹងជំទាស់នឹងដីកាសម្រេចលើកចោលពាក្យសុំដោយមិនបានកែតម្រូវក្នុងពេលសមរម្យនេះ ច្បាប់បានបញ្ញត្តថាអាចប្ដឹងជំទាស់បាន។[156]

## ២.១.២. ដីកាសម្រេចលើពាក្យសុំ

នីតិវិធីដាស់តឿន ជានីតិវិធីពិសេសមួយដែលសម្រេចដោយមិនបាច់ធ្វើការពិនិត្យលើសិទ្ធិសារធាតុទេ ដូចនេះការសម្រេចអាចធ្វើឡើងដោយមិនបាច់សួរកូនបំណុលឡើយ។[157]

សេចក្ដីសម្រេចរបស់តុលាការលើពាក្យសុំ គឺដីកាសម្រេច។ ដូចនេះ បើតុលាការយល់ឃើញថាមិនស្របច្បាប់ តុលាការនឹងចេញដីកាលើកចោលពាក្យសុំរបស់ម្ចាស់បំណុល បើតុលាការយល់ឃើញថាស្របច្បាប់ តុលាការនឹងចេញដីកាសម្រេចដាស់តឿនលើកូនបំណុលអំពីការស្នើសុំរបស់ម្ចាស់បំណុល។

តុលាការនឹងធ្វើការចេញដីកាសម្រេចលើកចោលពាក្យសុំ(២.១.២.១) ឬដីកាសម្រេចដាស់តឿនលើកូនបំណុល(២.១.២.២)។

[152] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៦៨។

[153] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៨ កថាខណ្ឌទី២។

[154] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៨ កថាខណ្ឌទី១ វាក្យខណ្ឌទី២។

[155] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦១ កថាខណ្ឌទី៧ វាក្យខណ្ឌទី២។

[156] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៨ កថាខណ្ឌទី៣ ។

[157] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៣ កថាខណ្ឌទី១។

### ២.១.២.១. ដីកាសម្រេចលើកចោល

កាលណាពាក្យសុំដីកាសម្រេចដាស់តឿន មិនស្របច្បាប់ដោយសារតែកង្វះលក្ខខណ្ឌតាមមាត្រា៣១៩ (លក្ខខណ្ឌនៃដីកាសម្រេចដាស់តឿន)[158] គឺមិនមានសរសេរការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ឬការដែលមិនអាចបញ្ជូនដីកានោះនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន ឬកង្វះលក្ខខណ្ឌតាមមាត្រា៣២០ (ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន)[159] ដែលដាក់ពាក្យសុំទៅតុលាការដែលគ្មានសមត្ថកិច្ច[160] ឬក្នុងករណីដែលមានភាពច្បាស់លាស់ថា គ្មានមូលហេតុក្នុងការទាមទារដោយគិតអំពីខ្លឹមសារនៃពាក្យសុំ[161] នោះតុលាការត្រូវលើកចោលពាក្យសុំនេះ ដោយដីកាសម្រេច។[162] ចំពោះការទាមទារមួយភាគដែលមិនអាចចេញដីកាសម្រេចដាស់តឿនបាន ក៏ត្រូវអនុវត្តបញ្ញត្តិមាត្រា៣២២(ការលើកចោលពាក្យសុំ) នេះដូចគ្នា[163] បានន័យថា ប្រសិនបើផ្នែកណាមួយនៃពាក្យសុំមានមូលហេតុនៃការលើកចោលដូចបានរៀបរាប់ខាងលើ នោះតុលាការត្រូវលើកចោលនូវផ្នែកដែលមានបញ្ហានោះ។[164]

ចំពោះដីកាសម្រេចលើកចោលពាក្យសុំនេះ មិនអាចប្តឹងឧបាស្រ័យដោយប្តឹងជំទាស់[165]នឹងដីកាសម្រេចនេះបានទេ ព្រោះម្ចាស់បំណុលអាចដាក់ពាក្យសុំដីកាសម្រេចដាស់តឿនម្តងទៀត ឬអាចធ្វើពាក្យបណ្តឹងធម្មតាបាន ដោយមិនបាត់បង់នូវវិធីអះអាងអំពីសិទ្ធិរបស់ខ្លួនឡើយ។[166]

### ២.១.២.២. ដីកាសម្រេចដាស់តឿន

នៅពេលដែលតុលាការទទួលស្គាល់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន នោះតុលាការត្រូវចេញដីកាសម្រេចដាស់តឿន។[167]

---

[158] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២២។

[159] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២២។

[160] ហ៊ី សោភា, *នីតិវិធីរដ្ឋប្បវេណី*, (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច),១១១។

[161] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២២។

[162] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២២។

[163] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២២។

[164] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៤៣។

[165] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, គន្ថីទី៣, ជំពូកទី៤. ជាបណ្តឹងជំទាស់ទៅតុលាការដើម។

[166] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៤៣។

[167] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៤៤។

ការចេញដីកាសម្រេចដាស់តឿននេះ ត្រូវសរសេរបញ្ជាក់នូវចំណុចដែលជាខ្លឹមសារដីកាសម្រេចដាស់តឿន(ក) និងត្រូវធ្វើការបញ្ជូនដីកាសម្រេចទៅកូនបំណុល(ខ) ដើម្បីឱ្យដីកាសម្រេចដាស់តឿនមានអានុភាព(គ)។

**ក. ខ្លឹមសារដីកាសម្រេចដាស់តឿន**

តុលាការត្រូវចេញដីកាសម្រេចដាស់តឿន ដោយសរសេរបញ្ជាក់នូវចំណុចដូចជា៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋាន ជាអាទិ៍ របស់ភាគី និងរបស់អ្នកតំណាងដែលច្បាប់បានកំណត់។[168]
- ដីកាសម្រេចដែលម្ចាស់បំណុលទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ[169]
- សេចក្តីបង្គាប់ឱ្យសងជាប្រាក់ដែលមានកំណត់នូវចំនួន[170]

ក្រៅពីចំណុចទាំងបីសំខាន់ខាងលើ តុលាការត្រូវសរសេរបន្ថែមថា៖ បើកូនបំណុលមិនបានដាក់ពាក្យប្តឹងតវ៉ាការដាស់តឿន ក្នុងអំឡុងពេល២(ពីរ)សប្តាហ៍ បន្ទាប់ពីបានទទួលការបញ្ជូននូវដីកាសម្រេចដាស់តឿននេះទេ នោះតុលាការត្រូវប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដោយឆន្ទានុសិទ្ធិរបស់ខ្លួន។[171]

**ខ. ការបញ្ជូនដីកាសម្រេចដាស់តឿនទៅកូនបំណុល**

កាលណាតុលាការបានចេញដីកាសម្រេចដាស់តឿន បន្ទាប់មកតុលាការត្រូវជូនដំណឹងអំពីដីកាសម្រេចដាស់តឿនទៅឱ្យម្ចាស់បំណុល ហើយបញ្ជូនដីកាសម្រេចនោះ ទៅកូនបំណុលផងដែរ។[172] ក្នុងករណីដែលមិនអាចបញ្ជូនដីកាសម្រេចទៅកូនបំណុល ដូចដែលម្ចាស់បំណុលបានរាយការណ៍ក្នុងពាក្យសុំទេ ព្រោះមូលហេតុដោយសារគ្មានទីលំនៅ ទីសំណាក់ ទីស្នាក់ការ ទីកន្លែងអាជីវកម្មរបស់កូនបំណុល ឬលំនៅឋានរបស់អ្នកទទួលបន្ទុកការងារចម្បង នៅទីកន្លែងដែលម្ចាស់បំណុលបានរាយការណ៍ទេ តុលាការត្រូវជូនដំណឹងទៅម្ចាស់បំណុល[173] ដើម្បីឱ្យម្ចាស់បំណុលរាយការណ៍ពីទីកន្លែងដែលត្រូវបញ្ជូនថ្មី។

បើម្ចាស់បំណុលមិនបានរាយការណ៍ពីកន្លែងថ្មីដែលត្រូវបញ្ជូន ក្រៅពីកន្លែងដែលត្រូវរាយការណ៍ពីមុនក្នុងអំឡុងពេល២(ពីរ)ខែ ដោយគិតចាប់ពីថ្ងៃដែលម្ចាស់បំណុលទទួលដំណឹងទេ នោះត្រូវចាត់ទុកថា ម្ចាស់

[168] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៤ កថាខណ្ឌទី១ ចំណុច ក ។

[169] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៤ កថាខណ្ឌទី១ ចំណុច ខ ។

[170] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៤ កថាខណ្ឌទី១ ចំណុច គ ។

[171] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៤ កថាខណ្ឌទី២។

[172] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៥ កថាខណ្ឌទី១។

[173] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៥ កថាខណ្ឌទី៣ វាក្យខណ្ឌទី១។

បំណុលនោះបានដកពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន[174] ហើយរយៈពេល២(ពីរ)ខែនេះមិនអាចពន្យារបានឡើយ។[175]

### គ. អានុភាពដីកាសម្រេចដាស់តឿន

ដីកាសម្រេចដាស់តឿននេះមានអានុភាព[176] នៅពេលដែលបានបញ្ជូនទៅដល់កូនបំណុល។[177] ដូចនេះដរាបណាកូនបំណុលមិនទាន់បានទទួលដីកាសម្រេចដាស់តឿនទេ នោះដីកាសម្រេចដាស់តឿនមិនទាន់មានអានុភាពទេ។

មួយវិញទៀត ក្នុងករណីដែលមិនអាចបញ្ជូនបានតាមទីកន្លែងដែលម្ចាស់បំណុលបានរាយការណ៍ទេ នោះម្ចាស់បំណុលត្រូវរាយការណ៍ពីទីតាំងថ្មីរបស់កូនបំណុលក្នុងអំឡុងពេល២(ពីរ)ខែ ហើយត្រូវបានបញ្ជូនដីកាសម្រេចដាស់តឿននេះទៅកូនបំណុលហើយកូនបំណុលបានទទួល ទើបដីកាសម្រេចមានអានុភាព ប៉ុន្តែបើផុតអំឡុងពេល២(ពីរ)ខែ នោះត្រូវចាត់ទុកថាម្ចាស់បំណុលបានដកពាក្យសុំ។[178]

## ២.២.ពាក្យសុំតវ៉ាលើដីកាសម្រេចដាស់តឿនមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

ដូចដែលបានសរសេរក្នុងខ្លឹមសារដីកាសម្រេចដាស់តឿន ច្បាប់បានទុកពេល២(ពីរ)សប្តាហ៍រាប់ចាប់ពីថ្ងៃកូនបំណុលបានទទួលដីកាសម្រេចដាស់តឿននេះ ដើម្បីឱ្យកូនបំណុលមានសិទ្ធិដាក់ពាក្យប្តឹងតវ៉ាលើដីកាសម្រេចនេះ ពីព្រោះ ការសម្រេចនេះគឺមិនបានពិនិត្យមើលអត្ថិភាពនៃសិទ្ធិទាមទារដែលម្ចាស់បំណុលបានអះអាងឡើយ ម្យ៉ាងទៀតគឺមិនបានសួរកូនបំណុលឡើយ។[179] ដូចនេះចាំបាច់ត្រូវទុកឱកាសឱ្យកូនបំណុលធ្វើការដាក់ពាក្យសុំតវ៉ាលើដីកាសម្រេចដាស់តឿនមកលើខ្លួននេះ ទៅតុលាការដើម។[180]

---

[174] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៥ កថាខណ្ឌទី៣ វាក្យខណ្ឌទី២។

[175] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៥ កថាខណ្ឌទី៤។

[176] គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, *សន្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពីសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី,* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), លេខ២០០. ផលគតិយុត្ត ដែលកើតចេញពីលិខិតគតិយុត្ត ដូចជា កិច្ចសន្យា ច្បាប់ សេចក្តីសម្រេចរបស់តុលាការ សេចក្តីសម្រេចរបស់រដ្ឋបាល។

[177] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៥ កថាខណ្ឌទី២ ។

[178] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៥ កថាខណ្ឌទី៣ វាក្យខណ្ឌទី២។

[179] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៣ និងមាត្រា៣២៤។

[180] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៣២៣ កថាខណ្ឌទី២ ចែងថា "*កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ទៅតុលាការដែលបានចេញដីកាសម្រេចនោះបាន។*" ដូចនេះ តុលាការដើមជាតុលាការដែលចេញដីកាសម្រេចដាស់តឿនពីការដាក់ពាក្យសុំរបស់ម្ចាស់បំណុល។

យើងនឹងសិក្សាទៅលើអានុភាពនៃដីកាសម្រេចដាស់តឿន ក្នុងករណីកូនបំណុលមិនបានដាក់ពាក្យសុំតវ៉ា(២.២.១) និងក្នុងករណីបានដាក់ពាក្យសុំតវ៉ា(២.២.២)។

### ២.២.១. អានុភាពដីកាសម្រេចដាស់តឿនក្នុងករណីគ្មានពាក្យសុំតវ៉ា

ក្នុងអំឡុងពេល២(ពីរ)សប្តាហ៍ បន្ទាប់ពីថ្ងៃដែលបានទទួលការបញ្ជូនដីកាសម្រេចដាស់តឿន ប្រសិនបើកូនបំណុលមិនបានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនទេ តុលាការត្រូវប្រកាសឱ្យអនុវត្តជាបណ្តោះ-អាសន្ន ដោយកំណត់បញ្ជាក់បន្ថែមនូវសោហ៊ុយសម្រាប់នីតិវិធីដាស់តឿនលើដីកាសម្រេចដាស់តឿន ដោយឆន្ទានុសិទ្ធិតុលាការ។[181]

### ២.២.២. អានុភាពដីកាសម្រេចដាស់តឿនក្នុងករណីមានពាក្យសុំតវ៉ា

ប៉ុន្តែបើករណីមានពាក្យសុំតវ៉ាលើដីកាសម្រេចដាស់តឿនក្នុងអំឡុងពេល២(ពីរ)សប្តាហ៍ នោះតុលាការនឹងពិនិត្យមើលពាក្យសុំតវ៉ានោះថាស្របច្បាប់(២.២.២.១) ឬមិនស្របច្បាប់(២.២.២.២)។

#### ២.២.២.១. ពាក្យសុំតវ៉ាស្របច្បាប់

ប្រសិនបើពាក្យសុំតវ៉ារបស់កូនបំណុលលើដីកាសម្រេចដាស់តឿននៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នក្នុងអំឡុងពេល២(ពីរ)សប្តាហ៍នោះមានលក្ខណៈស្របច្បាប់ នាំឱ្យដីកាសម្រេចដាស់តឿននោះ ត្រូវបាត់បង់អានុភាពក្នុងទំហំនៃការតវ៉ានោះ។[182]

ចំពោះការទាមទារដែលទាក់ទងនឹងការតវ៉ាចំពោះដីកាសម្រេចដាស់តឿន នៅពេលដែលពាក្យសុំតវ៉ាមានលក្ខណៈស្របច្បាប់ ត្រូវចាត់ទុកថាកូនបំណុលបានដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ចដែលបានកំណត់នៅមាត្រា ៣២០ (ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន) នៃក្រមនីតិវិធីរដ្ឋប្បវេណី នៅពេលដែលមានពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនរបស់ម្ចាស់បំណុល ។[183]

នោះតុលាការមិនអាចភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នបានទេ។[184] ក្នុងករណីនេះប្រាក់សោហ៊ុយសម្រាប់នីតិវិធីដាស់តឿន គឺជាផ្នែកមួយនៃប្រាក់ប្រដាប់ក្តី ។[185] នោះមានន័យថា នីតិវិធីដាស់តឿនត្រូវ

---

[181] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៨ កថាខណ្ឌទី១។

[182] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៧ កថាខណ្ឌទី១។

[183] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៧ កថាខណ្ឌទី២។

[184] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៤៥។

[185] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៤៥។

បានក្លាយជានីតិវិធីបណ្តឹងធម្មតា នៅពេលដែលពាក្យសុំតវ៉ារបស់កូនបំណុលមានភាពស្របច្បាប់ គឺតុលាការត្រូវធ្វើការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការទាមទារដែលត្រូវបានអះអាងដោយម្ចាស់បំណុល និងចេញសាលក្រមតាមនីតិវិធីបណ្តឹងធម្មតា។[186]

### ២.២.២.២. ពាក្យសុំតវ៉ាមិនស្របច្បាប់

ប្រសិនបើតុលាការយល់ឃើញថា ពាក្យសុំតវ៉ារបស់កូនបំណុលលើដីកាសម្រេចដាស់តឿននៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នក្នុងអំឡុងពេល២(ពីរ)សប្តាហ៍ មានលក្ខណៈមិនស្របច្បាប់ នោះតុលាការនឹងលើកចោលពាក្យសុំតវ៉ានោះដោយដីកាសម្រេចលើកចោល។[187]

ដូចនេះ តុលាការនឹងអនុវត្តដូចគ្នានឹងករណីដែលកូនបំណុលមិនបានដាក់ពាក្យសុំតវ៉ានឹងដីកាសម្រេចដាស់តឿន ក្នុងរយៈពេល២(ពីរ)សប្តាហ៍ដែរ គឺចេញដីកាសម្រេចដាស់តឿនដោយភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នដែរ។ ប៉ុន្តែការប្រកាសនេះត្រូវរង់ចាំ១(មួយ)សប្តាហ៍គិតចាប់ពីថ្ងៃដែលកូនបំណុលបានទទួលដីកាសម្រេចលើកចោលពាក្យសុំតវ៉ា ព្រោះកូនបំណុលមានសិទ្ធិប្តឹងជំទាស់នឹងដីកាលើកចោលនេះ។[188]ដូចនេះច្បាប់បានផ្តល់សិទ្ធិឱ្យកូនបំណុលក្នុងការប្តឹងជំទាស់នឹងដីកាសម្រេចលើកចោលពាក្យសុំតវ៉ា។

កូនបំណុលអាចប្តឹងជំទាស់នឹងដីកាសម្រេចលើកចោលពាក្យសុំតវ៉ានេះ[189]ទៅតុលាការជាន់ខ្ពស់។[190] ការប្តឹងជំទាស់នេះមានរយៈពេល១(មួយ)សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលដំណឹងពីដីកាសម្រេចលើកចោល ហើយរយៈពេល១(មួយ)សប្តាហ៍នេះមិនអាចពន្យារបានឡើយ។[191]

ប្រសិនបើកូនបំណុលមិនបានដាក់ពាក្យបណ្តឹងជំទាស់នឹងដីកាសម្រេចលើកចោលទេ នោះតុលាការនឹងចេញដីកាសម្រេចដាស់តឿនដោយភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។[192] ហើយក្នុងករណីដែលដីកាសម្រេចលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿននោះបានចូលជាស្ថាពរ មានន័យថាកូនបំណុលថ្លោះសិទ្ធិក្នុងការប្តឹងជំទាស់ គឺដូចដែលកូនបំណុលមិនបានដាក់ពាក្យប្តឹងជំទាស់ក្នុងរយៈពេល

---

[186] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៤៦។

[187] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៦ កថាខណ្ឌទី១។

[188] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៩ កថាខណ្ឌទី២ និងមាត្រា៣០៣។

[189] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៧ កថាខណ្ឌទី២។

[190] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៩ កថាខណ្ឌទី២។

[191] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០៣។

[192] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៨ កថាខណ្ឌទី១។

កំណត់១(មួយ)សប្តាហ៍ដែរ នោះតុលាការសម្រេចចេញដីកាសម្រេចដាស់តឿនដោយភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នដូចគ្នា។[193]

ប៉ុន្តែកាលណាកូនបំណុលបានដាក់ពាក្យបណ្តឹងជំទាស់ គឺត្រូវដាក់នៅតុលាការដើម នោះតុលាការដើមនឹងត្រូវផ្ញើពាក្យបណ្តឹងជំទាស់ទៅតុលាការបណ្តឹងជំទាស់ដែលជាតុលាការជាន់ខ្ពស់ ដើម្បីពិនិត្យបណ្តឹងនោះថាបណ្តឹងជំទាស់នោះស្របច្បាប់(ក) ឬមិនស្របច្បាប់(ខ)។

### ក. បណ្តឹងជំទាស់ស្របច្បាប់

កូនបំណុលអាចប្តឹងជំទាស់នឹងដីកាសម្រេចលើកចោលពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿននេះបានក្នុងរយៈពេល១(មួយ)សប្តាហ៍ គិតចាប់ពីថ្ងៃដែលទទួលដំណឹងអំពីដីកាសម្រេចលើកចោលពាក្យសុំ។[194]

បើតុលាការបណ្តឹងជំទាស់ពិនិត្យឃើញថាបណ្តឹងជំទាស់ស្របច្បាប់ នោះតុលាការនឹងចេញដីកាទទួលស្គាល់បណ្តឹងជំទាស់របស់កូនបំណុល គឺមានន័យថា តុលាការបណ្តឹងជំទាស់មិនទទួលស្គាល់ដីកាសម្រេចដាស់តឿនដែលចេញដោយតុលាការដើមទេ។ នោះនីតិវិធីដាស់តឿននឹងក្លាយជាបណ្តឹងធម្មតានៅតុលាការដើម ហើយម្ចាស់បំណុលមិនអាចប្តឹងជំទាស់នឹងដីកាសម្រេចរបស់តុលាការបណ្តឹងជំទាស់នេះបានឡើយ។[195] នោះតុលាការដើមនឹងធ្វើការជំនុំជម្រះទៅលើអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល គឺជនុំជម្រះតាមនីតិវិធីបណ្តឹងធម្មតា។

### ខ. បណ្តឹងជំទាស់មិនស្របច្បាប់

បើតុលាការជាន់ខ្ពស់ពិនិត្យឃើញថាបណ្តឹងជំទាស់មិនស្របច្បាប់ នោះតុលាការជាន់ខ្ពស់នឹងចេញដីកាសម្រេចលើកចោលបណ្តឹងជំទាស់។ មានន័យថា តុលាការបណ្តឹងជំទាស់ទទួលស្គាល់ដីកាសម្រេចដាស់តឿនរបស់តុលាការដើម។

ប៉ុន្តែក្នុងករណីដែលពុំបានសរសេរច្បាស់លាស់អំពីមូលហេតុនៃការទាមទារឱ្យលុបចោល ក្នុងពាក្យបណ្តឹងជំទាស់ទេ ម្ចាស់បណ្តឹងជំទាស់គប្បីដាក់លិខិតជាលាយលក្ខណ៍អក្សរដែលសរសេរពីចំណុចទាំងនេះ ទៅតុលាការបណ្តឹង នៅក្នុងអំឡុងពេល២(ពីរ)សប្តាហ៍ គិតចាប់តាំងពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងជំទាស់នោះ។[196]

[193] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៨ កថាខណ្ឌទី១។

[194] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០៣។

[195] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៩ កថាខណ្ឌទី៣។

[196] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០១ កថាខណ្ឌទី២។

## ២.៣. ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

តុលាការត្រូវប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ដោយបញ្ជាក់បន្ថែមនូវប្រាក់សោហ៊ុយសម្រាប់នីតិវិធីដាស់តឿន ដោយឆន្ទានុសិទ្ធិនៅពេល៖[197]

- កូនបំណុលមិនបានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ក្នុងអំឡុងពេល២(ពីរ)សប្ដាហ៍ បន្ទាប់ពីថ្ងៃទទួលការបញ្ជូនដីកាសម្រេចដាស់តឿន[198]
- កូនបំណុលបានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ប៉ុន្តែតុលាការចេញដីកាសម្រេចលើកចោលពាក្យសុំតវ៉ានេះ ហើយដីកាសម្រេចលើកចោលពាក្យសុំតវ៉ានេះចូលជាស្ថាពរ។[199]

ក្រោយពីតុលាការបានចេញដីកាសម្រេចដាស់តឿនហើយ ដីកាសម្រេចដាស់តឿនដែលភ្ជាប់បញ្ជាក់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននេះ ត្រូវបញ្ជូនទៅភាគី។[200]

ដីកាសម្រេចដាស់តឿនដោយភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ជាប្រភេទលិខិតអនុវត្ត។[201] ហើយអាចធ្វើការអនុវត្តដោយបង្ខំបាន។[202]

ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននេះ អាចបាត់បង់អានុភាព ដោយការប្រកាសសាលដីការបស់តុលាការជាន់ខ្ពស់ដែលសម្រេចផ្លាស់ប្ដូរការបណ្ដោះអាសន្នតាមទំហំផ្លាស់ប្ដូរ។[203] ការណ៍នេះអាចកើតមានពេលកូនបំណុលដាក់ពាក្យប្ដឹងជំទាស់នឹងដីកាសម្រេចលើកចោលពាក្យសុំតវ៉ា ហើយតុលាការបណ្ដឹងជំទាស់ចេញដីកាសម្រេចទទួលស្គាល់ពាក្យសុំនោះ។ បញ្ញត្តិស្ដីពីសាលក្រមត្រូវយកមកអនុវត្តដូចគ្នា ចំពោះដីកាសម្រេច។[204] ដូចនេះ ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននេះ អាចបាត់បង់អានុភាព ដោយការប្រកាសដីកាសម្រេចរបស់តុលាការជាន់ខ្ពស់ដែលសម្រេចផ្លាស់ប្ដូរនោះ។ ហើយម្ចាស់បំណុលត្រូវធ្វើបដិទានទៅកូនបំណុលវិញ។[205] ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននេះ នឹងមិនមានទេប្រសិនបើមិនបានបញ្ជូនទៅដល់កូនបំណុល។[206]

---

[197] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៨។

[198] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៨ កថាខណ្ឌទី១។

[199] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៨ កថាខណ្ឌទី១។

[200] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៨ កថាខណ្ឌទី២។

[201] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៥០ កថាខណ្ឌទី២ ចំណុច ឃ។

[202] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៥០ កថាខណ្ឌទី១។

[203] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៨ កថាខណ្ឌទី៣ និងមាត្រា១៩៧ កថាខណ្ឌទី១។

[204] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២១៦។

[205] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៩៧ កថាខណ្ឌទី២។

[206] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៨ កថាខណ្ឌទី៣ និងមាត្រា៣២៥ កថាខណ្ឌទី២។

## ២.៤. ពាក្យសុំតវ៉ា ក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

បន្ទាប់ពីតុលាការបានចេញដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយការប្រកាសឱ្យអនុវត្តជាបណ្តោះ-អាសន្នរួច កូនបំណុលអាចដាក់ពាក្យសុំតវ៉ាម្តងទៀតបានប្រសិនបើខកខាន ឬបរាជ័យក្នុងការដាក់ពាក្យសុំតវ៉ាមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។

ចំពោះកូនបំណុលអាចដាក់ឱ្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿននេះទៅតុលាការដែលចេញដីកានេះក្នុងអំឡុងពេល២(ពីរ)សប្តាហ៍ ក្រោយពីបានទទួលការបញ្ជូនដីកាសម្រេចដាស់តឿននេះ។[207] រយៈពេល២(ពីរ)សប្តាហ៍នេះមិនអាចពន្យារបានឡើយ។[208]

ដូចនេះយើងនឹងសិក្សាលើអានុភាពនៃដីកាសម្រេចភ្ជាប់ការប្រកាសនេះ ក្នុងករណីគ្មានពាក្យសុំតវ៉ា (២.៤.១) និងមានពាក្យសុំតវ៉ា(២.៤.២) ពីកូនបំណុល។

### ២.៤.១. អានុភាពដីកាសម្រេចដាស់តឿនក្នុងករណីគ្មានពាក្យសុំតវ៉ា

ប្រសិនបើកូនបំណុលមិនបានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នក្នុងរយៈពេល២(ពីរ)សប្តាហ៍បន្ទាប់ពីថ្ងៃដែលបានទទួលការបញ្ជូនដីកាសម្រេចដាស់តឿននេះទេ ដីកាសម្រេចដាស់តឿននោះនឹងមានអានុភាពដូចសាលក្រមស្ថាពរដែរ។[209] ក្នុងន័យនេះ ការអនុវត្តជាបណ្តោះអាសន្នពីម្ចាស់បំណុលនឹងចូលជាស្ថាពរ នឹងមិនអាចដាក់ពាក្យសុំតវ៉ាទៅតុលាការដើម ឬដាក់ពាក្យប្តឹងជំទាស់ទៅតុលាការជាន់ខ្ពស់បានទេ ហើយកូនបំណុលក៏មិនមានសិទ្ធិក្នុងការធ្វើបដិទានបានដែរ។

### ២.៤.២. អានុភាពដីកាសម្រេចដាស់តឿនក្នុងករណីមានពាក្យសុំតវ៉ា

ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន នៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននេះ មិនមានអានុភាពធ្វើឱ្យបាត់បង់អានុភាពនៃដីកាសម្រេចដាស់តឿនដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្តោះ-អាសន្នទេ។[210] មានន័យថា ម្ចាស់បំណុលនៅតែអាចអនុវត្តជាបណ្តោះអាសន្នលើកូនបំណុលបាន។

---

[207] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៣ កថាខណ្ឌទី២ និងមាត្រា៣២៩ កថាខណ្ឌទី១។

[208] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២៩ កថាខណ្ឌទី ២។

[209] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣៣។

[210] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៤៧។

ពាក្យសុំតវ៉ានេះ មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលទាមទារឱ្យលុបចោលដីកាសម្រេច។ ដីកាសម្រេចនេះសំដៅដល់ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសជាបណ្តោះអាសន្ន។

ប្រសិនបើកូនបំណុលបានដាក់ពាក្យសុំតវ៉ាលើដីកាសម្រេចដាស់តឿននេះ នោះតុលាការនឹងពិនិត្យមើលអំពីភាពស្របច្បាប់(២.៤.២.១) ឬមិនស្របច្បាប់(២.៤.២.២)។

### ២.៤.២.១. ពាក្យសុំតវ៉ាស្របច្បាប់

ប្រសិនបើមានពាក្យសុំតវ៉ាស្របច្បាប់ចំពោះដីកាសម្រេចដាស់តឿន នៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ត្រូវចាត់ទុកថា កូនបំណុលបានដាក់ពាក្យបណ្តឹងទៅតុលាការដែលបានចេញដីកាសម្រេចដាស់តឿន នៅពេលមានពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនពីម្ចាស់បំណុល ចំពោះការទាមទារដែលម្ចាស់បំណុលបានអះអាង គឺនីតិវិធីដាស់តឿនត្រូវបានផ្ទេរជានីតិវិធីបណ្តឹងធម្មតា។[211] ក្នុងករណីនេះ ប្រាក់សោហ៊ុយសម្រាប់នីតិវិធីដាស់តឿន គឺជាផ្នែកមួយនៃប្រាក់ប្រដាប់ក្តី។[212]

ដូចនេះ ក្រោយពីពាក្យសុំតវ៉ាពិនិត្យមើលមានលក្ខណៈស្របច្បាប់ នីតិវិធីដាស់តឿននឹងត្រូវផ្ទេរជានីតិវិធីបណ្តឹងធម្មតា ហើយតុលាការនឹងធ្វើការវិនិច្ឆ័យចេញសាលក្រម។[213]

ប្រសិនបើតុលាការជំនុំជម្រះសម្រេចសេចក្តីទទួលស្គាល់ការទាមទាររបស់ម្ចាស់បំណុល នោះតុលាការនឹងចេញសាលក្រមទទួលស្គាល់នូវដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយការប្រកាសឱ្យអនុវត្តជាបណ្តោះ-អាសន្ន។[214] ប៉ុន្តែបើនីតិវិធីដាស់តឿនបានធ្វើឡើងដោយខុសច្បាប់ នោះតុលាការត្រូវចេញសាលក្រមលុបចោលដីកាសម្រេចដាស់តឿន។[215]

ប្រសិនបើតុលាការសម្រេចមិនទទួលស្គាល់ដីកាសម្រេចដាស់តឿន ដោយយល់ឃើញថា ការទាមទារនោះគ្មានមូលហេតុត្រឹមត្រូវ នោះតុលាការនឹងចេញសាលក្រមលុបចោលនូវដីកាសម្រេចដាស់តឿនដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។[216]

---

[211] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣១ កថាខណ្ឌទី១ និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ១, នីតិវិធីបណ្តឹង,* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ២៤៧។

[212] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣១ កថាខណ្ឌទី ២។

[213] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣១។

[214] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣២ កថាខណ្ឌទី១។

[215] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣២ កថាខណ្ឌទី១ វាក្យខណ្ឌទី២។

[216] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣២ កថាខណ្ឌទី២។

### ២.៤.២.២. ពាក្យសុំតវ៉ាមិនស្របច្បាប់

ប្រសិនបើកូនបំណុលបានដាក់ពាក្យសុំតវ៉ាលើដីកាសម្រេចដាស់តឿន នៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ហើយតុលាការយល់ឃើញថា ពាក្យសុំតវ៉ានេះមិនស្របច្បាប់ មានអំឡុងពេលដែលអាចដាក់ពាក្យសុំតវ៉ាចំពោះការដាស់តឿននោះ បានកន្លងផុតទៅហើយ ជាដើម។ នោះតុលាការត្រូវលើកចោលពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដោយដីកាសម្រេច។[217] ដីកាសម្រេចលើកចោលពាក្យសុំតវ៉ានេះ កូនបំណុលអាចប្ដឹងជំទាស់បាន។[218]

ច្បាប់បានផ្ដល់សិទ្ធិឱ្យកូនបំណុលក្នុងការប្ដឹងជំទាស់នឹងដីកាសម្រេចលើកចោលពាក្យសុំតវ៉ាក្រោយការប្រកាសជាបណ្ដោះអាសន្ននេះម្ដងទៀត។

កូនបំណុលអាចប្ដឹងជំទាស់នឹងដីកាសម្រេចលើកចោលពាក្យសុំតវ៉ានេះបាន[219] ទៅតុលាការជាន់ខ្ពស់។[220] ការប្ដឹងជំទាស់នេះមានរយៈពេល១(មួយ)សប្ដាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលដំណឹងពីដីកាសម្រេចលើកចោល ហើយរយៈពេល១(មួយ)សប្ដាហ៍នេះមិនអាចពន្យារបានឡើយ។[221]

កាលណាកូនបំណុលដាក់ប្ដឹងជំទាស់លើដីកាសម្រេចលើកចោលពាក្យសុំតវ៉ាលើដីកាសម្រេចដាស់តឿនទៅតុលាការជាន់ខ្ពស់។ តុលាការបណ្ដឹងជំទាស់នឹងពិនិត្យពីភាពមិនស្របច្បាប់(ក) និងភាពស្របច្បាប់(ខ)។

#### ក. បណ្ដឹងជំទាស់មិនស្របច្បាប់

ក្នុងករណីដែលតុលាការបណ្ដឹងជំទាស់ពិនិត្យឃើញថា បណ្ដឹងជំទាស់មិនស្របច្បាប់ នោះតុលាការចេញដីកាសម្រេចលើកចោលបណ្ដឹងជំទាស់នោះ។ ប៉ុន្តែតុលាការក៏អាចបង្គាប់ឱ្យកែតម្រូវផងដែរលើចំណុចដែលអាចកែបាន។[222]

ប្រសិនបើកូនបំណុលមិនបានដាក់ពាក្យបណ្ដឹងជំទាស់នឹងដីកាសម្រេចលើកចោលទេ នោះដីកាសម្រេចដាស់តឿនដោយភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននោះនឹងចូលជាស្ថាពរ។[223] ហើយក្នុងករណីដែលដីកាសម្រេចលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿននោះបានចូលជាស្ថាពរ មានន័យថា

---

[217] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣០ កថាខណ្ឌទី១។

[218] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣០ កថាខណ្ឌទី២។

[219] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣០ កថាខណ្ឌទី២។

[220] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៩ កថាខណ្ឌទី២។

[221] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០៣។

[222] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០១ កថាខណ្ឌទី២។

[223] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣៣។

កូនបំណុលថ្លោះសិទ្ធិក្នុងការប្តឹងជំទាស់ គឺដូចដែលកូនបំណុលមិនបានដាក់ពាក្យប្តឹងជំទាស់ក្នុងរយៈពេលកំណត់១(មួយ)សប្តាហ៍ដែរ នោះដីកាសម្រេចដាស់តឿនដោយភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននោះនឹងចូលជាស្ថាពរដូចគ្នា។[224]

**ខ. បណ្តឹងជំទាស់ស្របច្បាប់**

ក្នុងករណីដែលតុលាការបណ្តឹងជំទាស់ពិនិត្យឃើញថា បណ្តឹងជំទាស់ស្របច្បាប់ នោះតុលាការចេញដីកាសម្រេចទទួលស្គាល់បណ្តឹងជំទាស់ ហើយធ្វើការជំនុំជម្រះអំពីអង្គច្បាប់ ក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី១[225] ដើម្បីសម្រេចទទួលស្គាល់ពីអត្ថិភាព ឬនត្ថិភាពនៃដីកាសម្រេចដាស់តឿនដែលចេញដោយតុលាការដើម។

[224] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣៣។

[225] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០៤។

# ជំពូកទី៣
# ការអនុវត្ត
# នីកាសម្រេចជាស់តឿន

# ជំពូកទី៣
# ការអនុវត្តដីកាសម្រេចដាស់តឿន

ដីកាសម្រេចដាស់តឿនដែលចូលជាស្ថាពរ នោះនឹងមានអានុភាពដូចសាលក្រមស្ថាពរដែរ។[226] នោះយើងនឹងសិក្សាពីអានុភាពនៃការអនុវត្តដីកាសម្រេចដាស់តឿន(៣.១) ដែលអនុវត្តដោយស្ថាប័នអនុវត្ត(៣.២) និងគុណប្រយោជន៍នៃបញ្ញត្តិស្ដីពីនីតិវិធីដាស់តឿន(៣.៣)។

## ៣.១. អានុភាពនៃការអនុវត្ត

ការអនុវត្តដោយបង្ខំអាចធ្វើទៅបាន លុះត្រាតែឯកសារចម្លងយថាភូត ឬឯកសារ ចម្លងដែលមានសេចក្ដីបញ្ជាក់នៃលិខិតអនុវត្ត ឬសេចក្ដីសម្រេចដែលនឹងក្លាយជាលិខិតអនុវត្ត នៅពេលចូលជាស្ថាពរបានបញ្ជូនទៅកូនបំណុលនៃការអនុវត្តជាមុនរួចហើយ។[227] ប្រសិនបើឯកសារចម្លងយថាភូត ឬឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃលិខិតអនុវត្តត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្តរួចហើយ នោះម្ចាស់បំណុលនៃការអនុវត្តពុំចាំបាច់ធ្វើការបញ្ជូនម្ដងទៀតនោះទេ ជាពិសេសក្នុងករណីនៃការប្រើអនុសារសាលក្រម ជាលិខិតអនុវត្ត។ លិខិតអនុវត្តគួរតែត្រូវបានបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្តរួចហើយ ដោយពុំចាំបាច់មានពាក្យសុំទេ។[228] ក្នុងករណីនៃការប្រើឯកសារចម្លងយថាភូតនៃកំណត់ហេតុអំពីការផ្សះផ្សា ឬការទទួលស្គាល់នោះការបញ្ជូនគឺអាស្រ័យទៅលើការអនុវត្តព្រោះពុំមានបញ្ញត្តិដែលចែងពីការបញ្ជូនឱ្យទៅកូនបំណុលនៃការអនុវត្ត ដោយចាំបាច់មានពាក្យសុំ។ ប្រសិនបើនៅមិនទាន់បានបញ្ជូន ទៅកូនបំណុលនៃការអនុវត្តទេ នោះម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់ពាក្យសុំបញ្ជូនទៅក្រឡាបញ្ជី ក្នុងករណីនេះ អាជ្ញាសាលាអាចយកឯកសារចម្លងយថាភូត ឬឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃលិខិតអនុវត្ត ទៅទីកន្លែងនៃចលនវត្ថុដែលត្រូវរឹបអូស និងប្រគល់វាឱ្យទៅកូនបំណុលនៃការអនុវត្តបាន ព្រោះអាជ្ញាសាលាគឺជាស្ថាប័នដែលអនុវត្តការបញ្ជូន។[229]

ដើម្បីឱ្យការអនុវត្តមានអានុភាព យើងត្រូវមានពាក្យសុំអនុវត្ត(៣.១.១) រូបមន្តអនុវត្ត(៣.១.២) និងលិខិតអនុវត្ត(៣.១.៣)។

[226] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣៣។

[227] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦០។

[228] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៩០។

[229] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៤៧។

### ៣.១.១. ពាក្យសុំអនុវត្ត

ពាក្យសុំអនុវត្តត្រូវធ្វើជាលាយលក្ខណ៍អក្សរ ទៅស្ថាប័នអនុវត្តដែលមានសមត្ថកិច្ច។ ហើយនៅក្នុងពាក្យសុំនេះត្រូវសរសេរនូវចំណុចមួយចំនួនដូចខាងក្រោម៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយ និងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- សញ្ញាណនៃលិខិតអនុវត្ត
- សេចក្តីសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល
- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់
- ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំ តាមការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល។

នៅពេលដាក់ពាក្យសុំអនុវត្តដោយបង្ខំ ត្រូវភ្ជាប់ជាមួយនឹងលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត។[230] ពាក្យសុំអនុវត្តដោយបង្ខំ ត្រូវធ្វើទៅអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុជាកម្មវត្ថុនៃការអនុវត្តស្ថិតនៅ។[231] ម្ចាស់បំណុលនៃការអនុវត្តអាចសុំឱ្យអនុវត្តលើចលនវត្ថុ និងទីកន្លែងច្រើនក្នុងពាក្យសុំតែមួយបើចលនវត្ថុ និងកន្លែងនោះស្ថិតនៅក្នុងដែនសមត្ថកិច្ចតុលាការអនុវត្តតែមួយ។[232]

ម្ចាស់បំណុលនៃការអនុវត្តត្រូវចំណាយសោហ៊ុយសម្រាប់ការអនុវត្តដូចជា ពន្ធដាក់ពាក្យសុំ[233] (ដែលចំនួនដែលត្រូវបង់កំណត់ដោយច្បាប់ស្តីពីអាជ្ញាសាលា ប៉ុន្តែច្បាប់នេះនៅជាសេចក្តីព្រាងនៅឡើយ) សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ[234] និងសោហ៊ុយភាគី[235]។ សោហ៊ុយសម្រាប់ការអនុវត្តនេះ ម្ចាស់បំណុលនៃការអនុវត្ត

[230] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៨៩។

[231] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៨៤។

[232] ក្រុមការងារគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, "សិក្ខាសាលាគណៈមេធាវី(ធំ) លើកទី៩, ប្រធានបទ៖ នីតិវិធីអនុវត្តដោយបង្ខំ, ០៧ ឧសភា ២០១៥", នៅក្នុង *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA), វិច្ឆិកា ២០១៦), ១១១។

[233] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៧២។

[234] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៧៣។

[235] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៧៤។

ដែលបានដាក់ពាក្យសុំត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលតុលាការកំណត់ថាជាសោហ៊ុយចាំបាច់ ដើម្បីធ្វើនីតិវិធីនៃការអនុវត្តដោយបង្ខំ។ បើម្ចាស់បំណុលនៃការអនុវត្តមិនបានបង់សោហ៊ុយនោះជាមុនទេ តុលាការអនុវត្តអាចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំនោះបាន។ ចំពោះដីកាសម្រេចលើកចោលនេះអាចប្តឹងជំទាស់បាន។[236]

**៣.១.២. រូបមន្តអនុវត្ត**

រូបមន្តអនុវត្ត ជាលិខិតបញ្ជាក់ដែលចេញដោយក្រឡាបញ្ជី ឬសារការី (តាមប្រភេទនៃលិខិតអនុវត្ត) ដែលមានបញ្ជាក់ថា លិខិតអនុវត្តនោះអាចយកទៅអនុវត្តដោយបង្ខំបាន។ ជាគោលការណ៍ ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដោយភ្ជាប់នឹងរូបមន្តអនុវត្តលើកលែងតែករណីមួយចំនួនប៉ុណ្ណោះ ដែលការអនុវត្តដោយបង្ខំមិនទាមទារឱ្យមានរូបមន្តអនុវត្តឡើយ។ ចំពោះការអនុវត្តដោយបង្ខំ ដោយយកសេចក្តីសម្រេចខាងក្រោមនេះជាលិខិតអនុវត្ត ដែលមិនតម្រូវឱ្យមានរូបមន្តអនុវត្តទេគឺធ្វើឡើងដោយផ្អែកលើសេចក្តីចម្លងយថាភូតនៃសេចក្តីសម្រេចតែប៉ុណ្ណោះ៖

- សាលក្រមនៃបណ្តឹងរឿងក្តីទឹកប្រាក់តិច ដែលចូលជាស្ថាពរ
- សាលក្រមនៃបណ្តឹងរឿងក្តីទឹកប្រាក់តិច ដែលភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន
- ដីកាសម្រេចដាស់តឿនដែលភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។[237]

ដើម្បីទទួលបានរូបមន្តអនុវត្ត ត្រូវដាក់ពាក្យសុំរូបមន្តអនុវត្តទៅតុលាការ ហើយអ្នកដែលអាចផ្តល់រូបមន្តអនុវត្តបាន មានក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនោះតាមពាក្យ និងសារការីផ្តល់រូបមន្តអនុវត្តដែលមានទម្រង់ជាលិខិតយថាភូត។[238] សារការីផ្តល់រូបមន្តអនុវត្តដែលមានទម្រង់ជាលិខិតយថាភូត ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់។ ចំណែកឯក្រឡាបញ្ជីអាចផ្តល់រូបមន្តអនុវត្ត ដូចជា៖

- សាលក្រម ឬសាលដីកាស្ថាពរ ដែលបង្គាប់ឱ្យផ្តល់តាវកាលិក
- សាលក្រម ឬសាលដីកាដែលប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដែលបង្គាប់ឱ្យផ្តល់តាវកាលិក
- ដីកាសម្រេចចូលជាស្ថាពរ ដែលបង្គាប់ឱ្យផ្តល់តាវកាលិក
- ដីកាសម្រេចដាស់តឿន ដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន
- ការចាត់ចែងរបស់ក្រឡាបញ្ជី[239]

[236] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៧៥។

[237] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៥៤ កថាខណ្ឌទី១។

[238] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៥៤ កថាខណ្ឌទី២។

[239] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦៦។

- សាលក្រម ឬសាលដីកាស្ថាពររបស់តុលាការបរទេស ដែលទទួលស្គាល់ដោយសាលក្រមរបស់តុលាការខ្មែរចូលជាស្ថាពរ។
- សេចក្តីសម្រេចមជ្ឈត្តករ ដែលទទួលស្គាល់ដោយដីកាសម្រេចរបស់តុលាការចូលជាស្ថាពរ (ដីកាសម្រេចរបស់អនុវត្តសេចក្តីសម្រេចមជ្ឈត្តករ)
- កំណត់ហេតុស្តីពីការសះជា[240] និងកំណត់ហេតុផ្សេងទៀតដែលមានអានុភាពដូចសាលក្រម ឬសាលដីកាបានចូលជាស្ថាពរ។

រូបមន្តអនុវត្តត្រូវបានបែងចែកជាពីរប្រភេទ៖

- រូបមន្តអនុវត្តធម្មតា គឺក្នុងករណីយកបុគ្គលដែលកំណត់ក្នុងលិខិតអនុវត្ត ធ្វើជាកូនបំណុលនៃការអនុវត្ត និងម្ចាស់បំណុលនៃការអនុវត្ត
- រូបមន្តអនុវត្តពិសេស គឺត្រូវផ្តល់ជូនក្នុងករណី សិទ្ធិទាមទារដែលកំណត់ក្នុងលិខិតអនុវត្តភ្ជាប់ជាមួយលក្ខខណ្ឌបង្អង់ ឬពេលកំណត់មិនពិតប្រាកដ ហើយម្ចាស់បំណុលនៃការអនុវត្តបានបញ្ជាក់អំពីការបំពេញលក្ខខណ្ឌ ឬការមកដល់នូវពេលកំណត់មិនពិតប្រាកដនោះ។ ការអនុវត្តដោយបង្ខំដោយយកបុគ្គលផ្សេង ក្រៅពីភាគីដែលសរសេរក្នុងលិខិតអនុវត្ត ធ្វើជាកូនបំណុលនៃការអនុវត្ត ឬម្ចាស់បំណុលនៃការអនុវត្ត។

### ៣.១.៣. លិខិតអនុវត្ត

លិខិតអនុវត្ត ជាឯកសារយថាភូត ដែលបញ្ជាក់នូវអត្ថិភាពនៃសិទ្ធិទាមទារ (សិទ្ធិលើបំណុល ឬសិទ្ធិប្រាតិភោគ) របស់ម្ចាស់បំណុលដែលអាចអនុវត្តដោយបង្ខំដោយកូនបំណុល តាមរយៈការដាក់ពាក្យទៅស្ថាប័នអនុវត្តនៅពេលដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្ត ក្នុងន័យនេះ លិខិតអនុវត្តត្រូវជាលិខិតសម្រេចពីការផ្តល់តាវកាលិកទើបអាចអនុវត្តដោយបង្ខំបាន។ ដីកាសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន បន្ទាប់ពីរយៈពេល២(ពីរ)សប្តាហ៍ក្រោយពីការទទួលបានដីកាសម្រេចដាស់តឿន កូនបំណុលមិនអាចប្តឹងតវ៉ាបានទេ នោះតុលាការអាចប្រកាសការអនុវត្តជាបណ្តោះអាសន្នបាន។ បន្ថែមពីនេះទៀត ករណីដែលមានពាក្យសុំតវ៉ា ហើយតុលាការចេញដីកាសម្រេចលើកចោលពាក្យសុំ ដោយពាក្យនេះខុសច្បាប់ នៅពេលដីកាសម្រេចចូលជាស្ថាពរ តុលាការក៏អាចប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នដោយដីកាសម្រេចដាស់តឿនអាចក្លាយជាលិខិតអនុវត្តហើយ។

[240] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២២២។

ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើលិខិតអនុវត្ត។ ជាទូទៅ លិខិតអនុវត្តគឺសំដៅដល់សេចក្ដីសម្រេចដែលចូលជាស្ថាពរ ទើបមានអានុភាពអនុវត្តដោយបង្ខំ ប៉ុន្តែករណីមួយចំនួនសេចក្ដីដែលប្រកាសអនុវត្តជាបណ្ដោះអាសន្ន ក៏អាចយកធ្វើជាលិខិតអនុវត្តបានដែរ។ លិខិតអនុវត្តចែកចេញជាពីរប្រភេទគឺ លិខិតអនុវត្តទូទៅ និងលិខិតអនុវត្តពិសេស។

លិខិតអនុវត្តទូទៅមានចំនួន ៩ ប្រភេទដូចខាងក្រោម[241]៖

- សាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្ដល់តាវកាលិកដែលចូលជាស្ថាពរ
- សាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្ដល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន
- ដីកាសម្រេចបង្គាប់ឱ្យផ្ដល់តាវកាលិក។ ប៉ុន្តែ ចំពោះដីកាសម្រេចដែលមិនត្រូវមានអានុភាពបើមិនទាន់ចូលជាស្ថាពរវិញ មានកម្រិតតែដីកាសម្រេចនោះបានចូលជាស្ថាពរហើយ ជាគោលការណ៍ដីកាសម្រេចនឹងមានអានុភាពភ្លាមនៅពេលដែលបានធ្វើការជូនដំណឹង[242] ដូច្នេះបើដីកាសម្រេចនោះជាដីកាសម្រេចបង្គាប់ឱ្យផ្ដល់តាវកាលិកនាំឱ្យដីកាសម្រេចនោះមានអានុភាពអនុវត្តបាន ដូចជា ដីកាសម្រេចបង្គាប់ឱ្យបង់សោហ៊ុយចាំបាច់សម្រាប់ការអនុវត្តជំនួស[243]។ ក៏ប៉ុន្តែ ដីកាសម្រេចដែលមានអានុភាពទាល់តែចូលជាស្ថាពរវិញ លុះត្រាតែដីកាសម្រេចនោះបានចូលជាស្ថាពរក្រោយកំឡុងពេល៧(ប្រាំពីរ)ថ្ងៃបានកន្លងហួសទៅ គិតចាប់ពីពេលទទួលដំណឹងអំពីដីកាសម្រេចឱ្យប្រគល់អចលនវត្ថុ[244] ឬនាវា[245]ជាអាទិ៍។ ករណីនេះ ដីកាសម្រេចនឹងចូលជាស្ថាពរក្រោយកំឡុងពេល៧(ប្រាំពីរ)ថ្ងៃបានកន្លងហួសទៅ គិតចាប់ពីពេលទទួលដំណឹងអំពីដីកាសម្រេច[246] មានន័យថា បើមិនបណ្ដឹងជំនួសក្នុងកំឡុងពេល៧(ប្រាំពីរ)ថ្ងៃទេ ដីកាសម្រេចនោះនឹងចូលជាស្ថាពរ។
- ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន
- ការចាត់ចែងរបស់ក្រឡាបញ្ជី៖ ករណីដែលក្រឡាបញ្ជីបានកំណត់ប្រាក់ប្រដាប់ក្ដី ដូច្នេះនាំឱ្យភាគីម្ខាងទៀតអាចយកការចាត់ចែងរបស់ក្រឡាបញ្ជីទាក់នឹងប្រាក់ប្រដាប់ក្ដីទៅធ្វើការអនុវត្តដោយបង្ខំ

[241] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៥០។

[242] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១២។

[243] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥២៧ កថាខណ្ឌទី៤ និងមាត្រា៥២៨ កថាខណ្ឌទី១។

[244] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៥០។

[245] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៨៣។

[246] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០៣។

ដើម្បីទាមទារប្រាក់ពីកូនបំណុលនៃការអនុវត្តបាន ករណីកូនបំណុលនៃការអនុវត្តមិនព្រមសងប្រាក់ប្រដាប់ក្ដីដោយស្ម័គ្រចិត្ត។[247]

- លិខិតយថាភូតដែលធ្វើឡើងដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មានកំណត់។ ប៉ុន្តែ មានកម្រិតតែលិខិតដែលបញ្ជាក់សេចក្តីថ្លែងការណ៍ថា កូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ ដើម្បីធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតយថាភូតដែលធ្វើឡើងដោយសារការីបានលុះត្រាតែៈ ទី១ លិខិតនោះធ្វើឡើងដោយសារការីផ្ទាល់ មិនមែនលិខិតបញ្ជាក់ដោយសារការីទេ ទី២ បានកំណត់អំពីចំនួនទឹកប្រាក់ច្បាស់លាស់ និងទី៣ កូនបំណុលបានធ្វើសេចក្តីថ្លែងការណ៍ការបើខ្លួនមិនសងប្រាក់ទេ ម្ចាស់បំណុលអាចយកលិខិតនេះទៅធ្វើការអនុវត្តដោយបង្ខំបាន ដូចជា កិច្ចសន្យាខ្ចីបរិភោគដែលធ្វើឡើងដោយសារការី ជាអាទិ៍។
- សាលក្រម ឬសាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុវត្តដែលបានចូលជាស្ថាពរ។ សាលក្រមអនុវត្ត មានន័យថា ជាសាលក្រមដែលផ្តល់អានុភាពជាស្ថាពរទៅឱ្យសាលក្រម ឬសាលដីការបស់តុលាការបរទេស ដើម្បីអាចយកមកអនុវត្តនៅប្រទេសកម្ពុជាបាន។[248]
- សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថាពរ។ ដីកាសម្រេចអនុវត្តមានន័យថា ជាដីកាសម្រេចដែលផ្តល់អានុភាពជាស្ថាពរដល់សេចក្តីសម្រេចមជ្ឈត្តករ ដើម្បីអាចយកទៅអនុវត្តដោយបង្ខំបាន។[249]
- កំណត់ហេតុស្តីពីការសះជា[250] និងកំណត់ហេតុផ្សេងទៀតដែលមានអានុភាពដូចសាលក្រម ឬសាលដីកាស្ថាពរ គឺសំដៅដល់កំណត់ហេតុសះជា និងកំណត់ហេតុទទួលស្គាល់ការទាមទារមិនអាចធ្វើការអនុវត្តដោយបង្ខំបានទេ ដោយសារដើមចោទបានទទួលស្គាល់ដោយខ្លួនឯងថា ខ្លួនមិនមានសិទ្ធិនោះទេ។

លិខិតអនុវត្តពិសេសមានចំនួន ២ ប្រភេទៈ

- សាលក្រម ឬសាលដីកាស្ថាពរ ដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬលិខិតដែលមានអានុភាពដូចសាលក្រម ឬសាលដីកាស្ថាពរ ដូចជា សាលក្រមស្ថាពរដែលទទួលស្គាល់អត្ថិភាពនៃហ៊ីប៉ូតែក សាលក្រមច្រានចោលអំពីនត្ថិភាពនៃហ៊ីប៉ូតែក សាលក្រមស្ថាពរដែលបង្គាប់ឱ្យចុះបញ្ជី

[247] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦៦ កថាខណ្ឌទី១។

[248] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៥២។

[249] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៥៣។

[250] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២២២។

អំពីការបង្កើតហ៊ីប៉ូតែក កំណត់ហេតុសះជា ឬកំណត់ហេតុទទួលស្គាល់ការទាមទារដែលមានអត្ថន័យដូចសាលក្រមខាងលើ។

- លិខិតយថាភូតដែលធ្វើឡើងដោយសារការី ហើយដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ដូចជា លិខិតយថាភូតនៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ការបញ្ចាំអចលនវត្ថុ ជាអាទិ៍។

## ៣.២. ស្ថាប័នអនុវត្ត

ស្ថាប័នអនុវត្ត គឺជាស្ថាប័នដែលទទួលបន្ទុកកាន់អំណាចធ្វើការអនុវត្តដោយបង្ខំ ដែលជាអំណាចរបស់រដ្ឋ។ ស្ថាប័នអនុវត្ត ជាស្ថាប័នមួយដែលឯករាជ្យនៃអំណាចតុលាការ។ ដោយសារតែនីតិវិធីនៃការអនុវត្តដោយបង្ខំ គឺជានីតិវិធីដាច់ដោយឡែក និងឯករាជ្យពីនីតិវិធីបណ្តឹង ដូច្នេះមិនចាំបាច់ទាល់តែតុលាការទទួលពាក្យបណ្តឹង ជាស្ថាប័នអនុវត្តឡើយ មានន័យថា តុលាការនីតិវិធីនៃបណ្តឹង អាចផ្សេងពីស្ថាប័នអនុវត្តបាន។

ស្ថាប័នអនុវត្តចែកចេញជាពីរប្រភេទ គឺតុលាការអនុវត្ត (៣.២.១) និង អាជ្ញាសាលា(៣.២.២) ។

### ៣.២.១. តុលាការអនុវត្ត

តុលាការអនុវត្ត គឺសំដៅដល់សាលាដំបូង។ តុលាការអនុវត្តមានភារកិច្ចច្រើន ក្នុងនីតិវិធីអនុវត្តដោយបង្ខំ ជាអាទិ៍ ការអនុវត្តដោយបង្ខំរឹបអូសអចលនវត្ថុ។ តុលាការអនុវត្តមានភារកិច្ចធ្វើការអនុវត្តដោយបង្ខំ ឬដែលពាក់ព័ន្ធនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ គឺតុលាការអនុវត្ត។[251] តុលាការអនុវត្ត ធ្វើការអនុវត្តដោយមិនចុះដល់ទីកន្លែងជាក់ស្តែងនោះទេ ហើយក្នុងករណីដែលចាំបាច់ត្រូវចុះដល់កន្លែង គឺត្រូវមានអ្នកជំនួយចុះទៅដល់ទីកន្លែងនោះ។

ក្នុងករណីដែលតុលាការអនុវត្តដើរតួនាទីជាស្ថាប័នអនុវត្តដោយផ្ទាល់ ប្រភេទនៃនីតិវិធីនៃការអនុវត្តដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការនេះ រួមមាន ការអនុវត្តដោយបង្ខំ និងការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត[252] ការអនុវត្តដោយបង្ខំ និងការអនុវត្តសិទ្ធិលើប្រាតិភោគចំពោះអចលនវត្ថុ[253] ការអនុវត្តដោយបង្ខំ និងការអនុវត្តសិទ្ធិប្រាតិភោគ ចំពោះនាវា[254] ការអនុវត្តដោយបង្ខំ ឱ្យប្រគល់វត្ថុ ក្នុងករណីវត្ថុដែលជាកម្មវត្ថុត្រូវបានកាន់កាប់ដោយតតិយជន[255] និងការអនុវត្តដោយ

---

[251] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣៦។

[252] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤០២។

[253] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤១៨។

[254] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៥៦។

[255] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥២៦។

បង្ខំចំពោះកាតព្វកិច្ចដែលមានគោលបំណងឱ្យធ្វើ ឬមិនឱ្យធ្វើសកម្មភាពណាមួយ។[256]

នៅពេលដើរតួជាស្ថាប័នសម្រាប់ផ្តល់កិច្ចសហការ និងមើលខុសត្រូវលើនីតិវិធីនៃការអនុវត្តដែលស្ថិតនៅក្រោមបន្ទុករបស់អាជ្ញាសាលា តុលាការអនុវត្តមានសិទ្ធិអំណាចនៅក្នុងការអនុញ្ញាតឱ្យអនុវត្តនៅ ថ្ងៃសម្រាក ឬពេលយប់[257] ការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស[258] ជាអាទិ៍។ ចំពោះហេតុដែលកើតឡើងនៅក្នុងអំឡុងពេលនៃការអនុវត្ត តុលាការអនុវត្តក៏មានសមត្ថកិច្ចលើការសម្រេចសេចក្តីអំពីការតវ៉ាចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត[259] ជាអាទិ៍ ដែរ។ ការសម្រេចសេចក្តីអំពីការតវ៉ាចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា ស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ។ នៅក្នុងករណីនេះ ដោយសារថាសាលាដំបូងនោះមិនដើរតួនាទីជាស្ថាប័នអនុវត្ត គេមិនហៅតុលាការនោះថាជាតុលាការអនុវត្តទេ។[260] សមត្ថកិច្ចរបស់តុលាការអនុវត្ត គឺជាសមត្ថកិច្ចផ្តាច់មុខ[261] តុលាការដែលត្រូវអនុវត្តបែងចែកចំណែកត្រូវធ្វើតារាងចែងចំណែក នៅកាលបរិច្ឆេទនៃការបែងចែកចំណែកនោះ លើកលែងតែក្នុងករណីដែលម្ចាស់បំណុលមានតែម្នាក់ ឬក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយទឹកប្រាក់ដែលត្រូវបំពេញការចែកចំណែកនោះ អាចសងសព្វគ្រប់ចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ ព្រមទាំងសោហ៊ុយសម្រាប់ការអនុវត្ត។[262]

### ៣.២.២. អាជ្ញាសាលា

អាជ្ញាសាលា មានន័យពីរយ៉ាង គឺអាជ្ញាសាលាក្នុងនាមជាស្ថាប័ន និងអាជ្ញាសាលាក្នុងនាមជាមន្ត្រី។ អាជ្ញាសាលាក្នុងនាមជាស្ថាប័ន គឺជាស្ថាប័នយុត្តាធិការឯករាជ្យមួយ ដែលទទួលបន្ទុកធ្វើកិច្ចការបញ្ជូនឯកសារនានាដែលចេញដោយតុលាការ និងធ្វើការអនុវត្តដោយបង្ខំមួយចំនួនតាមច្បាប់កំណត់។ អាជ្ញាសាលាក្នុងនាមជាមន្ត្រី គឺជាមន្ត្រីរាជការដែលត្រូវតែងតាំងដោយប្រកាសក្រសួងយុត្តិធម៌។[263] សមត្ថកិច្ចរបស់អាជ្ញាសាលាក្នុងការអនុវត្តដោយបង្ខំ រួមមាន ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ និងការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ។

---

[256] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥២៧ និងមាត្រា៥២៨។

[257] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៤០។

[258] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៨១។

[259] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៤៤ កថាខណ្ឌទី១។

[260] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៣៦ កថាខណ្ឌទី៤ និងមាត្រា៣៤៤ កថាខណ្ឌទី២។

[261] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៤៦។

[262] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៨៩។

[263] សេង នាង, *សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំ*, (ភ្នំពេញ៖ រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ), ៦។

អាជ្ញាសាលាអនុវត្តដោយបង្ខំភាគច្រើនធ្វើសកម្មភាពជាក់ស្តែងនៅទីតាំង ដូចជា ការអនុវត្តការលក់អចលនវត្ថុ ការប្រគល់អចលនវត្ថុ ការរឹបអូសចលនវត្ថុ។ ប្រសិនបើម្ចាស់បំណុលមានតែម្នាក់ ឬច្រើននាក់ហើយប្រាក់ដែលបានមកពីការលក់ចលនវត្ថុដែលរឹបអូស ឬប្រាក់ដែលរឹបអូសអាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និងសោហ៊ុយសម្រាប់នីតិវិធីក្នុងការអនុវត្តទាំងអស់បាន អាជ្ញាសាលាត្រូវបែងចែកចំណែកឱ្យទៅម្ចាស់បំណុលនីមួយៗទៅតាមសិទ្ធិលើបំណុលរបស់ពួកគេ។[264] ចំពោះប្រាក់ដែល នៅសេសសល់ត្រូវប្រគល់ឱ្យទៅកូនបំណុលនៃការអនុវត្តវិញ។[265] ក្នុងករណីបើប្រាក់ដែលបានមកពីការលក់ចលនវត្ថុដែលរឹបអូស ឬប្រាក់ដែលបានរឹបអូស មិនអាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ អាជ្ញាសាលាត្រូវកំណត់ថ្ងៃណាមួយ ក្នុងអំឡុងពេល ២(ពីរ)សប្តាហ៍ ដើម្បីពិភាក្សាអំពីការចែកចំណែកនៃប្រាក់ដែលបានមកពីការលក់ ឬប្រាក់ដែលបានពីការរឹបអូស ហើយត្រូវជូនដំណឹងពីពេលវេលា និងទីកន្លែងទៅម្ចាស់បំណុលនីមួយៗ។[266] បើការពិភាក្សារវាងម្ចាស់បំណុលទាំងអស់ មានការស្រុះស្រួលឯកភាពគ្នាដាច់ស្រេចហើយ អាជ្ញាសាលាត្រូវធ្វើការបែងចែកចំណែកតាមការព្រមព្រៀងរបស់ម្ចាស់បំណុលនីមួយៗ។[267] ទោះបីជាការពិភាក្សាអាចធ្វើទៅបាន អាជ្ញាសាលាមិនអាចធ្វើការបែងចែកចំណែកទេ ប្រសិនបើម្ចាស់បំណុលមិនបានបង្ហាញខ្លួនមកទទួលចំណែក។ ក្នុងករណីនេះអាជ្ញាសាលាត្រូវធ្វើ ទុកនូវទឹកប្រាក់ស្មើនឹងចំណែកចំពោះម្ចាស់បំណុល នៅសាលាដំបូងដែលខ្លួនស្ថិតនៅ។[268]

ការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ចំពោះអចលនវត្ថុ គឺជាសមត្ថកិច្ចផ្តាច់មុខរបស់តុលាការអនុវត្ត ហើយជាធម្មតាអចលនវត្ថុមានតម្លៃខ្ពស់ និងអាចមានម្ចាស់សិទ្ធិជាច្រើនពាក់ព័ន្ធនឹងវត្ថុនោះ ហេតុនេះត្រូវបង្កើតយន្តការមួយដែលសមស្របសម្រាប់គ្រប់គ្រងភាពស្មុគស្មាញនៃការអនុវត្តសិទ្ធិទាំងនេះ។

[264] ក្រុមការងារគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, "សិក្ខាសាលាគណៈមេធាវី(ធំ) លើកទី៩, ប្រធានបទ៖ នីតិវិធីអនុវត្តដោយបង្ខំ, ០៧ ឧសភា ២០១៥", នៅក្នុង *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA), វិច្ឆិកា ២០១៦), ១១៧។

[265] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៩៩ កថាខណ្ឌទី១។

[266] ក្រុមការងារគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, "សិក្ខាសាលាគណៈមេធាវី(ធំ) លើកទី៩, ប្រធានបទ៖ នីតិវិធីអនុវត្តដោយបង្ខំ, ០៧ ឧសភា ២០១៥", នៅក្នុង *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA), វិច្ឆិកា ២០១៦), ១១៧។

[267] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៩៩ កថាខណ្ឌទី២។

[268] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤០០ កថាខណ្ឌទី២។

នៅពេលដាក់ពាក្យសុំអនុវត្តដោយបង្ខំ ត្រូវភ្ជាប់នូវឯកសារនានាដែលជាលក្ខខណ្ឌគោល ដូចជាលិខិតអនុវត្ត រូបមន្តអនុវត្ត ឯកសារបញ្ជាក់អត្តសញ្ញាណអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត ដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ឬរបស់អ្នកធានាដោយវត្ថុ។[269]

ដើម្បីអនុវត្ត និងសម្រេចសិទ្ធិទាំងនេះ យន្តការគាំទ្រគឺ ទី១(មួយ) នីតិវិធីរឹបអូស ទី២(ពីរ) នីតិវិធីលក់ និង ទី៣(បី) នីតិវិធីចែកចំណែក គឺជាយន្តការអនុវត្តសិទ្ធិ តាមរយៈការរឹបអូសដើម្បីលក់ប្តូរជាប្រាក់ ហើយយកប្រាក់នោះទៅទូទាត់ជាមួយនឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលត្រូវបានសម្រេចសេចក្តីជាស្ថាពរក្នុងសាលក្រម ឬសាលដីការបស់តុលាការអង្គសេចក្តី ដែលជាលទ្ធផលនៃការអនុវត្តសិទ្ធិស្ថាពរឱ្យបានសម្រេចជាលក្ខណៈសត្យានុម័ត។[270]

បន្ទាប់ពីទទួលបាននូវពាក្យសុំអនុវត្តដោយបង្ខំ អាជ្ញាសាលាត្រូវសម្រេចអំពីកាលបរិច្ឆេទនៃការចុះអនុវត្តរឹបអូស ហើយអាជ្ញាសាលាជូនដំណឹងពីកាលបរិច្ឆេទនោះ ទៅម្ចាស់បំណុលនៃការអនុវត្ត ព្រោះម្ចាស់បំណុលនៃការអនុវត្តអាចចង់ទៅទីកន្លែងនៃចលនវត្ថុដែលត្រូវរឹបអូសជាមួយនឹងអាជ្ញាសាលា។ អាជ្ញាសាលាមិនជូនដំណឹងទៅកូនបំណុលនៃការអនុវត្តឡើយ ព្រោះកូនបំណុលនៃការអនុវត្តអាចលាក់ទុកចលនវត្ថុដែលត្រូវរឹបអូសនោះ។ នៅពេលចុះទៅដល់កន្លែងអនុវត្តបើជួបកូនបំណុលនៃការអនុវត្ត អាជ្ញាសាលាត្រូវដាស់តឿនឱ្យកូនបំណុលនៃការអនុវត្តនោះសងបំណុលដោយស្ម័គ្រចិត្តនៅមុនពេលចាប់ផ្តើមរឹបអូស អាជ្ញាសាលាអាចទទួលសំណងនៃបំណុល និងសោហ៊ុយសម្រាប់ការអនុវត្តសម្រាប់ម្ចាស់បំណុលនៃការអនុវត្តបាន។[271]

អាជ្ញាសាលាត្រូវលុបចោលការរឹបអូស បើប៉ាន់ប្រមាណឃើញថាប្រាក់ដែលបានមកពីការលក់ចលនវត្ថុដែលត្រូវរឹបអូសនោះ គ្មានចំនួនសេសសល់ក្រោយពីសងសិទ្ធិលើបំណុលដែល មានអាទិភាពជាងសិទ្ធិលើ

---

[269] ក្រុមការងារគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, "សិក្ខាសាលាគណៈមេធាវី(ធំ) លើកទី៩, ប្រធានបទ៖ នីតិវិធីអនុវត្តដោយបង្ខំ, ០៧ ឧសភា ២០១៥", នៅក្នុង *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA), វិច្ឆិកា ២០១៦), ១១៩។

[270] ក្រុមការងារគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, "សិក្ខាសាលាគណៈមេធាវី(ធំ) លើកទី៩, ប្រធានបទ៖ នីតិវិធីអនុវត្តដោយបង្ខំ, ០៧ ឧសភា ២០១៥", នៅក្នុង *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA), វិច្ឆិកា ២០១៦), ១១៩។

[271] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៨៤។

បំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយសម្រាប់នីតិវិធី។[272] អាជ្ញាសាលាអាចលុបចោលការរឹបអូសចលនវត្ថុ ដែលបានរឹបអូសរួចហើយបានប្រសិនបើបានអនុវត្តការលក់តាមនីតិវិធីសមរម្យហើយ នៅតែមិនអាចលក់ចលនវត្ថុដែលរឹបអូសនោះបាន ហើយប៉ាន់ប្រមាណឃើញថានៅតែមិនអាចលក់បាននៅពេលអនាគត។[273]

នៅពេលតុលាការអនុវត្តបានទទួលពាក្យសុំអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុលនៃការអនុវត្តដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ តុលាការអនុវត្តនឹងចេញដីកាសម្រេចបានផ្ដើមការលក់ដោយបង្ខំ ដោយចង្អុលបង្ហាញអំពីភាគីនៃសំណុំរឿងអនុវត្ត កម្មវត្ថុនៃការអនុវត្តប្រកាសអំពីការរឹបអូសអចលនវត្ថុនោះ ហើយបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត។[274] ជាគោលការណ៍អានុភាពនៃការរឹបអូស កើតឡើងនៅពេលដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំត្រូវបានបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត ប៉ុន្តែប្រសិនបើការចុះបញ្ជីអំពីការរឹបអូសត្រូវបានធ្វើឡើងមុនពេលបញ្ជូនដីកាសម្រេច នោះការរឹបអូសបង្កើតអានុភាពនៅពេលចុះបញ្ជី ហើយដីកាសម្រេចនេះ គប្បីបញ្ជូនទៅកូនបំណុលនៃការអនុវត្តបន្ទាប់ពីចុះបញ្ជីរឹបអូស ដើម្បីកុំឱ្យកូនបំណុលនៃការអនុវត្ត មានឱកាសធ្វើអនុប្បទានទៅតតិយជន។ អានុភាពចម្បងនៃការរឹបអូស គឺហាមឃាត់កូនបំណុលនៃការអនុវត្តមិនឱ្យចាត់ចែង ហើយអាជ្ញាធរមានសមត្ថកិច្ចជាអ្នកមានសិទ្ធិចាត់ចែង។ នៅពេលការរឹបអូសបង្កើតអានុភាព កូនបំណុលនៃការអនុវត្តអាចប្រើប្រាស់អចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសបាន តាមវិធីប្រើប្រាស់ធម្មតា។[275]

ការលក់ត្រូវធ្វើឡើងដោយតុលាការអនុវត្ត ក្នុងនាមអ្នកមានសិទ្ធិចាត់ចែងដែលបានទទួលតាមរយៈអានុភាពនៃការរឹបអូស ហេតុនេះការលក់ឡាយឡុងតាមផ្លូវតុលាការគឺជានីតិវិធីប្រកាសឱ្យអ្នកស្នើសុំទិញមកទិញវត្ថុនេះ ដោយកំណត់បុគ្គលណាម្នាក់ក្នុងចំណោមបុគ្គលទាំងនោះ ឱ្យក្លាយជាអ្នកទិញ រីឯដីកាសម្រេចអនុញ្ញាតឱ្យលក់ ចាត់ទុកជាការបង្ហាញឆន្ទៈរបស់តុលាការអនុវត្តក្នុងនាមអ្នកលក់ចំពោះអ្នកទិញ ហើយចំពោះតម្លៃលក់វិញ គឺផ្អែកលើរបាយការណ៍របស់អ្នកវាយតម្លៃដែលត្រូវបានចាត់តាំងដោយតុលាការ និងបន្ទាប់ពីបានតម្លៃលក់នោះមក តុលាការអនុវត្តពិចារណាអំពីផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ដោយប្រើ

---

[272] ក្រុមការងារគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, "សិក្ខាសាលាគណៈមេធាវី(ធំ) លើកទី៩, ប្រធានបទ៖ នីតិវិធីអនុវត្តដោយបង្ខំ, ០៧ ឧសភា ២០១៥", នៅក្នុង *មេរៀនស្ដីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA), វិច្ឆិកា ២០១៦), ១១៥។

[273] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៩៣។

[274] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤១៩។

[275] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤២១ កថាខណ្ឌទី៣។

មូលដ្ឋាននៃតម្លៃលក់ ក្នុងការកំណត់តម្លៃលក់អប្បបរមា ហេតុនេះតម្លៃលក់នេះមិនមែនជាតម្លៃទីផ្សារនោះទេ គឺជាតម្លៃលក់ឡាយឡុងតាមផ្លូវតុលាការ ដោយធ្វើយ៉ាងណាឱ្យមានភាពឆាប់រហ័ស នាំឱ្យតុលាការអនុវត្តពិចារណាផលប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ខ្ពស់ជាងផលប្រយោជន៍របស់កូនបំណុលនៃការអនុវត្ត។[276]

## ៣.៣. គុណប្រយោជន៍នៃបញ្ញត្តិស្តីពីនីតិវិធីដាស់តឿន

សង្គមមនុស្សមានការរីកចម្រើនជានិច្ច ហើយកាន់តែមានភាពស្មុគស្មាញ និងទាមទារឱ្យមាននីតិវិធីសង្គ្រោះសិទ្ធិរបស់ម្ចាស់បំណុលប្រកបដោយភាពឆាប់រហ័ស និងទាន់ពេលវេលា។ ប៉ុន្តែ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ត្រូវតែមានវិធានបញ្ញត្តិដើម្បីការពារផលប្រយោជន៍របស់ភាគីម្ខាងទៀតផងដែរ។

នីតិវិធីដាស់តឿន គឺជាបទបញ្ញត្តិដែលមានលក្ខណៈថ្មីស្រឡាង ដែលមិនធ្លាប់ត្រូវបានបទដ្ឋានគតិយុត្តណាមួយសម្រាប់ដោះស្រាយបណ្តឹងរដ្ឋប្បវេណីឡើយ។ នីតិវិធីនេះត្រូវបានបង្កើតឡើង ដើម្បីសម្រេចចំពោះពាក្យសុំរបស់ម្ចាស់បំណុលចំពោះកូនបំណុល នូវការទាមទារដែលមានគោលបំណងឱ្យសងប្រាក់ ហើយដែលអត្ថិភាពនៃអង្គហេតុនៃការបង្កើតសិទ្ធិ មិនមានវិវាទរវាងម្ចាស់បំណុល និងកូនបំណុល។

នីតិវិធីនេះអាចធ្វើឱ្យម្ចាស់បំណុលអាចទទួលបាននូវដីកាសម្រេចដាស់តឿនមួយ ដែលជាលិខិតអនុវត្តនៅពេលដែលដីកានេះចូលជាស្ថាពរ ដែលផ្តល់ផលប្រយោជន៍ខាងសេដ្ឋកិច្ចនៃបណ្តឹង និងធ្វើឱ្យសិទ្ធិរបស់ម្ចាស់បំណុលត្រូវបានការពារ និងអាចទទួលបានមកវិញដោយឆាប់រហ័ស។[277]

---

[276] ក្រុមការងារគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, "សិក្ខាសាលាគណៈមេធាវី(ធំ) លើកទី៩, ប្រធានបទ៖ នីតិវិធីអនុវត្តដោយបង្ខំ, ០៧ ឧសភា ២០១៥", នៅក្នុង *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA), វិច្ឆិកា ២០១៦),១២២។

[277] ហ៊ី សោភា, *នីតិវិធីរដ្ឋប្បវេណី,* (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច), ១១៧។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្វែងយល់ និងការស្រាវជ្រាវកន្លងមកយើងខ្ញុំទាំងពីររូបយល់ឃើញថា ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ជាគោលការណ៍នៅពេលដែលមានវិវាទកើតភាគីត្រូវធ្វើបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ច ហើយតុលាការនឹងដោះស្រាយបណ្តឹងតាមនីតិវិធីនៃការជំនុំជម្រះលើកទី១ ដែលហៅថានីតិវិធីបណ្តឹងធម្មតា មានដំណាក់កាលជាច្រើនដូចជា ដំណាក់កាលដាក់ពាក្យបណ្តឹង ដំណាក់កាលត្រៀមសម្រាប់ទាញហេតុផលផ្ទាល់មាត់ ដំណាក់កាលទាញហេតុផលដោយផ្ទាល់មាត់ និងចុងក្រោយនោះគឺដំណាក់កាលសម្រេចសេចក្តី។ ក៏ប៉ុន្តែនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីក៏បានចែងបញ្ញត្តិមួយចំនួនដែលផ្តល់ឱ្យម្ចាស់បំណុលនូវភាពងាយស្រួល ឆាប់រហ័ស ចំណាយថវិកាតិច និងយុត្តិធម៌ ហើយទទួលបាននូវលិខិតអនុវត្តដែលចាំបាច់ក្នុងការអនុវត្តដោយបង្ខំ ចំពោះការទាមទារដែលមានគោលបំណងសងជាប្រាក់នោះ គឺជានីតិវិធីដាស់តឿន។

ដើម្បីអនុវត្តនីតិវិធីដាស់តឿនបាន តម្រូវឱ្យគោរពនូវលក្ខខណ្ឌមួយចំនួនដូចជា ការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ត្រូវតែជាការទាមទារដែលមានមូលហេតុច្បាស់លាស់ ហើយការទាមទារនោះធ្វើទៅតុលាការដែលមានសមត្ថកិច្ច និងអាចធ្វើការបញ្ជូនដីកាសម្រេចដាស់តឿនក្នុងរង្វង់នៃដែនដីនៃព្រះរាជាណា-ចក្រកម្ពុជា ហើយហាមដាច់ខាត់ក្នុងការបញ្ជូនដីកាសម្រេចដាស់តឿនតាមរយៈការផ្សាយជាសាធារណៈ។ តុលាការដែលមានសមត្ថកិច្ចចំពោះនីតិវិធីដាស់តឿន គឺជាតុលាការដែលមានសមត្ថកិច្ចផ្តាច់មុខ ដែលភាគីអ្នកដាក់ពាក្យសុំអាចដាក់ពាក្យសុំបាន ទៅតុលាការនៃលំនៅឋានរបស់កូនបំណុល ឬទៅតុលាការនៃកន្លែងអនុវត្តកាតព្វកិច្ច។

ក្រោយពេលដែលម្ចាស់បំណុលបានដាក់ពាក្យសុំទៅតុលាការដែលមានសមត្ថកិច្ចឱ្យចេញដីកាសម្រេចដាស់តឿនរួចមក តុលាការនឹងធ្វើការពិនិត្យលើពាក្យសុំនោះតើត្រឹមត្រូវតាមច្បាប់ដែរទេ។ ក្នុងករណីដែលតុលាការពិនិត្យឃើញថាពាក្យសុំមិនមានលក្ខណៈត្រឹមត្រូវ ឬមិនបានបំពេញនូវលក្ខខណ្ឌឱ្យបានគ្រប់គ្រាន់ តុលាការនឹងធ្វើសេចក្តីបង្គាប់ឱ្យកែប្រែ ឬក៏អាចលើកចោលពាក្យសុំនោះចោលតែម្តង។ ប្រសិនបើពាក្យសុំនោះត្រឹមត្រូវតាមច្បាប់ និងលក្ខខណ្ឌ ជាអាទិ៍ តុលាការនឹងចេញនូវដីកាសម្រេចដាស់តឿន ដោយមិនចាំបាច់ជូនដំណឹងអំពីការដាក់ពាក្យសុំទៅកាន់កូនបំណុលឡើយ។ បន្ទាប់ពីតុលាការចេញដីកាសម្រេចដាស់តឿនរួចមក តុលាការនឹងធ្វើការជូនដំណឹងអំពីដីកានេះទៅម្ចាស់បំណុល ហើយនឹងធ្វើការបញ្ជូនដីកាសម្រេចដាស់តឿនទៅកូនបំណុល។ បើទោះបីជាតុលាការបានចេញដីកាសម្រេចដាស់តឿនរួចរាល់ហើយក៏ដោយ ក៏ច្បាប់បានផ្តល់សិទ្ធិឱ្យភាគីខាងកូនបំណុលប្តឹងតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលតុលាការបានបញ្ជូនមកខ្លួនបាន។

ការប្តឹងតវ៉ាចំពោះដីកាសម្រេចដាស់តឿននេះអាចធ្វើបាន ២ ដំណាក់កាល។ កូនបំណុលអាចប្តឹងតវ៉ាចំពោះដីកាសម្រេចដាស់តឿននូវមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដែលទុករយៈពេល ២ សប្តាហ៍ គិតចាប់ពីថ្ងៃដែលកូនបំណុលបានទទួលដីកាសម្រេចដាស់តឿន។ ប្រសិនបើការប្តឹងតវ៉ារបស់កូនបំណុលចំពោះដីកាសម្រេចដាស់តឿន តុលាការយល់ឃើញថាមានមូលហេតុត្រឹមត្រូវ និងស្របច្បាប់នោះ នាំឱ្យអានុភាពនៃការប្តឹងតវ៉ានឹងធ្វើឱ្យមានការផ្លាស់ប្តូរនូវនីតិវិធីក្នុងការសម្រេចសេចក្តី ពីការសម្រេចសេចក្តីតាមនីតិវិធីដាស់តឿនទៅជាការសម្រេចសេចក្តីតាមនីតិវិធីបណ្តឹងធម្មតាវិញ ដែលសេចក្តីតាមដំណាក់កាលនីមួយៗដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ ហើយការសម្រេចសេចក្តីរបស់តុលាការ នឹងធ្វើការវិនិច្ឆ័យដែលផ្អែកលើអង្គហេតុ និងអង្គច្បាប់ ដោយបង្ហាញនូវអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិលើបំណុលរបស់ភាគីម្ចាស់បំណុលនៃការទាមទារ។ ក៏ប៉ុន្តែ ប្រសិនបើពាក្យសុំតវ៉ានោះតុលាការយល់ឃើញថាមិនត្រឹមត្រូវ ឬមិនស្របច្បាប់នោះ តុលាការនឹងចេញដីកាសម្រេចលើកចោលពាក្យសុំតវ៉ានោះចោល។

ក្រោយរយៈពេល២(ពីរ)សប្តាហ៍ បើកូនបំណុលមិនធ្វើការតវ៉ាចំពោះដីកាសម្រេចដាស់តឿនទេ តុលាការនឹងចេញដីកាសម្រេចដាស់តឿនដោយភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ហើយក្រោយការប្រកាសនេះម្ចាស់បំណុលអាចដាក់ពាក្យសុំអនុវត្តមុនដីកាសម្រេចដាស់តឿនចូលជាស្ថាពរបាន ព្រោះថាដីកាសម្រេចដាស់តឿនដែលភ្ជាប់ការអនុវត្តជាបណ្តោះអាសន្ន គឺជាលិខិតអនុវត្ត។ ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននេះ ក្រមនីតិវិធីរដ្ឋប្បវេណីបានបើកសិទ្ធិឱ្យកូនបំណុលម្តងទៀតក្នុងការប្តឹងតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់នឹងប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដែលមានរយៈពេល២(ពីរ)សប្តាហ៍ គិតចាប់ពីថ្ងៃដែលកូនបំណុលបានទទួលនូវការបញ្ជូនដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយការប្រកាសការអនុវត្តជាបណ្តោះអាសន្ន។ ប្រសិនបើកូនបំណុលដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននោះ តុលាការយល់ឃើញថាមិនត្រឹមត្រូវ តុលាការនឹងចេញដីកាសម្រេចលើកចោលពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននោះ ហើយចំពោះដីកាសម្រេចលើកចោលពាក្យសុំតវ៉ារបស់កូនបំណុល កូនបំណុលមានសិទ្ធិប្តឹងតវ៉ាចំពោះនឹងដីកាសម្រេចលើកចោលពាក្យសុំតវ៉ារបស់កូនបំណុលចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយការអនុវត្តជាបណ្តោះអាសន្នបាន ដែលធ្វើទៅតុលាការជាន់ខ្ពស់។ ក៏ប៉ុន្តែ បើតុលាការយល់ឃើញថាពាក្យសុំតវ៉ារបស់កូនបំណុលចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ស្របច្បាប់ នោះនីតិវិធីដាស់តឿន ត្រូវផ្ទេរទៅនីតិវិធីបណ្តឹងធម្មតាវិញ ហើយការផ្ទេរនីតិវិធីនេះដែរមិនបានធ្វើឱ្យបាត់បង់អានុភាពនៃ ដីកាសម្រេចដាស់តឿនដែលភ្ជាប់នូវការប្រកាសជាបណ្តោះអាសន្នឡើយ។ ចំពោះការប្តូរពីនីតិវិធីដាស់តឿន ទៅនីតិវិធីបណ្តឹងធម្មតានេះ តុលាការនៃនីតិវិធី

បណ្ដឹងធម្មតា នឹងធ្វើការវិនិច្ឆ័យ និងសម្រេចសេចក្ដីបញ្ជាក់អំពី អត្ថិភាព ឬនត្ថិភាព នៃដីកាសម្រេចដាស់តឿន ពោលគឺតុលាការនឹងចេញនូវសាលក្រមបញ្ជាក់ ពីភាពត្រឹមត្រូវរបស់ដីកាសម្រេចដាស់តឿន ឬបង្ហាញពីការមិនត្រឹមត្រូវនៃដីកាសម្រេចដាស់តឿន។

ចំពោះសិទ្ធិប្ដឹងតវ៉ាចំពោះដីកាសម្រេចដាស់តឿនរបស់កូនបំណុលអាចអនុវត្តសិទ្ធិរបស់ខ្លួនបានចំពោះការតវ៉ាចំពោះដីកាសម្រេចដាស់តឿនមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន និងការតវ៉ាចំពោះដីកាសម្រេចដាស់តឿនក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន។ ចំពោះនីតិវិធីបណ្ដឹងធម្មតាដែលត្រូវបានផ្ទេរពីនីតិវិធីដាស់តឿន តាមរយៈការតវ៉ាចំពោះដីកាសម្រេចដាស់តឿនមុនការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន តុលាការនៃនីតិវិធីបណ្ដឹងនឹងធ្វើការវិនិច្ឆ័យទៅលើអង្គហេតុ និងអង្គច្បាប់ ដោយចេញសាលក្រមបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិលើបំណុល។ ចំណែកឯ នីតិវិធីបណ្ដឹងធម្មតាដែលត្រូវបានផ្ទេរពីនីតិវិធីដាស់តឿនតាមរយៈការតវ៉ាចំពោះដីកាសម្រេចដាស់តឿន ក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន តុលាការនៃនីតិវិធីចំពោះដីកាសម្រេចដាស់តឿន ក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន តុលាការនៃនីតិវិធីបណ្ដឹងធម្មតា នឹងធ្វើការវិនិច្ឆ័យ និងចេញសាលក្រមបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃដីកាសម្រេចដាស់តឿន។ ការដាក់ពាក្យសុំតវ៉ា មិនប្រាកដថាសុទ្ធតែតុលាការទទួលយកទាំងអស់នោះទេពោលគឺ ប្រសិនបើតុលាការយល់ឃើញថាពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនមិនត្រឹមត្រូវតាមច្បាប់ទេ តុលាការនឹងលើកពាក្យសុំតវ៉ានោះចោល ដោយដីកាសម្រេច។ បើទោះបីជាតុលាការលើកចោលពាក្យសុំតវ៉ានោះក៏ដោយ ក៏ច្បាប់បានផ្ដល់សិទ្ធិឱ្យកូនបំណុលផងដែរក្នុងការប្ដឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ក្នុងអំឡុងពេល ១(មួយ)សប្ដាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលដំណឹងពីដីកាសម្រេច។ ចំណែកឯ តុលាការដែលមានសមត្ថកិច្ចក្នុងការវិនិច្ឆ័យលើបណ្ដឹងជំទាស់ គឺជាតុលាការនៃបណ្ដឹងជំទាស់(សាលាឧទ្ធរណ៍) ដែលសម្រេចសេចក្ដីដោយដីកាសម្រេចលើបណ្ដឹងជំទាស់ ហើយដីកាសម្រេចបណ្ដឹងជំទាស់នេះដែរ មិនអាចប្ដឹងជំទាស់ទៀតបានឡើយ។

សរុបសេចក្ដីមក នីតិវិធីដាស់តឿនជានីតិវិធីដែលខ្លី និងល្អប្រសើរមួយ ប្រសិនបើពុំមានការប្ដឹងតវ៉ាពីកូនបំណុលដូចបានរៀបរាប់ខាងលើទេ នោះត្រឹមតែរយៈពេល៤(បួន)សប្ដាហ៍ប៉ុណ្ណោះ ម្ចាស់បំណុលអាចទទួលបានដីកាសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នចូលជាស្ថាពរ។ ហើយដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននេះដែរ មានអានុភាពដូចសាលក្រមស្ថាពរដែរ ហើយដីកាសម្រេចដាស់តឿនក្លាយជាលិខិតអនុវត្ត ដែលអាចឱ្យម្ចាស់បំណុលយកលិខិតអនុវត្តនេះ ទៅស្នើសុំឱ្យមានចំណាត់ការលើការអនុវត្តនៃដីកាសម្រេចដាស់តឿន តាមរយៈនីតិវិធីអនុវត្តដោយបង្ខំបាន។

# អនុសាសន៍

# អនុសាសន៍

នីតិវិធីដាស់តឿន ជានីតិវិធីមួយដែលមានលក្ខណៈខ្លី ងាយស្រួល ចំណេញពេលវេលា និងថវិកា។ បណ្តឹងរដ្ឋប្បវេណី មានប្រភេទបណ្តឹងធម្មតា និងបណ្តឹងពិសេស។ បណ្តឹងធម្មតា ត្រូវឆ្លងកាត់តាមនីតិវិធីបណ្តឹងធម្មតា មានការជំនុំជម្រះលើកទីមួយជាដើមហើយបណ្តឹងពិសេស មានលក្ខណៈពិសេស ងាយស្រួលជាងបណ្តឹងធម្មតា។ ប៉ុន្តែភាពងាយស្រួលនេះ ក៏បង្កជាគុណវិបត្តិមួយផងដែរ ដែលអ្នកអនុវត្តច្បាប់ភាគច្រើនហាក់មិនអនុវត្តនីតិវិធីដាស់តឿនមួយនេះទូលំទូលាយទេ។

គុណវិបត្តិនៃនីតិវិធីដាស់តឿននេះ មានលទ្ធភាពខ្ពស់ក្នុងការផ្ទេរមួយផ្នែក ឬទាំងស្រុងទៅជានីតិវិធីបណ្តឹងធម្មតា ប្រសិនបើពាក្យ "ការតវ៉ាស្របច្បាប់" ពុំត្រូវបានបកស្រាយក្នុងលក្ខណៈត្រឹមត្រូវ។ ពាក្យសុំតវ៉ាស្របច្បាប់ចំពោះដីកាសម្រេចដាស់តឿន នៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ក្នុងករណីនេះប្រសិនបើការតវ៉ានោះស្របច្បាប់ទាំងស្រុង នោះដីកាសម្រេចដាស់តឿននឹងបាត់បង់អានុភាពទាំងមូល តែបើការតវ៉ានោះលុបចោលបានតែមួយផ្នែកណាមួយនៃដីកាសម្រេចដាស់តឿន នោះផ្នែកដែលការតវ៉ាបានជោគជ័យនឹងត្រូវបង្វិលទៅជានីតិវិធីបណ្តឹងធម្មតា។ មួយវិញទៀត ការផ្ទេរនីតិវិធីដាស់តឿននឹងផ្ទេរទៅនីតិវិធីនៃបណ្តឹងប្រសិនបើមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ហើយតុលាការពិនិត្យឃើញថាស្របច្បាប់ នោះការទាមទារដែលទាក់ទងនឹងការតវ៉ាចំពោះដីកាសម្រេចដាស់តឿនរបស់កូនបំណុល ត្រូវចាត់ទុកថាបានដាក់ពាក្យបណ្តឹងទៅតុលាការដែលបានចេញដីកាសម្រេចដាស់តឿននោះ នៅពេលដែលមានពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន។ ការណ៍នេះហាក់ការពារសិទ្ធិស្មើគ្នា ដើម្បីកុំឱ្យមានការបំពានសិទ្ធិណាមួយកើតឡើង ប៉ុន្តែហាក់មានការពារលើកូនបំណុលច្រើនជាង ព្រោះកាលណាមានការដាក់ពាក្យស្នើសុំពីម្ចាស់បំណុល នោះកូនបំណុលភាគច្រើនត្រូវតែដាក់ពាក្យតវ៉ា។

ជាទីបញ្ចប់ ក្នុងនាមជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រមួយរូប ស្នើសុំដល់ប្រជាពលរដ្ឋ ពិសេសអ្នកអនុវត្តច្បាប់ក្នុងកិច្ចការរដ្ឋប្បវេណី ក្នុងការអនុវត្តនីតិវធីដាស់តឿននេះឱ្យមានភាពទូលំទូលាយព្រោះវាមានភាពរហ័ស និងជួយពន្លឿនកុំឱ្យមានការកកស្ទះសំណុំរឿងតាមសាលាជម្រះក្តី។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។
- ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
- ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់, នស/រកម/១០០៥/០៣០, ១៥ វិច្ឆិកា ២០០៥។

## ២. វចនានុក្រម

- ជួន ណាត. វចនានុក្រមខ្មែរ. ភ្នំពេញ៖ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧។
- សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ. វចនានុក្រមច្បាប់តាមបទដ្ឋានគតិយុត្តខ្មែរ. បោះពុម្ពលើកទី៣. ភ្នំពេញ៖ មករា ២០១៨។

## ៣. សៀវភៅ

- ក្រសួងយុត្តិធម៌. *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី. ភាគ១*, បោះពុម្ពលើកទី១. ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), ធ្នូ ២០១៥។
- ក្រសួងយុត្តិធម៌. *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី. ភាគ២*, បោះពុម្ពលើកទី១. ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), វិច្ឆិកា ២០១៦។
- ក្រសួងយុត្តិធម៌. *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី. ភាគ៣*, បោះពុម្ពលើកទី១. ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), មីនា ២០១៧។
- ក្រុមការងារក្រសួងយុត្តិធម៌. ប្រធានបទ៖ ការតំណាង, វិច្ឆិកា ២០១៦. នៅក្នុង *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី. ភាគ២*, បោះពុម្ពលើកទី១. ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), វិច្ឆិកា ២០១៦។

- ក្រុមការងារគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា. "សិក្ខាសាលាគណៈមេធាវី(ធំ) លើកទី១០, ប្រធានបទ៖ អង្គហេតុចម្បង និងការសរសេរពាក្យបណ្ដឹង, ២០ សីហា ២០១៥". នៅក្នុង *មេរៀនស្ដីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី. ភាគ២,* បោះពុម្ពលើកទី១. ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), វិច្ឆិកា ២០១៦។
- ក្រុមការងារគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា. "សិក្ខាសាលាគណៈមេធាវី(ធំ) លើកទី៩, ប្រធានបទ៖ នីតិវិធីអនុវត្តដោយបង្ខំ, ០៧ ឧសភា ២០១៥". នៅក្នុង *មេរៀនស្ដីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី. ភាគ២,* បោះពុម្ពលើកទី១. ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA), វិច្ឆិកា ២០១៦។
- ក្រុមការងារគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា. សិក្ខាសាលាគណៈមេធាវី(តូច) លើកទី១៤, ប្រធានបទ៖ នីតិវិធីដាស់តឿន, ១៦ កុម្ភៈ ២០១៧. នៅក្នុង *មេរៀនស្ដីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី. ភាគ៣*, បោះពុម្ពលើកទី១. ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), មីនា ២០១៧។
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. *សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី*. ភាគ១, *នីតិវិធីបណ្ដឹង*. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩។
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. *សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី*. ភាគ២, *ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ*. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩។
- ក្រុមការងារនៃអនាគតគ្រូបណ្ដុះបណ្ដាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ. *សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណីភាគ១*. ការកែសម្រួលលើការបោះពុម្ពលើកទី១. ភ្នំពេញ៖ មេសា ២០១៣។
- ក្រុមការងាររាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ. "សិក្ខាសាលាស្ដីពីនីតិវិធីនៃការបញ្ជូន, ធ្នូ ២០១៤". នៅក្នុង *មេរៀនស្ដីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី. ភាគ២,* បោះពុម្ពលើកទី១.

ភ្នំពេញ៖ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), វិច្ឆិកា ២០១៦។

- ក្រុមការងាររាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ. "កម្រងករណីសិក្សា និងសំណួរចម្លើយអំពីការអនុវត្តជាក់ស្តែងទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, កក្កដា ២០១២ ដល់ ធ្នូ ២០១៣". នៅក្នុង *មេរៀនស្តីពី ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី. ភាគ១,* បោះពុម្ពលើកទី១. ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី៤ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), ធ្នូ ២០១៥។

- គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី. *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី*. ភាគ១, គន្ថី១-ទី៣. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩។

- គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់. *សន្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពី សន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី*. ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧។

- ងួន រតនា ចៅក្រមសាលាឧទ្ធរណ៍. *នីតិវិធីដាស់តឿន*. ភ្នំពេញ៖ សាលាភូមិន្ទក្រឡាបញ្ជី។

- សេង នាង. *សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំ*. ភ្នំពេញ៖ រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ។

- ហាប់ ផល្ញី. វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា. បោះពុម្ពលើកទី៣. ភ្នំពេញ៖ ព្រៃមៀមអ៊ែតវើថាយស៊ីង, ២០២១។

- ហេង សុខណា ចៅក្រមសាលាឧទ្ធរណ៍បាត់ដំបង និងជាគ្រូបណ្តុះបណ្តាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ. *នីតិវិធីនៃការបញ្ជូន*. ភ្នំពេញ៖ រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ។

- ហ៊ី សោភា. *នីតិវិធីរដ្ឋប្បវេណី*. ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

- អ៊ីវ ប៉ូលី. *ក្រមនីតិវិធីរដ្ឋប្បវេណី. មេរៀនទី២អំពី សមត្ថកិច្ចសាលាជម្រះក្តី*. ភ្នំពេញ៖ វគ្គបណ្តុះបណ្តាលវិភាគទានច្បាប់ជំនាន់ទី៧, ២០២៣។

- អ៊ីវ ប៉ូលី. *មេរៀនសង្ខេបស្តីពីនីតិវិធីរដ្ឋប្បវេណី*. ភ្នំពេញ, ២០១០។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធគតិយុត្ត

**ឧបសម្ព័ន្ធទី១៖** គំរូដីកាសម្រេចដាស់តឿន

**ឧបសម្ព័ន្ធទី២៖** គំរូដីកាសម្រេចលើកចោលពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន

**ឧបសម្ព័ន្ធទី៣៖** រូបមន្តអនុវត្តសាលក្រម

## ២. ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១៖** គំនូស និងការសង្ខេបពីលំហូរនីតិវិធីដាស់តឿន

# ឧបសម្ព័ន្ធគតិយុត្ត

# គំរូ

# ដីកាសម្រេចដាស់តឿន

# <u>ដីកាសម្រេចដាស់តឿន</u>

យើង ................. ជាចៅក្រមនៃសាលាដំបូង... ។

**បានឃើញ** មាត្រា៣២០, មាត្រា៣២៣, មាត្រា ៣២៤ និងមាត្រាពាក់ព័ន្ធផ្សេងទៀតនៃក្រមនីតិវិធីរដ្ឋប្បវេណី។

**បានឃើញ** សំណុំរឿងរដ្ឋប្បវេណីលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ.... របស់សាលាដំបូង... ។

រវាង**ម្ចាស់បំណុលឈ្មោះ** ............ អសយដ្ឋាន .....

និង**កូនបំណុលឈ្មោះ** ................ អសយដ្ឋាន ....

ដែលមានកម្មវត្ថុបណ្តឹង៖ ..............................

**បានឃើញ** ពាក្យសុំឲ្យចេញដីកាសម្រេចដាស់តឿន ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់ម្ចាស់បំណុលឈ្មោះ .... ។

**<u>សំអាងហេតុ</u>**

- ....................................................................................................................................... ។
- ....................................................................................................................................... ។
- ....................................................................................................................................... ។

<u>ហេតុដូច្នេះសម្រេច</u>

បង្គាប់ឲ្យកូនបំណុលឈ្មោះ ..... សងជាប្រាក់ចំនួន ............ ទៅឲ្យម្ចាស់បំណុលឈ្មោះ ....... ។

**បើកូនបំណុលមិនបានដាក់ពាក្យប្តឹងតវ៉ាការដាស់តឿន ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ បន្ទាប់ពីបានទទួល ការបញ្ជូននូវដីកាសម្រេចដាស់តឿននេះទេ នោះតុលាការត្រូវប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។**

ធ្វើនៅ ....., ថ្ងៃទី... ខែ... ឆ្នាំ... ។

ចៅក្រម

# គំរូ
# ដីកាសម្រេចលើកចោល
# ពាក្យសុំតវ៉ា
# ចំពោះ
# ដីកាសម្រេចដាស់តឿន

ដីកាសម្រេចលើកចោល

ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន

យើង ................. ជាចៅក្រមនៃសាលាដំបូង... ។

**បានឃើញ** មាត្រា៣២៦ និងមាត្រាពាក់ព័ន្ធផ្សេងទៀតនៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**បានឃើញ** សំណុំរឿងរដ្ឋប្បវេណីលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ.... របស់សាលាដំបូង... ។

**បានឃើញ** ដីកាសម្រេចដាស់តឿន ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់សាលាដំបូង .... ។

**បានឃើញ** ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់កូនបំណុលឈ្មោះ .... ។

## <u>សំអាងហេតុ</u>

- ........................................................................................................................................ ។
- ........................................................................................................................................ ។
- ........................................................................................................................................ ។

## <u>ហេតុដូច្នេះសម្រេច</u>

លើកចោលពាក្យសុំតវ៉ា ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់កូនបំណុលឈ្មោះ.... ចោលជាអសារបង់ ។

ធ្វើនៅ ....., ថ្ងៃទី... ខែ... ឆ្នាំ... ។

ចៅក្រម

# រូបមន្តអនុវត្តសាលក្រម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ
លេខ:..........

# រូបមន្តអនុវត្តសាលក្រម

**យើង ក្រឡាបញ្ជីនៃសាលាដំបូងខេត្តព្រះសីហនុ**

-បានឃើញ មាត្រា ៣៥៤,៣៥៥,៣៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ: ១០ "ង" ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញ លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមលេខ:..04.ក.ស/20 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ ២០២០ របស់ឈ្មោះ ជាដើមចោទ។

-បានឃើញ ពាក្យសុំផ្តល់រូបមន្តអនុវត្ត ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ ជាដើមចោទ។

**សូមបញ្ជាក់ខ្លឹមសារនៃការអនុវត្ត មានដូចខាងក្រោមនេះ**

**ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ** ភេទប្រុស អាយុ៦៩ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ននៅក្រុមទី១១ ភូមិបន្ទាយប្រិយ ឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

**អាចអនុវត្តដោយបង្ខំ** តាមអំណាចសាលក្រមរដ្ឋប្បវេណីលេខ: ១០ "ង" ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុចសេចក្តីសម្រេចបញ្ចប់ទាំងមូល។

**លើកូនបំណុលនៃការអនុវត្តឈ្មោះ** , ភេទស្រី អាយុ៥២ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ននៅក្រុមទី១១ ភូមិបន្ទាយប្រិយ ឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកស្ថាប័ននៃការអនុវត្តដោយបង្ខំ ឱ្យបានសម្រេចតាមសាលក្រមស្ថាពរនេះ និងឱ្យអាជ្ញាធរសាធារណៈជួយអនុវត្តសាលក្រមនេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

ថ្ងៃពុធ ៦រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ខេត្តព្រះសីហនុ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០
ក្រឡាបញ្ជី

# ឧបសម្ព័ន្ធរូបភាព

# គំនូស និង
# ការសង្ខេបពីលំហូរ
# នៃនីតិវិធីដាស់តឿន

## គំនូស-សង្ខេបស្ដីពីលំហូរនីតិវិធីដាស់តឿន ៖

ពាក្យសុំចេញដីកាសម្រេចដាស់តឿន
CCP320、322

↓

ចេញដីកាសម្រេចដាស់តឿន
CCP323, 324

↓

ការបញ្ជូនដីកាសម្រេចដាស់តឿន
CCP325

២សប្ដាហ៍ →

***ពាក្យសុំតវ៉ានឹងការដាស់តឿនមុនពេលប្រកាសអនុវត្តបណ្ដោះអាសន្ន***
***CCP323Ⅱ、326、327***

↓ ២សប្ដាហ៍

***ប្រកាសអនុវត្តបណ្ដោះអាសន្ន***
***CCP328***

↓

***ការបញ្ជូនដីកាសម្រេចដាស់តឿនដោយភ្ជាប់ការប្រកាសអនុវត្តបណ្ដោះអាសន្ន CCP328***

២សប្ដាហ៍ →

ពាក្យសុំតវ៉ានឹងការដាស់តឿនក្រោយពេលប្រកាសអនុវត្តបណ្ដោះអាសន្ន CCP329330

↓

នីតិវិធីបណ្ដឹង
CCP331332

↓ ២សប្ដាហ៍

***ស្ថាពរ***
***CCP333***

↓

***ករណីកូនបំណុលមិនព្រមសងដោយស្ម័គ្រចិត្ត***

↓

***ពាក្យសុំអនុវត្តដោយបង្ខំ***
CCP334～